ក្រុម... ទម្លាប់
COMMISSION DES MOEURS ET COUTUMES

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE

ឆ្នាំទី៣៤ លេខ ៧ ខែ កក្កដា

ព.ស. ២៥០៤ គ.ស. ១៩៦២

- ភ្នំពេញ -

ក-២២៤

ពុទ្ធសាសនបណ្ឌិត្យ
បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ

ចេញរាល់ខែពីពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង


ផ្នែកសាសនា — ទំព័រ

— អដ្ឋង្គិកមគ្គ អធិប្បាយ អ្នកឧកញ៉ា ទា-សាន អតីតរដ្ឋមន្ត្រី រៀបរៀង (តចប់) . . . ៧២៣
— ព្រះអភិធម្មបិដក (គម្ពីរព្រះយមកៈ) លោកប៊ូ-ប៊ុ ប្រែរៀបរៀង (ត) . . . . . ៧៣៣
— មធុរសវាហិណី សម្ដេចព្រះធម្មលិខិត ល្វី-ឯម ឧត្តមប្រឹក្សា ប្រែរៀបរៀង (ត) . . ៧៤១
— មហោសធជាតក លោក អ៊ឹម-កែន ចម្លងពីសាស្ត្រាស្លឹករឹតព្រះពុទ្ធវង្ស កឹម-គួរ ពិនិត្យ (ត) ៧៥០
— ប្រវត្តិព្រះឥន្ទនឹងសង្គ្រាមអសុរ (ពាក្យកាព្យ) លោកផល-ទិត្យ និពន្ធ (តចប់) . . . ៧៦៣

ផ្នែកអក្សរសាស្ត្រ

— ភាសានិងអក្សរសាស្ត្រខ្មែរ លោក ឱក-គាម រៀបរៀង (ត) . . . . . . . ៧៧៦
— ពាក្យខ្មែរប្រែពីបរទេស ដោយគណៈកម្មការជាតិនៃការសិក្សាផ្នែកអក្សរ "ក" (ត) . . ៧៩១
— វចនានុក្រមសំស្ក្រឹត-ខ្មែរ ព្រះមហា ប៉ាង-ខាត់ រៀបរៀង (ត) . . . . . . . ៧៩២
— រឿងសាមកុក អ្នកឧកញ៉ា នូ-កន ប្រែរៀបរៀង (ត) . . . . . . . . . ៧៩៣
— រឿងព្រេងទាក់ទងដោយប្រវត្តិសាស្ត្រប្រទេសកម្ពុជា . . . . . . . . ៨១២
— អង្គរនឹងសម័យអង្គរ លោក ផេង-ជ្រីវ ប្រែពីទស្សនាវដ្ដី "ញ៉ូ-អ្យូយ៉ង់" (ក្រុងប្រាក) លេខ ៣/១៩៦១ . . . . . . . . . . . . . . . . . ៨២០
— អ្នករៀនដើម្បីជាតិ លោកអ៊ាំង-ហួន អតីតអប់រំសុខភាពខេត្តសៀមរាបរៀបរៀង . . . ៨២៩

បច្ចុប្បន្នភាពជាតិ

— ព្រះរាជពិធីបួងសួងលាព្រះបំណន់នៅខេត្តសៀមរាប និងព្រះវិហារសួរ (កណ្ដាល) . . ៨៣១


មួយឆ្នាំមាន ១២ សៀវភៅ តម្លៃជារ ២៣០រ០០

LIBRARY
INSTITUT

34è Année — N° 7 — Juillet 1962

# KAMBUJASURIYA

Revue mensuelle de culture religieuse et littéraire publiée par l'Institut-Bouddhique de Phnom-Penh

## SOMMAIRE

### Partie religieuse


—Athangikamgga expliqué par l'Oknha TEA-SAN (suite et fin) . . 723

—Préah Abhidhamma pitaka «Kampir Préah Yamaka» par M. BOU-PO (suite) . . . . . . . . . . . . . . . . 733

—Madhurasavahini par Samdech Préah Dhammalikhita LOUIS-EM (suite) . . . . . . . . . . . . . . . . 741

—Mahosotha Jataka relevé du manuscrit sur feuilles de la tanier par M. IM-PHON, revu et corrigé par le Vén. KEM-TO (suite) . . 751

—L'Histoire d'Indra et de la guerre des Asora (en vers) par M. PHAL-TIT (suite et fin) . . . . . . . . . . . . . . 763


### Partie littéraire


—Le Langage et la littérature Khmèrs par M. DIK-KEAM (suite) . . 776

—Activité de la Commission Culturelle chapitre «Ka» (suite) . . . 791

—Dictionnaire Sanscrit-Khmer par Vén. PANG-KHAT (suite) . . . 792

—Histoire de Sam-Kok traduite par Oknha NOU-KAN (suite) . . . 793

—Un conte relatif à l'histoire du Kampuchéa . . . . . . . . . 812

—Angkor et son époque traduit de New-Orient (Prague) n° 3/1961 par M. PHÉNG-CHRIV . . . . . . . . . . . . . . . . 820

—S'instuire pour l'intérêt de la Nation par M. AING-HUON . . . . 829


### Actualités Nationales


—Céremonies Royales de BUONGSUONG à la Province de SIEMRÉAP et de KANDAL . . . . . . . . . . . . . . . . 831


Prix d'Abonnement annuel (comprenant 12 numéros) : 230 $ 00

## ផ្នែកសាសនា

## អដ្ឋង្គិកមគ្គអធិប្បាយ

ពាក្យឃាត់មិនឲ្យ ធ្វើការអាក្រក់
ជាការណាមក ឲ្យធ្វើល្អទៅ ។
ឲ្យដុសខាត់ចិត្ត កុំឲ្យហ្មងសៅ
នេះឯងលោកហៅ ពុទ្ធសាសនា ។

ប.ព.

អ្នកឧកញ៉ា ឆា-សា ជ អតីតរដ្ឋមន្ត្រីរៀបរៀង

(តមក)

ឯខន្ធ ៥ នេះជាអនិច្ចំ មិនទៀង មិនតាំងនៅឋិតថេរយូរអង្វែងឡើយ ពីព្រោះខន្ធ ៥ នោះដែលហេតុបច្ច័យតាក់តែងឲ្យកើតមានឡើងហើយ ត្រូវតែទ្រុឌទ្រោមចាស់គ្រាំគ្រាវិនាសសាបសូន្យទៅវិញជាធម្មតា ។

ខន្ធ ៥ ជាទុក្ខំ នាំមកនូវទុក្ខ ព្រោះកិរិយាចាស់គ្រាំគ្រាទ្រុឌទ្រោមវិនាសទៅវិញ ដោយជរា ព្យាធិ មរណៈ តែងនាំមកនូវទុក្ខសោកសង្រេងខ្លោចផ្សាគ្រប់យ៉ាង ។

ខន្ធ ៥ ជាអនត្តា មិនមែនជារបស់យើង មិនមែនជាខ្លួនប្រាណរបស់យើងទេ ពីព្រោះខន្ធ ៥ នេះ មិនស្តាប់បង្គាប់យើងឡើយ បើទុកជាយើងបង្គាប់ថាខន្ធ ៥ កុំចាស់ កុំឈឺ កុំស្លាប់ក៏ដោយ ខន្ធ ៥ នៅតែចាស់ ឈឺ ស្លាប់ជាធម្មតាឥតមានស្តាប់បង្គាប់អ្នកឯណាឡើយ ។

មិនតែប៉ុណ្ណោះខន្ធ ៥ នេះលោកចាត់ទុក៖

១- ដូចជារបស់ខ្ចីគេប្រើ ៈ- ធម្មតារបស់ខ្ចីគេ កាលប្រើប្រាស់តាមត្រូវការរួចហើយ ត្រូវតែប្រគល់ឲ្យទៅម្ចាស់គេវិញ ។

ដោយហេតុនេះ យើងពុំគប្បីប្រកាន់មាំក្នុងចិត្តថា ខន្ធ ៥ នោះជារបស់យើង ជាយើង ជាខ្លួនប្រាណរបស់យើងឡើយ ពីព្រោះការតាំងចិត្តប្រកាន់មាំដូច្នេះ នាំឲ្យយើងជំពាក់ជាប់ចិត្តនឹងខន្ធ ៥ នោះ ដែលជាហេតុនាំឲ្យយើងតក់ស្លុតរន្ធត់ចិត្ត ព្រួយចិត្ត ខ្លោចផ្សាចិត្ត នៅវេលាដែលខន្ធនោះមានវិបត្តិប្រែប្រួលម្តងៗ ដោយជរា ព្យាធិ ឬមរណៈមកបៀតបៀនពុំខានឡើយ ។

២- ដូចជាផ្ទះភ្លើងឆេះ ៈ- ធម្មតាផ្ទះដែលភ្លើងឆេះ រមែងតែឆេះខ្ទេចខ្ទីវិនាសសាបសូន្យអស់ដូចម្តេចមិញ រីឯខន្ធ ៥ ដែលឆេះដោយភ្លើងកិលេសនឹងភ្លើងទុក្ខ ក៏តែងតែឆេះទ្រុឌទ្រោមបែកធ្លាយវិនាសខ្ទេចខ្ទីសាបសូន្យអស់ក៏ដូច្នោះដែរ ពីព្រោះខន្ធ ៥ ដែលហេតុបច្ច័យតាក់តែងឲ្យកើតឡើងហើយរមែងតែចាស់គ្រាំគ្រាទ្រុឌទ្រោមវិនាសសាបសូន្យអស់ទៅវិញជាធម្មតា ។

៣- ជាទីប្រជុំនៃសាកអសុគ្គី អាការៈ ៣២ មានសក់ រោម ស្បែកឆ្អឹងជាដើមដែលសុទ្ធតែជារបស់បដិក្កូលគួរឲ្យខ្ពើម ។

៤- មិនតែប៉ុណ្ណោះខន្ធ ៥ នេះជាភារៈ គឺជាបន្ទុកមួយដ៏ធ្ងន់ពន់ពេក

គួរតែខ្មាក់ចោល ពីព្រោះការឧបត្ថម្ភទុកបំរុងខន្ធ ៥ នេះឲ្យមានដំណើរប្រព្រឹត្តទៅបានសុខស្រួលជាប្រក្រតីនោះ បង្ខំសត្វឲ្យរវល់ប្រឹងប្រែងខ្នះខ្នែងឥតគិតដល់ការលំបាកនឿយហត់អ្វីសោះ គឺគិតតែខំប្រកបការងារគ្រប់បែបយ៉ាង ជួបប្រទះនឹងគ្រោះថ្នាក់ធ្ងន់ឬស្រាល ឬជួបប្រទះនឹងសេចក្តីទុក្ខព្រួយលំបាកគ្រប់បែបយ៉ាង រកសេចក្តីសប្បាយសុខស្រួលគ្មានឡើយៗ

រីឯអារម្មណ៍៥ នោះគឺៈ

១- រូប គឺសំដៅរូបសត្វនឹងរូបសង្ខារ.- ឯរូបសត្វ បានដល់រូបមនុស្សនឹងសត្វ, រីឯរូបសង្ខារ បានដល់រូបដែលគេតាក់តែងឲ្យកើតឡើងជារូបដូចផ្ទះជាដើម ៗ

២- សម្លេង គឺសំដៅសម្លេងសត្វ នឹងសម្លេងសង្ខារ ៗ សម្លេងសត្វបានដល់សម្លេងមនុស្សសត្វជាដើម, សម្លេងសង្ខារបានដល់សម្លេងដែលគេតាក់តែងឲ្យកើតឡើងជាសម្លេងមានសម្លេងទ្រ ចាប៉ី ខ្លុយជាដើមៗ

៣- ក្លិន គឺសំដៅក្លិនផ្កា ក្លិនគ្រឿងក្រអូប នឹងក្លិនរូប ៗ

៤- រស គឺសំដៅសម្ផស្សដែលប៉ះពាល់ត្រូវដោយអណ្តាត មានការប៉ះពាល់ត្រូវភោជនាហារដោយអណ្តាតជាដើម ៗ

៥- ផោដ្ឋព្វៈ គឺសំដៅសម្ផស្សដែលប៉ះពាល់ត្រូវដោយកាយ មានការស្ទាប ឧបជាដើមដែលអាចនឹងញុំាងកត. គឺសេចក្តីត្រេកត្រអាលឲ្យកើតឡើង ៗ

ឯអារម្មណ៍ទាំង ៥ ដូចខាងលើ សុទ្ធតែមានសុភនិមិត្តជាគ្រឿងសម្គាល់ថាល្អ, ដូចជារូប មានសោភគណភាពជាដើម ជាសុភនិមិត្ត, សំឡេងមានពីរោះជាសុភនិមិត្ត ។ល។

ឯសុភនិមិត្តនេះហើយដែលជាគ្រឿងសំរើបចិត្ត, លួងលោមចិត្តឲ្យប្រាថ្នានូវអារម្មណ៍ ៥ នោះ ដែលជាហេតុនឹងញ៉ាំងរាគៈ គឺសេចក្ដីត្រេកត្រអាល ឬសេចក្ដីសប្បាយរីករាយឲ្យកើតមានឡើងជាលំដាប់ ។

ដោយហេតុនោះ ទើបបណ្ឌិតលោកចាត់ទុកអារម្មណ៍៥ នោះជាវត្ថុកាម គឺវត្ថុជាទីគួរឲ្យពេញចិត្ត, គួរឲ្យស្រឡាញ់នឹងគួរឲ្យប្រាថ្នា ។

ចំណែកឯរាគៈដែលកើតឡើងដោយអារម្មណ៍ ៥ នោះ បណ្ឌិតលោកចាត់ទុកជាកិលេសកាម គឺកិលេសជាគ្រឿងញុះញង់ចិត្តឲ្យស្រឡាញ់ នឹងឲ្យប្រាថ្នានូវអារម្មណ៍ ៥ នោះវិញថែមទៀត ។

គឺអារម្មណ៍ ៥ នេះហើយ ដែលធ្វើសត្វឲ្យស្រវឹង ឲ្យវង្វេងក្រេបភ្លាំងស្មារតីបណ្ដោយចិត្តឲ្យជាប់ជំពាក់នឹងកាមគុណ ៥ នោះឯង ។

គឺអារម្មណ៍ ៥ នេះហើយ ដែលធ្វើសត្វឲ្យធ្លាក់ខ្លួនទៅជាខ្ញុំនៃតណ្ហា, វិលកើតវិលស្លាប់ក្នុងវដ្ដសង្សារទុក្ខវេទនារកទីបញ្ចប់គ្មានឡើយ ។

៣– តើបណ្ឌិតលោកប្រើឧបាយដូចម្ដេច ដើម្បីនឹងរារាំងកុំឲ្យចិត្តលុះទៅក្នុងការលួងលោមនៃអារម្មណ៍ ៥ នោះបាន?

ដើម្បីនឹងរាំងចិត្តកុំឲ្យលុះទៅក្នុងការលួងលោមរបស់អារម្មណ៍ ៥

នោះបាន បណ្ឌិតទាំងឡាយ មានអរិយបុគ្គលជាដើម លោករមែងតែព្យាយាមចំរើនរូបជ្ឈាន ៤ មានបឋមជ្ឈានជាដើម ដើម្បីនឹងលះអង្គឈាន ៤ គឺវិតក្កៈ, វិចារៈ, បីតិ និងសុខ ឲ្យដាច់ស្រឡះកុំឲ្យមានដំណើរប្រព្រឹត្តទៅបានទៀត ដែលជាហេតុនឹងធ្វើឲ្យវចីសង្ខារ គឺវិតក្កៈ, វិចារៈ ហើយនិងចិត្តសង្ខារ គឺសញ្ញា ៦ និងវេទនា ៤ គឺសោមនស្ស, ទោមនស្ស, សុខ និងទុក្ខរលត់ព្រមទៅជាមួយគ្នាជាលំដាប់ ។

កាលបើវេទនា ៤ នេះរលត់អស់លែងប្រព្រឹត្តទៅបានទៀតហើយ ទើបនៅខណៈនោះវេទនាទី ៥ គឺឧបេក្ខាក៏កើតឡើងហើយតាំងនៅជាស្ថាពរ ជាគូអង្គទី ២ នៃចតុត្ថជ្ឈាននោះឯង ។

គឺឧបេក្ខានេះហើយ ដែលបណ្ឌិតលោកចាត់ទុកថាជាឆឡង្គុបេក្ខា គឺឧបេក្ខាដែលអាចពាំងចិត្ត, ឧបត្ថម្ភចិត្តមិនឲ្យលុះទៅក្នុងការលួងលោមនៃអារម្មណ៍ ៦ នោះបាន ព្រមទាំងអាចការពារទ្រទ្រង់ចិត្តមិនឲ្យលុះទៅក្នុងការញុះញង់នៃរាគៈ ទោសៈបានថែមទៀត ។ ពីព្រោះ ឆឡង្គុបេក្ខានោះ កាលកើតមានក្នុងខន្ធសន្តានហើយ រមែងតែតាំងនៅជាកណ្តាលមិនអើពើ គឺមិនសោមនស្សមិនទោមនស្សជានិច្ចចំពោះឥដ្ឋានិដ្ឋារម្មណ៍ ដែលជាហេតុធ្វើឲ្យរាគៈនិងទោសៈ គ្មានឱកាសនឹងចូលមកកើតក្នុងខន្ធសន្តានបានសោះ ។

អាស្រ័យហេតុនេះ បានជាអរិយបុគ្គលដែលបានសម្រេចចតុត្ថជ្ឈាន

ប្រកបដោយអង្គឯកគ្គតានឹងឧបេក្ខា រមែងតែលះរាគៈ ទោសៈ ដាច់ស្រឡះដោយសមុច្ឆេទប្បហាន ហើយបានត្រាស់ដឹងនូវអនាគាមិមគ្គនិងអនាគាមិផលជាលំដាប់ដូច្នេះឯង ។

លំដាប់តទៅនេះ ខ្ញុំនឹងធ្វើអត្ថាធិប្បាយអំពីសមថកម្មដ្ឋាន និងវិបស្សនាកម្មដ្ឋាន ដែលជាកម្មដ្ឋានអាចញ៉ាំងការត្រាស់ដឹងមគ្គ ៤ ផល ៤ និងនិព្វានឲ្យសម្រេចឡើងបានដូចតទៅនេះ ៖

## ៨- តើកម្មដ្ឋានទាំង ២ ប្រការនេះ ជាកម្មដ្ឋានពិបាកហួសវិស័យនៃយោគាវចរក្នុងបច្ចុប្បន្ននឹងចំរើនឲ្យសម្រេចប្រយោជន៍ ឬដូចម្ដេច ?

តាមយោបល់ខ្ញុំនោះ កម្មដ្ឋានទាំង ២ ប្រការនេះ ពិតជាមជ្ឈិមាបដិបទាគឺបដិបទាយ៉ាងកណ្ដាលមិនតឹងពេកមិនធូរពេក ដែលយោគីអាចនឹងព្យាយាមបំពេញឲ្យសម្រេចទៅបានដោយស្រួលទេ ពីព្រោះខ្ញុំយល់ឃើញថា ការដែលពិបាកបំផុតនោះ គឺការចំរើនកសិណ ពីព្រោះការចំរើនកសិណ ដែលជាបុព្វកិច្ច រមែងតែនាំឲ្យជួបប្រទះនឹងឧបសគ្គគ្រប់យ៉ាងពុំខានឡើយ ។

ម្យ៉ាងទៀត ការពត់តម្រង់ចិត្តឲ្យនៅស៊ប់ក្នុងអារម្មណ៍តែមួយ ក៏ជាការពិបាកបំផុតដែរ មិនងាយនឹងធ្វើឲ្យបានសម្រេចក្នុងរយៈពេលដ៏ខ្លីទៅ

បានឡើយ ពីព្រោះចិត្តជាធម្មជាតមិនចេះនៅស្ងៀម មិនព្រមនៅនឹងមួយកន្លែង ដោយចិត្តនោះចេះតែអន្ទះអន្ទែងឆ្វេឆ្វាចង់រកផ្លូវនឹងស្ទុះចេញទៅកាន់អារម្មណ៍នៅគ្រប់ទិសទីជានិច្ច ទោះនៅជិតឬនៅឆ្ងាយក៏ដោយ ។

អាស្រ័យហេតុនេះ ទើបយោគាវចរអង្គណាបានតាំងចិត្តយ៉ាងមាំក្នុងការចំរើនកម្មដ្ឋាន ហើយព្យាយាមតស៊ូចំពោះឧបសគ្គទាំងឡាយ លុះត្រាតែបានសម្រេចនូវអប្បនាសមាធិ គឺចិត្តតាំងចុះស៊ប់នៅក្នុងអារម្មណ៍តែមួយកាលណាហើយ យោគាវចរអង្គនោះគង់នឹងមានសង្ឃឹមទុកជាមុនថា មុខតែនឹងមានភ័ព្វសំណាងដើរទៅដល់ទីដៅគោលគឺការត្រាស់ដឹងមគ្គ៤ផល ៤ នឹងនិព្វានពុំខានឡើយ ពីព្រោះអប្បនាសមាធិនោះទុកដូចជាកូនសោរមួយពិសេសសម្រាប់ឲ្យយោគាវចរចាក់បើកទ្វារកម្មដ្ឋានផ្សេង ៗ ដើរចូលទៅកាន់មគ្គ ផល និព្វាន សមតាមសេចក្ដីប្រាថ្នាទៅបាន ។

ឯហេតុដែលនាំខ្ញុំឲ្យហ៊ានវិនិច្ឆ័យដូច្នេះ ពីព្រោះខ្ញុំយល់ឃើញថា គុណធម៌ទាំងឡាយដែលនឹងសម្រេចឡើងបាន ក៏ត្រូវអាស្រ័យអប្បនា-សមាធិជាមូលដ្ឋាន ។

មែនពិត ការចំរើនវិបស្សនាភាវនាដោយចិត្តស្ងប់ជាអប្បនាសមាធិ រមែងតែញុំាងវិបស្សនាញាណ គឺញាណដែលដឹងនូវដំណើរសង្ខារធម៌ទៅតាមការណ៍ពិតឲ្យសម្រេចឡើងបាន ។

ឯការចំរើនឈាន ក៏ត្រូវការអប្បនាសមាធិជាមូលដ្ឋានដែរ ពីព្រោះ

ឈានចិត្តទាំង ៨ សុទ្ធតែសម្បយុត្តដោយអង្គឯកគ្គតា គឺអប្បនាសមាធិនោះឯង ។

អាស្រ័យហេតុនេះ បើពុទ្ធបរិស័ទណាមានចិត្តប្រាថ្នាចង់ត្រាស់ដឹងនូវលោកុត្តរធម៌នោះ គប្បីចាប់បដិបត្តិធម៌ទៅតាមកម្មវិធីដែលខ្ញុំបានរៀបរាប់ទុកក្នុងសៀវភៅ លោកុត្តរាភិសម័យ ជាកិច្ចពិសោធន៍ល្បងមើលទៅកុំឲ្យខាន ក្រែងឧបនិស្ស័យដែលបានកសាងសន្សំទុកពីអតីតជាតិ ជួយឧបត្ថម្ភនាំឲ្យបានសម្រេចគោលបំណងនៅថ្ងៃណាមួយទៅក៏មិនដឹង?

ម្យ៉ាងវិញទៀត ឯការត្រាស់ដឹងមគ្គ ៤ ផល ៤ នោះមានមជ្ឈដ្ឋានអ្នកជំនាញខាងពុទ្ធសាសនាខ្លះ អះអាងថាមិនចាំបាច់ចំរើនសមថកម្មដ្ឋាន មានការចំរើនកសិណនិងឈាននោះទេ គឺចំរើនតែវិបស្សនាភាវនា ក៏អាចនឹងញ៉ាំងការត្រាស់ដឹងមគ្គផលនោះដែរ ដោយសំអាងទៅព្រះអរហន្តសុក្ខវិបស្សកា ដែលចំរើនតែវិបស្សនាសុទ្ធជាតួយ៉ាងស្រាប់ ។

ចំពោះរឿងនេះ ខ្ញុំមិនយល់ស្របទៅតាមមតិខាងលើនេះទេ ពីព្រោះខ្ញុំយល់ឃើញថា មានតែប្រជុំនៃកម្មដ្ឋាន ២ គឺសមថកម្មដ្ឋាន និងវិបស្សនាកម្មដ្ឋានតែប៉ុណ្ណោះទេ ដែលអាចញ៉ាំងខន្ធសន្តានឲ្យរួចចាកសំយោជនៈ ១០ ដើម្បីការត្រាស់ដឹងមគ្គ ៤ និងផល ៤ បានជាដាច់ខាត ដោយសំអាងថាការចំរើនកសិណ និងឈានតែងផ្តល់ឲ្យយោគាវចរនូវសមាធិ និងឈានចិត្ត ដែលជាគ្រឿងអាចញ៉ាំងចេតោវិមុត្តិ គឺការរួចចាកកិលេស

ដោយផ្តុំចិត្តឲ្យសម្រេចទៅបាន ហើយម្យ៉ាងទៀត ការចំរើនវិបស្សនាកម្ម-ដ្ឋាន ក៏រមែងហុចឲ្យកើតនូវវិបស្សនាញាណ ដែលជាគ្រឿងអាចនាំឲ្យបញ្ញាវិមុត្តិ គឺការរួចចាកកិលេសដោយបញ្ញាកើតឡើងបាន ។

មែនពិត ក្នុងបណ្តាសំយោជនៈ ១០ មានសំយោជនៈ ៤ គឺសក្កាយ-ទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាស និងអវិជ្ជា ត្រូវលះដោយបញ្ញា, ហើយសំយោជនៈ ៦ ទៀតគឺ កាមរាគ បដិឃៈ រូបរាគ អរូបរាគៈ មានះ និងឧទ្ធច្ចៈ ត្រូវលះដោយចិត្ត ពោលគឺដោយឈានចិត្តនោះឯង ។

តាមយោបល់ខ្ញុំ ការចំរើនវិបស្សនាការដោយចិត្តមិនសម្បយុត្តដោយអប្បនាសមាធិ តាំងនៅក្នុងអារម្មណ៍តែមួយទេ ពុំអាចនឹងញុំាងវិបស្សនា-ញាណ គឺញាណដែលដឹងច្បាស់នូវដំណើរសង្ខារធម៌ មានបញ្ចក្ខន្ធជាដើមទៅតាមហេតុពិត ឲ្យសម្រេចកើតមានឡើងបានឡើយ ។

អាស្រ័យហេតុនេះ បានជាខ្ញុំយល់ឃើញថាមានតែប្រជុំភាវនា ២ គឺសមថភាវនា វិបស្សនាភាវនានោះទេ ដែលអាចញុំាងការត្រាស់ដឹងមគ្គផល និព្វាន ឲ្យសំរេចឡើងបានដោយប្រការដូច្នេះឯង ។

រីឯមជ្ឈដ្ឋានខ្លះ ដែលអះអាងថាការចំរើនវិបស្សនាភាវនាអាចនាំឲ្យត្រាស់អរហត្តមគ្គ អហត្តផលបាន ដោយលើកយកព្រះអហន្តសុក្ខវិបស្ស-កោ ជាឧទាហរណ៍នោះ គឺសំដៅការត្រាស់ដឹងក្នុងសម័យពុទ្ធកាល ពី

ព្រោះក្នុងពុទ្ធសម័យ ទើបមានព្រះអរហន្ត ៤ ពួក មានព្រះអរហន្តសុក្ខវិបស្សកោជាដើម ។

បើពោលក្នុងពុទ្ធកាលវិញ ឃើញថាមិនចាំបាច់តាំងចំរើនវិបស្សនាភាវនា ឬសមថភាវនាផង ក៏មានពុទ្ធបរិស័ទជាច្រើនអាចត្រាស់ដឹងលោកុត្តរធម៌បានដែរ ពីព្រោះក្នុងជំនាន់ពុទ្ធកាលនោះ ព្រះសម្ពុទ្ធជាបរមគ្រូព្រះអង្គតែងតែសំដែងធម្មទេសនាប្រោសសត្វ ដែលមានបុញ្ញាភិនីហារក្រាស់ មានបញ្ញិន្ទ្រិយ៍ជាដើម ឲ្យត្រាស់ដឹងលោកុត្តរធម៌ ចាប់ពីសោតា រហូតដល់ព្រះអរហត្ត ពុំអាចនឹងរាប់ឈ្មោះឲ្យអស់បានផង ។

សរុបសេចក្តីទៅ ខ្ញុំសូមអំពាវនាវដល់ពុទ្ធបរិស័ទដែលបានអានសៀវភៅនេះ មេត្តាជួយពិនិត្យអំពីរឿងនេះឲ្យបានជាក់ច្បាស់ឡើង ដើម្បីបំបាត់កុំឲ្យនៅមានមតិខុសគ្នាចំពោះវត្តប្រតិបត្តិ ដើម្បីមគ្គ ផល និព្វាននោះតទៅទៀត ពីព្រោះពុទ្ធកាលកន្លងផុតទៅបាន ២៥ សតវត្សទៅហើយ គេពុំទាន់បានឮដំណឹងថាមានយោគាវចរ ពុទ្ធសាសនិកអង្គណាមួយបានសម្រេចនូវលោកុត្តរភិសម័យនៅឡើយសោះ ។

ព្រះអភិធម្មបិដក

# គម្ពីរព្រះយមកៈ

លោក ប៊ូ - ប៊ី ប្រែរៀបរៀង

( តមក )

---

## ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច

កាលណាអង្គសម្តេចព្រះមានព្រះភាគត្រាស់ទេសនាទុក្ខនិរោធគាមិនីបដិបទាអរិយសច្ចជាគំរប់បួនតទៅ ទ្រង់ត្រាស់បុច្ឆាថា របស់ពិតនៃព្រះអរិយៈជាគំរប់បួននោះតើមានប្រការដូចម្តេច គឺរបស់អ្វី ?

ទើបទ្រង់ត្រាស់វិសជ្ជនាថា របស់ពិតនៃព្រះអរិយៈជាគំរប់បួននោះ គឺបដិបទាដ៏ញុំាងសត្វឲ្យដល់នូវព្រះនិព្វានជាទីរលត់ទុក្ខ ។

ទ្រង់ត្រាស់បុច្ឆាថា បដិបទាដ៏ញុំាងសត្វឲ្យដល់នូវព្រះនិព្វាននោះតើគឺអ្វី ?

ទ្រង់ត្រាស់វិសជ្ជនាថា គឺព្រះអដ្ឋង្គិមគ្គ ផ្លូវមានអង្គប្រាំបីប្រការ ។

ទ្រង់ត្រាស់បុច្ឆាថា ចុះអដ្ឋង្គិកមគ្គ ផ្លូវមានអង្គប្រាំបីនោះតើដូចម្តេច?

ទ្រង់ត្រាស់វិសជ្ជនាថា ព្រះអដ្ឋង្គិកមគ្គ ផ្លូវមានអង្គប្រាំបីប្រការនោះគឺ សម្មាទិដ្ឋិ ១ សម្មាសង្កប្បៈ ១ សម្មាវាចា ១ សម្មាកម្មន្ត ១ សម្មាអាជីវៈ ១ សម្មាវាយាមៈ ១

សម្មាសតិ ១ សម្មាសមាធិ ១ រួមជាប្រាំបីប្រការ ។

ក្នុងសម្មាទិដ្ឋិនោះ មានព្រះពុទ្ធដីកាត្រាស់បុច្ឆាថា កតមា សម្មាទិដ្ឋិ សម្មាទិដ្ឋិនោះតើដូចម្ដេច? របស់អ្វីហៅថា សម្មាទិដ្ឋិ?

ទើបត្រាស់វិសជ្ជនាថា សម្មាទិដ្ឋិនោះ បានទឹងបញ្ញាឃើញត្រូវ ឃើញមិនវិបរិតខុសពីព្រះពុទ្ធោវាទ ឃើញនៅក្នុងកងទុក្ខ ទីកើតនៃទុក្ខជាដើម ដូច្នេះឯងឈ្មោះថា សម្មាទិដ្ឋិ ។ សម្មាទិដ្ឋិ ឃើញត្រូវក្នុងការប្រតិបត្តិដែលនឹងញុំាងសត្វឲ្យដល់នូវព្រះនិព្វាន ចាត់ជាមាគ៌ាកណ្ដាល មិនតឹងពេកមិនធូរពេក ។ ព្រះអរិយៈទាំងឡាយនឹងបានដល់នូវព្រះនិព្វាន ព្រោះហេតុធ្វើដំណើរទៅតាមមាគ៌ាគឺសម្មាទិដ្ឋិនេះ បើប្រាសចាកសម្មាទិដ្ឋិហើយ ក៏មិនអាចទៅកាន់ព្រះនិព្វានបានឡើយ ។

មានពាក្យអធិប្បាយថា សម្មាបការេន ទស្សនំ សម្មាទិដ្ឋិនោះ បានទឹងបញ្ញាពិចារណាឃើញដោយប្រពៃ ដោយកំណត់មានក្នុងទីបំផុត បញ្ញាដែលពិចារណាឃើថាសត្វកើតមកក្នុងសង្សារវដ្តទាំងអស់សុទ្ធតែមានកម្មជារបស់ខ្លួន គឺថាបានកសាងការកុសលក៏តាមឧបត្ថម្ភឲ្យប្រកបដោយទ្រព្យស្រីង្គារ បរិបូណ៌ដោយកិត្តិយសឥស្សរិយយសបរិវារយសចេញមុខចេញនាមប្រាកដដល់លោកទាំងឡាយ លោកទាំងពួងតែងស្រឡាញ់រាប់អានស្មើមុខ ។ អ្នកដែលបានកសាងអកុសលទុក អកុសលក៏ជាប់តាមឲ្យផលតាមកម្មវិស័យឲ្យសោយទុក្ខវេទនា ជាមនុស្សកំព្រា

អនាថា ទាល់ក្រគ្មានលាភ គ្មានញាតិគ្មានមិត្រជាទីស្រឡាញ់ពេញចិត្តនឹង
ប្រាថ្នាអ្វីមិនបានសម្រេចដូចប្រាថ្នា បញ្ញាពិចារណាឃើញដូច្នេះកប់ចូល
ក្នុងសម្មាទិដ្ឋិបាន ព្រោះថាបុគ្គលនឹងធ្វើការកុសលនោះ ក៏អាស្រ័យនូវ
កម្មស្សកតាញាណ ដូចសាធុជនលះបង់ការងារក្នុងផ្ទះ ដាស់តឿន
បបួលគ្នាមកស្តាប់ព្រះធម្មទេសនាអស់កាលជានិច្ច ព្រោះហេតុមានបញ្ញា
ជា សម្មាទិដ្ឋិ ។ បើបុគ្គលមានបញ្ញាជា មិច្ឆាទិដ្ឋិ ឃើញខុសពី
ព្រះពុទ្ធោវាទហើយ ក៏គ្មានចិត្តជ្រះថ្លានឹងការកុសល ឲ្យយល់ឃើញថា
នឹងខាតការងារ ឲ្យទានឃើញថានឹងអស់ទ្រព្យ រក្សាសីលនឹងនឿយ
ហត់ ត្រូវដុសខាត់កាយនឹងចិត្ត ឯចិត្តនោះមិនងាយនឹងដុសខាត់ឲ្យស្អាត
បានទេ ស្តាប់ធម្មទេសនាក៏ត្រូវអង្គុយស្តាប់ដូចគេ នឹងនាំឲ្យពេយខ្នងចង្កេះ
ជើងដៃគ្មានការសប្បាយសោះ កាលបើយល់ឃើញដូច្នេះហើយក៏កប់ចូល
ក្នុងមិច្ឆាទិដ្ឋិ ដែលនឹងឲ្យឃ្លាតឆ្ងាយពីព្រះនិព្វាន ។ ឯសម្មាទិដ្ឋិនោះ
មិនតែនាំឲ្យបានជិតព្រះនិព្វានពល់គ្រា សូម្បីនៅជាលោកិយ ក៏អាចឲ្យ
បានសម្រេចលោកុត្តរក្នុងអបរាបរកាលខាងមុខ ។ ហេតុនោះ សម្តេច
ព្រះបរមអនុត្តរញ្ញាណទ្រង់ប្រោសប្រទាន ព្រះធម្មទេសនានូវសម្មាទិដ្ឋិនេះ
ឈ្មោះថាជាបដិបទាញុំាងសត្វឲ្យដល់នូវព្រះនិព្វាន ។

ក្នុងសម្មាសង្កប្បៈនោះ សម្តេចព្រះតថាគតទ្រង់ត្រាស់ពុច្ឆាថា កតមោ សម្មាសង្កប្បោ សម្មាសង្កប្បៈនោះតើគឺអ្វី ? ទើបត្រាស់វិស-

ដូចជា សម្មាសង្កប្បៈនោះបានដឹងការត្រិះរិះត្រូវ ។ ឯការត្រិះរិះត្រូវនោះ គឺបានដឹងការត្រិះរិះក្នុងដំណើរចេញបព្វជ្ជា ហៅថា នេក្ខម្មសង្កប្បៈ១ ត្រិះរិះក្នុងការមិនព្យាបាទមនុស្សសត្វដទៃ ហៅថា អព្យាបាទសង្កប្បៈ ១ ត្រិះរិះក្នុងការមិនបៀតបៀនមនុស្សសត្វដទៃឲ្យវេទនា ហៅថា អវិហឹសាសង្កប្បៈ ១ រួមគ្នាត្រូវជាសម្មាសង្កប្បៈ ៣ ប្រការ ។

ក្នុងសម្មាវាចានោះ បានដឹងសំដីត្រូវ ។ ឯសំដីត្រូវនោះ បានដឹងការពោលពាក្យវៀរចាកវចីទុច្ចរិតបួនប្រការ ដែលផ្ទុយពីសម្មាវាចា ។ ឯវចីទុច្ចរិតបួនប្រការនោះ គឺពោលមុសាវាទ ១ ពោលជាបេសុញ្ញវាទ ១ ពោលជាផរុសវាទ ១ ពោលជាសម្ផប្បលាបវាទ ១ ។

មុសាវាទ គឺការនិយាយកុហកបញ្ឆោត, និយាយមិនពិត ដូចជារបស់មាននិយាយថាគ្មាន, របស់ដែលបានឮបានស្តាប់ប្រាប់គេថាមិនបានឮ មិនបានស្តាប់ នឹងមិនបានឃើញជាដើម ។

បេសុញ្ញវាទ គឺការនិយាយពាក្យញុះញង់កាត់កិនបំបែកបំបាក់អ្នកដទៃឲ្យគេបែកខ្ញែកចិត្តពីគ្នា ឲ្យគេស្អប់គ្នា ដើម្បីឲ្យគេមកស្រឡាញ់ខ្លួនឯងវិញ ។

ផរុសវាទ គឺការនិយាយពាក្យអាក្រក់គ្រោតគ្រាតបោះបោក ជេរប្រទេចផ្តាសា នឹងពោលប្រកបដោយអក្កោសវត្ថុដប់ប្រការ មានជេរថាអាឯងជាសត្វតិរច្ឆាន, ជាប្រេត, ជាឧដ្ឋ, ជាគោ, ជាលា, ជាសត្វនរកជាដើម ។

សម្ផប្បលាបៈ គឺការនិយាយពាក្យឥតប្រយោជន៍ បានដល់ការនិយាយពាក្យជាត្មុកកំប្លែងលេងសើច ជាហេតុដល់ឲ្យអ្នកស្តាប់សើចលេងសប្បាយជាដើម ។ ការដែលវៀរចាកវចីទុច្ចរិតបួនប្រការនេះ ឈ្មោះថាសម្មាវាចា ។

ក្នុងសម្មាកម្មន្តៈនោះ ព្រះពុទ្ធអង្គទ្រង់ត្រាស់បុច្ឆាថា កតមោ សម្មាកម្មន្តោ សម្មាកម្មន្តៈនោះតើដូចម្តេច? ទើបទ្រង់ត្រាស់វិសជ្ជនាថា សម្មាកម្មន្តៈនោះ បានដល់ការវៀរ គឺបានដល់ការលះបង់នូវកាយទុច្ចរិតបីប្រការ គឺ បាណាតិបាត មិនសម្លាប់មនុស្សឬសត្វ ១ អទិន្នាទាន មិនលួចទ្រព្យសម្បត្តិរបស់អ្នកដទៃ ១ កាមេសុមិច្ឆាចារ មិនប្រព្រឹត្តខុសក្នុងកាមដ៏ជាអគមនីយដ្ឋាន ក្នុងស្ត្រី ២០ ពួក ១ ។ ការដែលវៀរចាកកាយទុច្ចរិតបីប្រការនេះឯងហៅថា សម្មាកម្មន្តៈ ។

ក្នុងសម្មាអាជីវៈនោះ ព្រះពុទ្ធអង្គទ្រង់ត្រាស់បុច្ឆាថា កតមោ សម្មាអាជីវោ សម្មាអាជីវៈនោះតើដូចម្តេច? ទើបទ្រង់ត្រាស់វិសជ្ជនាថា សម្មាអាជីវៈនោះ បានដល់ការចិញ្ចឹមជីវិតត្រូវ ។ ឯការចិញ្ចឹមជីវិតត្រូវនោះ បានដល់កសិកម្ម, គោរក្ខកម្ម និងពាណិជ្ជកម្ម ។

កសិកម្មនោះ បានដល់ការធ្វើស្រែចម្ការច្បារដំណាំផងទាំងពួង ។

គោរក្ខកម្មនោះ បានដល់ការទទួលស៊ីឈ្នួលគេថែរក្សាគោ ឬក្របីជ្រូកសេះជាដើម យកថ្លៃឈ្នួលមកចិញ្ចឹមជីវិត ។

ពាណិជ្ជកម្ម នោះ បាននឹងការធ្វើជំនួញផ្សេង ៗ វៀរចាក មិច្ឆាពាណិជ្ជ ប្រាំប្រការដូចពោលហើយនេះ ហៅថា សម្មាអាជីវៈ ។

ក្នុងសម្មាវាយាមៈនោះ បាននឹងសម្មប្បធាន ទាំងបួន ។

ក្នុងសម្មាសតិនោះ ព្រះពុទ្ធអង្គទ្រង់ត្រាស់បុច្ឆាថា កតមា សម្មាសតិ សម្មាសតិនោះតើដូចម្តេច ? ទើបទ្រង់ត្រាស់វិសជ្ជនាថា សម្មាសតិនោះ បាននឹងការនឹករឭកត្រូវ គឺនឹករឭកក្នុងព្រះសតិបដ្ឋានទាំងបួន និងនឹករឭកក្នុងព្រះអនុស្សតិកម្មដ្ឋានទាំងដប់ប្រការ មានព្រះពុទ្ធានុស្សតិជាដើម ។ បុគ្គលដែលជាបច្ចិមាជនតាសត្វ គឺសត្វកើតក្នុងជំនាន់ក្រោយ សូម្បីនឹងពោលដោយអត្តនោមត្យាធិប្បាយ បុគ្គលទាំងឡាយដែលច្រើនទៅដោយសទ្ធាជឿ កាលឃើញវត្ថុទានហើយនឹករឭកថា របស់នោះវត្ថុនេះនឹងយកទុកដាក់ធ្វើជាបិណ្ឌបាតទានក៏បាន ព្រោះហេតុថាទាននោះនឹងបានជាឧបនិស្ស័យទៅក្នុងបរភពខាងមុខ ឯទាននោះសោតក៏រាប់បញ្ចូលក្នុងបារមី ៣០ ប្រការ សូម្បីព្រះពុទ្ធជាអម្ចាស់ទាំងឡាយដែលបានត្រាស់ដឹងនូវព្រះអនុត្តរសម្មាសម្ពោធិញ្ញាណ ក៏អាស្រ័យតែបានបំពេញទានបារមីផង ទើបបានសម្រេចគ្រប់ព្រះអង្គ ។ ព្រោះហេតុនោះ បណ្ឌិតជាតិគប្បីកំណត់ទុកក្នុងចិត្តថា ការដែលនឹករឭកថា វត្ថុនោះ ៗ អាត្មានឹងដាក់បម្រុងធ្វើបិណ្ឌបាតទាន យ៉ាងនេះក៏ចាត់ដោយវោហារថាជាសម្មាសតិបាន ព្រោះការនឹករឭកនោះផុតទោស ។ ប៉ុន្តែក្នុងព្រះពុទ្ធដីកា

ប្រាថ្នាការនឹកឭកគ្រូដែលនឹងឲ្យសម្រេចសម្បត្តិជាលោកុត្តរ ។ ឯ-លោកុត្តរសម្បត្តិនោះ ក៏សម្រេចទៅតាមសម្បត្តិក្នុងលោកិយ ។ ការនឹកឭកអ្វី ៗ ប្រាសចាកទោសឥតទោស អាចចាត់ជាសម្មាសតិបាន ព្រោះនឹងជាបច្ច័យឲ្យបានទូវលោកុត្តរសម្បត្តិក្នុងកាលខាងមុខ ។

ក្នុងសម្មាសមាធិនោះ ព្រះពុទ្ធអង្គទ្រង់ត្រាស់ទេសនាសំដៅយកចិត្តតាំងមាំក្នុងឈាន ។ ឯសត្វកើតមកក្នុងកាលខាងក្រោយនេះ មិនបានតាំងចិត្តឲ្យមាំក្នុងឈានក៏ពិតមែនហើយ ប៉ុន្តែអ្នកប្រាជ្ញបរិសុទ្ធិឋានថាចិត្តដែលតាំងមាំស៊ប់ស្ងួនក្នុងទានសីលនឹងក្នុងការកុសលទាំងពួង ក៏ហៅថា សម្មាសមាធិបាន ព្រោះសម្មាសមាធិនោះប្រែថា តាំងចិត្តមាំដោយល្អប្រពៃ ព្រះនិព្វាន បើមិនបានសម្រេច ក្នុងជាតិនេះទេ ក៏គង់ជាបច្ច័យឲ្យសម្រេចទូវព្រះនិព្វានក្នុងជាតិខាងមុខដែរ ។

អដ្ឋមគ្គទាំងប្រាំបីប្រការ មានសម្មាទិដ្ឋិជាដើម មានសម្មាសមាធិជាបរិយោសាននេះ ព្រះពុទ្ធអង្គទ្រង់ត្រាស់ទេសនាថា ជាមគ្គ, ជាផ្លូវប្រតិ-បត្តិញាំងសត្វឲ្យដល់ទូវព្រះនិព្វានជាទីលត់ទុក្ខបានពិតប្រាកដ ទើបឈ្មោះថា ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ដែលទ្រង់ត្រាស់ទេសនាក្នុងសច្ចយមកៈ ក្នុងគម្ពីរព្រះយមកៈដោយប្រការដូច្នេះ ។

---

## សង្ខារយមក

កោយោ សង្ខារោ កាយសង្ខារោ វចីសង្ខារោ ចិត្ត-

សង្ខារោតិ យស្ស កាយសង្ខារោ ឧប្បជ្ជតិ តស្ស វចី
សង្ខារោ ច ចិត្តសង្ខារោ ឧប្បជ្ជតីតិ ។

លំដាប់នេះ នឹងវិសជ្ជនាក្នុងសង្ខារយមកៈតទៅ សេចក្តីថា ភគវា សម្តេចព្រះមានព្រះភាគ កាលព្រះអង្គនឹងត្រាស់ទេសនានូវសង្ខារយមកៈនោះ ទើបមានព្រះពុទ្ធដីកាបុច្ឆាជាគូ ។ ហើយវិសជ្ជនាជាគូ ។ ដូចគ្នា ។ ព្រះអង្គទ្រង់ត្រាស់បុច្ឆាថា តយោ សង្ខារា សង្ខារទាំងឡាយនោះមានបីប្រការ គឺ កាយសង្ខារ ១ វចីសង្ខារ ១ ចិត្តសង្ខារ ១ ។

ព្រះពុទ្ធអង្គទ្រង់ត្រាស់បុច្ឆាថា កាយោ កាយសង្ខារោ ឈាម កាយនោះឬ ឈ្មោះថា កាយសង្ខារ, កាយសង្ខារនោះឬ ឈ្មោះថា កាយ ។ វចីនោះឬ ឈ្មោះថា វចីសង្ខារ វចីសង្ខារនោះឬឈ្មោះថា វចី ។ ចិត្តនោះឬឈ្មោះថា ចិត្តសង្ខារ, ចិត្តសង្ខារនោះឬឈ្មោះថា ចិត្ត?

ត្រាស់បុច្ឆាដូច្នេះហើយ ទើបត្រាស់វិសជ្ជនាថា អាមន្តា អើ! កាយនោះឯងហើយឈ្មោះថា កាយសង្ខារ, កាយសង្ខារនោះឯងហើយឈ្មោះថា កាយ ។ វចីនោះឯងហើយឈ្មោះថា វចីសង្ខារ ។ នោះឯងហើយឈ្មោះថា វចី ។ ចិត្តនោះឯងហើយឈ្មោះថា ចិត្តសង្ខារ ។ នោះឯងហើយឈ្មោះថា ចិត្ត ។

(នៅមានត)

## មធុរសភាសិណី

សម្តេចធម្មលិខិត ល្វី-ឯម ប្រែរៀបរៀង

(តមក)

លុះព្រះអង្គមានព្រះពុទ្ធដីកាដូចនេះហើយ ក៏នាំយកអតីតនិទានមកសំដែងប្រាប់ទុក្ខសោមណោថា៖ គារ បានឮរៀងៗមក នាកាលអតីតកាលកន្លងលើសទៅយូរណាស់ហើយ អ្នកបានកើតជាទារកតូចនៅអាស្រ័យក្នុងស្រុកមួយ បានលេងល្បែងជាមួយនឹងកូនក្មេងអ្នកស្រុកទាំងឡាយ ហើយបានកាន់យកបន្ទាដ៏ល្អិតស្រួចទៅដោតសត្វរុយ ដែលមានជីវិតរស់នៅឲ្យដេកជាប់លើបន្ទាដ៏ស្រួច ដោតភ្ជាប់នឹងសំបកស្តៅក្នុងមណ្ឌលសម្រាប់លេងនាកាលនោះឯងៗ ម្យ៉ាងទៀត អ្នកឯងត្រូវស្តាប់បាបកម្មរបស់អ្នកមួយសណ្ឋានទៀត, មានសេចក្តីដំណាលថា មាតារបស់អ្នកបានឃើញអ្នកលេងល្បែងមិនគួរដូចនោះហើយ ក៏ពោលទូន្មានប្រដៅអ្នកមិនឲ្យលេងល្បែងដែលប្រកបដោយពៀរដូចនោះឡើយ, ហើយអ្នកបានក្រោធខឹងដេរប្រទេចផ្តាសាទៅលើមាតាវិញថា បើម៉ែមិនឲ្យខ្ញុំលេងយ៉ាងនេះទេ មានតែម៉ែឲ្យខ្ញុំចាប់ម៉ែយកទៅដោតឲ្យអង្គុយលើឈើស្រួចទាំងរស់វិញ ហេតុតែបាបកម្មទាំងពីរយ៉ាងនេះហើយ បានជាអ្នកអន្ទោលទៅមកក្នុងសាគរគឺសង្សារវដ្ត គេតែងចាប់ចងអ្នកយកទៅឲ្យអង្គុយលើឈើអណ្តោត

តាំងរស់កំណត់ ៥០០ ជាតិនឹងជាតិនេះឯង អ្នកសោយទុក្ខវេទនាក្នុងជាតិនេះទៀតក៏នឹងបានរួចស្រឡះអំពីបាបកម្មនោះហើយ ។ លុះព្រះអង្គបានប្រកាសប្រាប់នូវបាបកម្មយ៉ាងនេះ ហើយក៏សំដែងព្រះធម៌ទេសនាតទៅទៀត ដ៏សំគួរដល់អធ្យាស្រ័យនៃឧត្តរសាមណេរដោយន័យផ្សេង ៗ ដូចបានពណ៌នាមកហើយប៉ុណ្ណេះជាដើម ។

ឯឧត្តរសាមណេរក៏មានសេចក្តីសោមនស្សជ្រះថ្លាស្អាតបរិសុទ្ធ កើតឡើងព្រមអាស្រ័យដោយហត្ថសម្ផស្សនៃព្រះសាស្តាចារ្យជាម្ចាស់ ដែលទ្រង់ស្ទាបលើសិរសារបស់ខ្លួនប្រាកដស្មើដោយទឹកអម្រិតដ៏ត្រជាក់ដែលបុគ្គលយកមកស្រោចពីលើដោយពិត ហើយបានញ៉ាំងបីតិនឹងបាមោជ្ជដ៏លើសលប់ឲ្យកើតឡើងក្នុងសន្តាន តាំងបានញ៉ាំងចិត្តឲ្យឡើងកាន់វិបស្ស-នាមគ្គ ដោយប្រាជ្ញាចាស់ក្លាហើយញ៉ាំងកិលេសទាំងឡាយឲ្យអស់សូន្យទៅតាមលំដាប់នៃវិបស្សនាមគ្គនោះ ព្រមទាំងបានសំរេចនូវអភិញ្ញាប្រាំមួយ និងបដិសម្ភិទាបួន ជាអង្គព្រះអរហន្តដ៏វិសេសក្នុងលោក ។

ចំណែកឯសត្វទាំងឡាយប្រមាណប្រាំបីម៉ឺនបួនពាន់ ដែលបានមកប្រជុំស្តាប់ព្រះធម៌ទេសនាក្នុងទីនោះ សឹងបានសំរេចនូវមគ្គផលសំគួរតាមឧបនិស្ស័យរៀងខ្លួនដោយពិត ។

រីឯឧត្តរសាមណេរលុះបានអភិញ្ញាទាំង ៦ ហើយ សឹងប្រកបដោយមហិទ្ធិរិទ្ធិច្រើន ក៏ហោះឡើងអំពីឈើអណ្តាតទៅស្ថិតនៅលើអាកាស

សម្ដែងបាដិហារ្យជាអស្ចារ្យផ្សេងៗ ក្នុងកាលនោះហោង ។

មហាជនទាំងឡាយសោត ក៏សឹងមានចិត្តស្ញើចស្ញប់ស្ញែងជាអស្ចារ្យពន់ពេកក្នុងកាលនោះដែរ ។ ចំណែកភិក្ខុទាំងឡាយកាលបើបានឃើញទត្តសាមណេរសម្ដែងនូវបាដិហារ្យជាអស្ចារ្យដូចនោះហើយ ក៏សួរថា ម្នាលអ្នកមានអាយុ អ្នកមានឧបនិស្ស័យធម៌ដ៏ក្លៀវក្លាដល់ម្ល៉េះ ចុះកាលដែលអ្នកសោយទុក្ខវេទនាប្រាកដដល់ខ្លួនដូចមានហើយ ហេតុអ្វីក៏អ្នកមិនប្រកបវិបស្សនាមគ្គនោះ ឲ្យសំរេចព្រះអរហត្តទៅតែម្ដងទៅ ។

ឯទត្តសាមណេរបានស្ដាប់ហើយពោលតបថា: បពិត្រលោកអ្នកដ៏មានអាយុទាំងឡាយ ទោសក្នុងសង្សារវដ្ដនិងសភាពរបស់សត្វទាំងឡាយគ្រប់តែខ្ញុំបានឃើញជាមុនដូច្នេះឯង ។

ព្រោះហេតុនោះ កាលខ្ញុំសោយនូវទុក្ខវេទនាប្រាកដដូច្នោះ ក៏ពុំអាចនឹងចំរើនវិបស្សនាមគ្គហើយត្រាស់ដឹងនូវគុណវិសេសបានឡើយ ។ លុះដល់ចំណេរមកជាខាងក្រោយ ទត្តសាមណេរនោះបានប្រកាសសម្ដែងនូវទីតាំងបុព្វចរិតរបស់ខ្លួន ដែលធ្លាប់សន្សំពីមុនមកក្នុងកណ្ដាលទីប្រជុំព្រះភិក្ខុសង្ឃ ហើយពោលនូវបទព្រះគាថាទាំងឡាយថា:

សុមេធោ ជាម សម្ពុទ្ធោ ទ្វត្តិំសវរលក្ខណោ
វិវេកកាមោ ភគវា ហិមវន្តមុបាគមិ ។

អធិប្បាយថា: ព្រះសម្មាសម្ពុទ្ធទ្រង់ព្រះនាមសុមេធ ទ្រង់មានជោគ

ដ៏យព្រះអង្គប្រកបដោយព្រះមហាបុរិសលក្ខណៈទាំង៣២ដ៏ប្រសើរ ព្រះអង្គមានព្រះទ័យប្រាថ្នានូវទីវិវេកដ៏ស្ងាត់ចាកពួក ព្រះអង្គចូលកាន់ប្រទេសហិមពាន្តជាទីរហោស្ថានដ៏សប្បាយដោយពិត ។

អជ្ឈោគហេត្វា ហិមវន្តំ អគ្គោ ការុណិកោ មុនិ
បល្លង្កំ អាភុជិត្វាន និសីទិ បុរិសុត្តមោ ។

ព្រះសុមេធសម្ពុទ្ធជាអ្នកប្រាជ្ញ ប្រកបដោយសេចក្តីករុណាដ៏ប្រសើរខ្ពង់ខ្ពស់, ជាមហាបុរសដ៏ឧត្តមជាងបុរស លុះព្រះអង្គបានយាងចុះកាន់ព្រៃហិមពាន្តហើយ ក៏ពត់ព្រះភ្នែនពែនព្រះបាទគង់នៅក្នុងទីនោះឯង ។

វិជ្ជាធរោ តទា អាសឹ អន្តលិក្ខេ ចរោ អហំ
តិសុលកណ្ណិការំ គយ្ហ គច្ឆាមិ អម្ពរេ តទា ។

កាលនោះ ខ្ញុំម្ចាស់បានអន្ទោលទៅកើតជាវិជ្ជាធរមួយប្រាណ បានហោះទៅតាមអាកាស បានកាច់ផ្កាកណ្ណិការមួយចង្កោមដែលប្រដាប់ដោយទងតែមួយមានផ្កាបី មានអាការហាក់ដូចជាដោតចង់ក្រងនឹងឈើស្រួចទាំងបី ស្រេចហើយហោះទៅតាមអាកាសក្នុងកាលនោះឯង ។

បព្វតគ្គេ យថា អគ្គិ បុណ្ណមាសេវ ចន្ទិមា
វនំ ឱភាសតេ ពុទ្ធោ សាលរាជាវ ផុល្លិតោ ។

ព្រះសុមេធសម្ពុទ្ធជាម្ចាស់ ទ្រង់ញុំាងព្រៃទាំងអស់ឲ្យភ្លឺរុងរឿងបីដូចជាអណ្តាតភ្លើង ឆេះឡើងលើកំពូលភ្នំ ពុំនោះសោត បីដូចជាព្រះចន្ទ

ឡើងនៅថ្ងៃពេញបុរមី ពុំនោះសោត បីដូចជាដើមព្រីងប្រចាំទ្វីប ដែលជាស្តេចនៃឈើទាំងឡាយ មានផ្កាដ៏រីកស្គុះស្គាយហើយមានពន្លឺរុងរឿងក្រៃលែង ។

ភារោ និក្ខមិត្វាន ពុទ្ធរំសីរ ជារេ

ឧប្បត្តិរ ឧសំកាសា ទិស្វា ចិត្តំ បសីទយឹ ។

ពន្លឺរស្មីរបស់ព្រះសម្ពុទ្ធជាម្ចាស់ បានផ្សាយពីព្រៃហិមពាន្តសុះចេញសះនោសនៅ បីដូចភ្លើងឆេះគំនរស្រមោចញដ៏ព្រៃបំបុស, លុះខ្ញុំម្ចាស់បានឃើញរស្មីនោះហើយ ក៏មានចិត្តជ្រះថ្លាពន់ពេក ។

វិចិនំ អទ្ទសំ បុប្ផំ កណ្ណិការកណ្ណិកំ ច

តីណិ បុប្ផានិ អាទាយ ពុទ្ធសេដ្ឋំ អបូជយឹ ។

ខ្ញុំម្ចាស់បានជ្រើសរើសនូវគុម្ពផ្កាកណ្ណិការ ក៏បានឃើញផ្ការីកល្អហើយបានកាច់ផ្កាទាំងឡាយបី កាន់យកទៅបូជាព្រះសម្មាសម្ពុទ្ធដ៏ប្រសើរវិសេស ក្នុងលោក ដោយសេចក្តីគោរព ។

ពុទ្ធស្ស អានុភាវេន តីណិ បុប្ផានិ មេ តទា

ឧទ្ធំ វណ្ណា អធោ បត្តា ឆាយំ កុព្វន្តិ សត្ថុនោ ។

ដោយអានុភាពនៃព្រះពុទ្ធជាម្ចាស់ ផ្កាទាំងបីរបស់ខ្ញុំ ក្នុងកាលនោះក៏មានទងត្រឡប់ទៅខាងលើ មានត្របកស្រទាប់ផ្កាសំយុងចុះមកខាង

ក្រោម ធ្វើជាម្ចប់ចាំងថ្វាយព្រះសាស្តា មានអាការដូចជាឆត្របើកចាំង
ពីលើដូច្នោះ ។

តេន កម្មេន សុកតេន ចេតនាបណិធីហិ ច ជហិត្វា មានុសំ ទេហំ តាវតឹសូបគា អហំ ។ ដោយអំពើជាកុសលរបស់ខ្ញុំនោះផង ដោយចេតនាដែលដំកល់ទុកល្អជាកំណប់បុណ្យនោះផង ខ្ញុំម្ចាស់បានលះបង់រាងកាយជារបស់មនុស្សហើយ បានអន្ទោលទៅកាន់ស្ថានតាវតឹសសួគ៌ដោយពិត ។ តត្ថ មេ សុកតំ អំពើដែលខ្ញុំបានធ្វើល្អហើយនោះ សឹងមានវិមានទិព្វដ៏ប្រាកដដោយផ្កាកណ្ណិការទាំងឡាយមានកំពស់ហុកសិបយោជន៍, ទទឹងសាមសិប-យោជន៍, មានល្វែងមួយរយគត់, មានទំហុំល្វែងទាំងអស់ប្រមាណមួយពាន់គូនសរសឹងប្រដាប់ទៅដោយទង់ជាយ ទង់ជ្រុងដ៏ច្រើនដេរដាស សំ-រេចដោយមាសសុទ្ធ ។ ឯគ្រឿងកម្រាលដំរីសេសប្រមាណមួយសែនសំរេចដោយមាសខ្លះ ដោយកែវមណីខ្លះ ដោយកែវមានពណ៌ដូចឈាមសត្វខ្លះ សំរេចដោយកែវផលិកខ្លះ ឯបល្ល័ង្កកើតឡើងតាមតែប្រាថ្នា បើប្រាថ្នាចង់បានយ៉ាងណា ក៏សំរេចយ៉ាងនោះ, ទាំងទីដំណេកដ៏មានដំរៀច្រើនសោត សឹងប្រដាប់ដោយពូកចំរៀកវិចិត្រដោយកែវផ្សេង ៗ ព្រមទាំងខ្នល់ខ្នើយក៏សំរេចដោយកែវផ្សេង ៗ ដូចគ្នាទាំងអស់, បើវេលាណាខ្ញុំធ្វើដំណើរចេញអំពីទេវវិមាន ទៅកាន់ទេវចារិក សឹងមានពួកទេវតាតាម

ហៃហាម, ផ្ទៃអាកាសខាងក្រោម មានផ្កាកណ្ណិការប្រតិស្ឋាន (ដូចជាកម្រាល) ឯខាងលើមានផ្កាត្របាំង (ដូចជាឆត្រ) មានទំហំប្រមាណមួយរយយោជន៍ជុំវិញខ្លួន ៗ ចំណែកឯក្លិនត្បូងទ្រីយ៍ប្រមាណប្រាំមួយមីនគ្រឿង សឹងប្រដាប់ដោយផ្កាកណ្ណិការ តែងតាមតោមពេមបំរើខ្ញុំ តាំងពេលព្រឹកល្ងាច តាំងយប់តាំងថ្ងៃ ដោយល្បែងច្រៀងរាំប្រគំអស់កាលជានិច្ចពុំដែលដាច់ឡើយ ហេតុតែផលានិសង្សដែលខ្ញុំបានធ្វើពុទ្ធបូជានោះ ខ្ញុំបានសោយសម្បត្តិដូចបានពណ៌នាមកយ៉ាងនេះ គឺបានជាស្តេចនៃទេវតាប្រាំរយជាតិ, បានជាស្តេចចក្រពត្រាធិរាជបីរយជាតិ បានជាស្តេចបទេសរាជ, ឯករាជ, សាមន្តរាជ ជាអសំខេយ្យ ជាតិរាប់ពុំបានឡើយ ៗ

ភវាភវេ សំសរន្តោ មហាភោគំ លភាមហំ
ភោគេ មេ ឩនតា នត្ថិ ពុទ្ធបូជាយិទំ ផលំ ៗ

កាលខ្ញុំម្ចាស់អន្ទោលទៅក្នុងភពតូចភពធំ តែងបានសោយនូវសម្បត្តិធំប្រសើរ, ខ្ញុំមិនបានខ្វះខាតភោគសម្បត្តិប្រើប្រាស់ដល់ម្តងផត អត្តីមានឡើយ, នេះជាផលដែលខ្ញុំបានធ្វើពុទ្ធបូជាដោយពិត ៗ

ទុវេ ភវេ សំសរាមិ ទេវត្តេ អថ មានុសេ
អញ្ញំ គតិ ន ជានាមិ ពុទ្ធបូជាយិទំ ផលំ ៗ

ម្យ៉ាងវិញទៀត ខ្ញុំតែងបានអន្ទោលទៅក្នុងភពតាំងពីរ គឺទេវភពនិង

មនុស្សគត ខ្ញុំពុំដែលបានស្គាល់នូវគតិដ៏ទៃដល់ម្ដងឡើយ នេះជាផលដែលខ្ញុំបានធ្វើពុទ្ធបូជា ។

ទុវេ កុលោបបជ្ជាមិ ខត្តិយេ ចាបិ ព្រាហ្មណេ
និចេ កុលេ ន ជាយាមិ ពុទ្ធបូជាយិទំ ផលំ ។

ចំណែកខាងមនុស្សគត ខ្ញុំតែងបានទៅកើតតែក្នុងត្រកូលពីរគឺត្រកូលក្សត្រិយ៍ ១ ត្រកូលព្រាហ្មណ៍មហាសាល ១ ខ្ញុំពុំដែលស្គាល់ត្រកូលថោកទាបឡើយ, នេះជាផលដែលខ្ញុំបានធ្វើពុទ្ធបូជាដោយពិត ។

ហត្ថិយានំ អស្សយានំ សិវិកា សន្ទមានិកំ
លភាមិ សព្វមេវេតំ ពុទ្ធបូជាយិទំ ផលំ ។

ខ្ញុំតែងបាននូវយានដំរី យានសេះ វរមាស និងរថមានសណ្ឋានដូចរូបគ្រុឌទាំងអស់នេះរាល់ៗ ជាតិពុំដែលខ្វះឡើយ, ទាំងអស់នេះជាផលដែលខ្ញុំបានធ្វើពុទ្ធបូជាដោយពិត ។

ទាសិគណំ ទាសគណំ នារិយោ ច អលង្កតា លភាមិ
សព្វមេវេតំ ពុទ្ធបូជាយិទំ ផលំ ។

ខ្ញុំតែងបាននូវខ្ញុំស្រីជាច្រើនផង ខ្ញុំប្រុសជាច្រើនផង នូវនារីទាំងឡាយសឹងមានដងខ្លួនប្រដាប់ដោយគ្រឿងអម្ពរផង ទាំងអស់នេះជាផលដែលខ្ញុំបានធ្វើពុទ្ធបូជាដោយពិត ។

កោសេយ្យកម្ពលិយានិ ខោមកប្បាសិកានិ ច

លភាមិ សត្យមេវេតំ ពុទ្ធបូជាយិទំ ផលំ ។

ខ្ញុំតែងបានទូវសំពត់កោសេយ្យវស្ត្រ សំពត់កម្ពលទាំងឡាយផង សំពត់ដែលត្បាញដោយសម្បកឈើ និងសំពត់កប្បាសទាំងឡាយផង ទាំងអស់នេះជាផលដែលខ្ញុំបានធ្វើពុទ្ធបូជាដោយពិត ។

ឆវត្ថំ ឆវដលំ ជាឧត្តរសកោជកំ
លភាមិ សត្យមេវេតំ ពុទ្ធបូជាយិទំ ផលំ ។

ខ្ញុំតែងបានទូវសំពត់ថ្មី ផ្លែឈើដំបូង ភោជនដ៏មានរសជាតដ៏ប្រសើរ ផ្សេងៗ ទាំងអស់នេះជាផលដែលខ្ញុំបានធ្វើពុទ្ធបូជាដោយពិត ។

នវំ ខាទ នវំ កុញ្ជ នវស្មឹ អាសនេ សយ
លភាមិ សត្យមេវេតំ ពុទ្ធបូជាយិទំ ផលំ ។

ខ្ញុំតែងបានទូវពាក្យសំដីដ៏ពីរោះថា អ្នកម្ចាស់សូមពិសាក្រយានេះ សូមបរិភោគភោជននេះ សូមសំរានលើអាសននេះ ទាំងអស់នេះជាផលដែលខ្ញុំបានធ្វើពុទ្ធបូជាដោយពិត ។

សព្វត្ថបូជិតោ ហោមិ យសោ អច្ចុគ្គតោ មម
មហាបក្ខោ សទា ហោមិ អភេជ្ជបរិសោ សទា
ញាតីនំ ឧត្តមោ ហោមិ ពុទ្ធបូជាយិទំ ផលំ ។

តួខ្ញុំនេះឯង គេតែងតែបូជាគ្រប់ប្រទេសទាំងពួង ខ្ញុំមានបរិវារយស ខ្ពង់ខ្ពស់ក្រៃលែង មានយសសក្តិដ៏សព្វ ៗ កាល មានយសបរិវារពុំដែល

បែកខ្ញែកពីគ្នាកាលវេលាទាំងពួង ខ្ញុំជាបុគ្គលប្រសើរវិសេសជាងញាតិទាំងឡាយ នេះជាផលដែលខ្ញុំបានធ្វើពុទ្ធបូជាដោយពិត ។

សីតំ ឧណ្ហំ ន ជានាមិ បរិឡាហោ ន វិជ្ជតិ
អថោ ចេតសិកំ ទុក្ខំ ហទយេ មេ ន វិជ្ជតិ
សុវណ្ណវណ្ណា ហុត្វាន សំសរាមិ ភវេ ភវេ
វេវណ្ណិយំ ន ជានាមិ ពុទ្ធបូជាយិទំ ផលំ ។

ខ្ញុំពុំដែលស្គាល់ត្រជាក់ពេក ក្តៅពេកដល់ម្តងឡើយ ទាំងសេចក្តីក្តៅក្រហាយក៏ពុំដែលកើតមានដល់ខ្ញុំដែរ ម្យ៉ាងវិញទៀតសេចក្តីលំបាកកាយលំបាកចិត្តពុំដែលកើតមានក្នុងហឫទ័យរបស់ខ្ញុំដែរ ខ្ញុំកែងអន្ទោលទៅកើតក្នុងភពទាំងពួងសឹងមានពណ៌សម្បុរល្អដូចជាពណ៌មាស ខ្ញុំពុំដែលស្គាល់ពណ៌សម្បុរផ្សេងពីមាសឡើយ នេះជាផលដែលខ្ញុំបានធ្វើពុទ្ធបូជាដោយពិត ។

ទេវលោកា ចវិត្វាន សុក្កមូលេន ចោទិតោ
ភជកបាបុរេ ជាតោ មហាសាលេសុ អឌ្ឍកេ
បញ្ចកាមគុណេ ហិត្វា បព្វជឹ អនគារិយំ
ជាតិយា សត្តវស្សាហំ អរហត្តមបាបុណឹ ។

( នៅមានត )

# មហោសថជាតក

លោក អ៊ឹម-គង់ ចម្លងពីសាស្ត្រាស្លឹករឹត

ព្រះពុទ្ធវង្ស គីម-ទូរ ពិនិត្យ

(តមក)

កាលនោះមានបុរសម្នាក់ធ្វើមុសាកាចស្រដីនូវពាក្យកុហកទូលថា ទេវ បពិត្រអើយ ! មានកាលមួយថ្ងៃ អញខ្ញុំផឹកស្រាហើយស្រេកទឹក ចូលទៅក្នុងនគរលុះដោយនូវការបន្ទិច អញខ្ញុំទៅយល់ស្រះបោក្ខរណីធំមួយ គេធ្វើប្រយោជន៍ដើម្បីតែងនឹងលេងទឹកនៃអ្នកនគរផងទាំងឡាយ សប្បាយជិះលើទូក តែងនុទមកបេះផ្កាលេងជាសប្បាយនឹងគេហោង; បុរសនោះទូលថា បពិត្រអើយ ! ស្រះនោះសោត អញខ្ញុំដឹងស្មានធ្លោស្រះនេះដូច្នេះ, មួយទីសោត អញខ្ញុំដឹងស្មានជំរៅស្រះនោះ មាននៅក្នុងនោះស្រាប់ ប្រវែង ១០០ ហត្ថមែនពិតហោង ។ កាលនោះព្រះបាទចុលនីស្ដេចស្ដាប់ពាក្យបុរសនោះហើយ មានព្រះបន្ទូលនឹងអាចារ្យកេវដ្ដព្រាហ្មណ៍ថាដូច្នេះ អាចារ្យ ហៃអាចារ្យអើយ ! រីយើងពុំអាចនឹងចាប់គេបាននឹងបង្អត់ទឹកនេះឡើយ, ស្ដេចបន្ទូលថា ចូរបានាំនូវគំនិតថ្មីទៀតហោង ។ ទើបអាចារ្យកេវដ្ដព្រាហ្មណ៍ទូលថា បពិត្រមហារាជអើយ ! ទោះយ៉ាងបីមានដូច្នោះ យើងក៏ចាប់យកឲ្យបាននឹងបង្អត់បាយនេះម្ដង នាក្នុងនគរនោះមានប៉ុន្តែស្រូវនៅឯក្រៅនោះឯងអេះ ។ ស្ដេចមានបន្ទូលថា អាចារ្យ

ហៃអាចារ្យអើយ ! ពោះយោបមានដូច្នេះ យើងធ្វើដូច្នោះហោង ៗ ទៅ·
មហោសថអ្នកដឹងពតិមាននោះដាក់ដូចនូវដំណើរនិយាយមុននោះហោង ;
ឥ មេ គោវដ្ឋ[illegible]ព្រាហ្មណោ បណ្ឌិតការី ជាជាតិតិ អនុ·
ធាការមត្តកោ កាលលំ ឧត្វា វិហា តត្ថ ភេធាបេសិ ៗ
ពោធិសត្តានំ អធិប្បាយោ ជាម ឥជ្ឈតិ ៗ ព្រះមហា-
សត្វថា នាអាចារ្យគោវដ្តព្រាហ្មណ៍នេះ រាំពុំដឹងសភាពនៃអញជាអ្នកមាន
ប្រាជ្ញាឈ្លាសប្រតិពល យល់អស់អាចរសេចក្តីកំបាំងនូវកិច្ចការសង្គ្រាម
ជ័យនៃអញសភាពជាអ្នកប្រាជ្ញានោះឡើយ ហើយពោធិសត្វអ្នកឲ្យជាន់
កក់លើភាគបន្ទាយនោះល្អហើយ ឲ្យដាំនូវពូជស្រូវលើភាគបន្ទាយនោះ ៗ
ហេតុតែព្រះបារមីនៃពោធិសត្វទឹងបានត្រាស់ប្រាជ្ញាសព្វញ្ញុតញ្ញាណនោះ
មិញ នាបរោលកលអធិប្បាយសំរិទ្ធពោធិសត្វហោង ៗ ពូជស្រូវនោះ
ក៏លាស់ឡើងតែមួយពព្រឹនោះ យល់ប្រាកដលើភាគបន្ទាយនោះហោង ៗ
រីព្រះបាទចុលនីព្រហ្មទត្តរាជ ស្តេចយល់ស្រូវព្រះមហោសថនោះហើយ
មានព្រះបន្ទូលថា អម្ភោ ខ្មាលគ្នាយើងតាំងឡាយអើយ ! នោះអ្វីយល់
មកប្រាកដទៀវលើភាគបន្ទាយនោះហ្នឹង ? ៗ បុរសដែលជាឧបនិក្ខិត្ត
ទៅមហោសថ ឮពាក្យស្តេចចុលនីនោះហើយ ទើងអណ្តាតមាត់ដូចគេ
តក់ ក៏ក្រាបទូលថា ទេវ បពិត្រអម្ចាស់ ! ដូចយើងឮមកថា ទៅមហោ·
សថបុត្រគហបតីសិរីវឌ្ឍកសេដ្ឋី គាត់យល់អនាគតកាលទឹងមកឯក្នុង

ស្អែកនឹងក្រមិនទេឡើយ អ្នកឲ្យជញ្ជូននូវស្រូវអំពីស្រុកក្រៅ យកទៅចាក់បំពេញក្នុងឃ្លាំងទាំង ១៨ នោះ ឯស្រូវសំណល់លែងនោះ ឲ្យចាក់ទុកនាខាងបន្ទាយនោះហោង, ដូចយើងឮមកថា ស្រូវនោះដោយត្រូវកំដៅថ្ងៃស្ងួត ស្រូវនៅជាពូជ នៅត្រូវភ្លៀងទុះចុះទទឹកត្រជាក់ ស្រូវនោះដុះឡើងលើក្បាលបន្ទាយនោះ; មានកាលមួយថ្ងៃ, សូម្បីអញខ្ញុំចូលទៅដោយទ្វារបន្តិច អញខ្ញុំយល់ផ្កាស្រូវខាងក្បាលបន្ទាយនោះ ហើយអញខ្ញុំយកស្រូវនោះនឹងដៃឯងមកមើល ដែលគេចាក់ចោលបង់នៅកណ្ដាលផ្លូវផ្លា; លំដាប់នោះ, ឯអ្នកផងទាំងឡាយក៏ស្រដីនឹងអញខ្ញុំថា ហៃបុរសអាយ ! ព្រះស្ដេចរកអំពើអ្វីនូវប្រការដូច្នោះ ក៏ថាដូចយើងគិតហើយ ឯព្រះស្ដេចឃ្លានបាយដឹង ? ចូរព្រះស្ដេចយកសំពត់មកនឹងវេចស្រូវនោះនាំទៅនាផ្ទះអាត្មា, ព្រះស្ដេចនឹងបើស នឹងបុកដណ្ដាំបាយ ព្រះស្ដេចយកបរិភោគហោង ៗ ស្ដេចស្ដាប់ពាក្យបុរសនោះហើយ បន្ទូលនឹងអាចារ្យកេវដ្ឋព្រាហ្មណ៍ថា អាចរិយ ហៃអាចារ្យអើយ ! ឯយើងពុំអាចចាប់បានស្ដេចវិទេហរាជដោយនូវបង្អត់បាយឡើយ ៗ អាចារ្យកេវដ្ឋព្រាហ្មណ៍ទូលថា ទេវ បពិត្រអើយ ! អញខ្ញុំមានឧបាយមួយវិញទៀត, ទូលថា បពិត្រអើយ ! តោះយោបីបើមានដូច្នោះ យើងនឹងធ្វើឲ្យមាននឹងឥតអុសផុតហោង; នាបីហៅនគរនោះ មានអុសប៉ុន្តែឯក្រៅនោះឯង ៗ ស្ដេចបន្ទូលថា ហៃអាចារ្យអើយ ! តោះយោបីមានដូច្នោះ យើងនឹងធ្វើដូច្នោះហោងណា

បពិត្រអម្ចាស់ ៗ ចៅមហោសថអ្នកប្រាជ្ញ អ្នកដឹងពតិមានជាក់ថា គេចោម
បង្កត់អុសដូច្នោះហើយ , ពោធិសត្វអ្នកឲ្យរណ្តាប់គរអុសទុកលើក្បាល
បន្ទាយនោះ យល់ប្រមាណប៉ុនភ្នំ ៗ រីមនុស្សផងទាំងឡាយ មួយអន្លើ
នឹងបុរសអាមាត្យស្តេចចុលនីច្រើនរកការស្វែងរកអុសនូវបន្ទែកពុំបានឡើយ,
រីបុរសពោធិសត្វថា ហៃម្នាលព្រះស្វែងទាំងឡាយ ព្រះស្វែងអត់អុស
ដណ្តាំបាយហូបនោះ តោះយោបឃ្លានណាស់ផង ? ចូរព្រះស្វែងមកយក
អុសនេះទៅមួយបាច់ម្នាក់ គ្រាន់ចំអិនបបរយាគូដណ្តាំបាយ ព្រះស្វែង
បរិភោគហោង, ពួកមហាជនទាំងឡាយ បោះនូវអុសដ៏ធំ ៗ ទៅឲ្យ ៗ
ឯចំណែកស្ដេចចុលនីក៏យល់ប្រាកដនាអុសលើភាគបន្ទាយនោះ ហើយ
ដណ្តឹងអាមាត្យថា នោះអ្វីអ្នកទាំងឡាយ ? ៗ អាមាត្យទូលថា ទេវ
បពិត្រអើយ ! ដូចយើងគិតហើយ, រីចៅមហោសថបុត្រគហបតីអ្នកយល់
អនាគតទៅឯក្រែកស្ដេចនឹងក្រ អ្នកឲ្យដញ្ជូនអុសព្វដ៏នាគ្រកូលចំណែក
ភាគបន្ទាយខាងឯលើមកគរទុកលើភាគបន្ទាយនោះច្រើនក្រៃ ៗ ព្រះបាទ
ចុលនី ស្តាប់ពាក្យបុរសជាទុបទិក្ខតចៅមហោសថនោះ ហើយបន្ទូលនឹង
អាចារ្យកេវដ្តព្រាហ្មណ៍ថា អាចារ្យ ហៃអាចារ្យអើយ ! យើងពុំអាច
នឹងចាប់បាន សូម្បីនឹងផ្តាច់នូវអុសនេះឡើយ, ស្ដេចបន្ទូលថា រីកលទុបាយ
អំពើនោះ ចូរអ្នកនាំមកទៀតហោង ៗ អាចារ្យកេវដ្តព្រាហ្មណ៍ទូលថា
ដូច្នេះ មហារាជ បពិត្រមហារាជអើយ ! កុំបីអម្ចាស់បារម្ភឡើយ,

មានឧបាយកលមួយវិញទៀត ។ ស្ដេចបន្ទូលថា នែអាចារ្យអើយ ! នាប៉ីហៅឧបាយកលនោះដូចម្ដេច ? អញគិតមិនយល់ក្នុងឧបាយកលព្រះស្ដេចឡើយ, អាចារ្យកេវដ្ដព្រាហ្មណ៍ទូលថា ទេវ បពិត្រមហារាជអើយ ! វយើងទាំងឡាយអម្បាលនេះ ពុំអាចនឹងចាប់បានរាជសម្បត្តិស្ដេចវិទេហ-រាជនេះបានឡើយ, អាចារ្យកេវដ្ដព្រាហ្មណ៍ទូលថា បើដូច្នេះ យើងទៅកាន់នគរយើងវិញហោង ។ អាចារ្យកេវដ្ដព្រាហ្មណ៍ទូលថា ទេវ បពិត្រអើយ ! អស់អ្នកផងទាំងឡាយគេដឹងថា ស្ដេចចុលនីព្រហ្មទត្ត គាត់នៅមួយអន្លើនូវស្ដេចមួយរយនឹងមួយ ពុំអាចនឹងចាប់ស្ដេចវិទេហរាជបាន សមយើងនឹងខ្មាសគេអសារកេតការទេហោង; អាចារ្យថា ដូចអញគិតហើយ វែងមហោសថសោតជាអ្នកប្រាជ្ញ, អញឯងសោត ក៏សឹងជាអ្នកប្រាជ្ញដែរ អញនឹងកាន់យកនូវប្រាជ្ញាអញមួយ ធ្វើកលឲ្យលើនូវប្រាជ្ញាមហោសថវិញទៀតហោង ។ ស្ដេចបន្ទូលថា នែអាចារ្យអើយ ! នាប៉ីហៅឲ្យលើសកលមួយនោះ តើដូចម្ដេច ? ។

ទេវ ធម្មយុទ្ធំ ឆាម ការស្សាមាតិ ។ គឺ ឆាមេតំ ធម្មយុទ្ធំ ឆាមាតិ ។ មហារាជ ឆ ទ្វេ សេនា យុជ្ឈិស្សន្តិ . . . . . អាចារ្យកេវដ្ដព្រាហ្មណ៍ទូលថា ទេវ បពិត្រមហារាជអើយ ! អញខ្ញុំនឹងធ្វើហៅគធម្មយុទ្ធ ។ ស្ដេចបន្ទូលថា នែអាចារ្យអើយ ! វីអែតើហៅគធម្មយុទ្ធនុះ តើដូចម្ដេច ? ។ អាចារ្យកេវដ្ដព្រាហ្មណ៍

ទូលថា មហារាជអើយ ! រីច្បាំងនឹងសេនាយោធាជាគំរប់ពីរនោះគ្មាន
ឡើយ, បពិត្រអម្ចាស់អើយ ! មួយទៀតសោត មានតែអម្ចាស់ស្ដេចគង់ទៀ
សៀមនៅក្នុង អញខ្ញុំមានប៉ុន្ដែអ្នកប្រាជ្ញនឹងអ្នកប្រាជ្ញ អាចមកនៅឋាន
មួយផងគ្នា ថាលើសនៃលែងអ្នក ២ នោះ នរអ្នកឯណា ថាចេះសំពះមុន
ហើយ ក៏អ្នកនោះហៅចាញ់មែនពិតហោង ; ឯមហោសថសោត សភាព
មិនដឹងគំនិតអាត្មាអញនេះ, រីអញជាអ្នកប្រាជ្ញ ហើយចាស់ផង រីមហោ-
សថជាអ្នកប្រាជ្ញក្មេងគាត់ ថាបើគាត់យល់អញចាស់ហើយ គាត់សំពះ
អញហោង, មួយទៀតសោត ថាបើគាត់សំពះអញហើយ នោះហៅស្ដេច
វិទេហរាជចាញ់យើងហោង; ឮដ៏កាលនោះ, . យើងផ្ចាញ់មហោសថបុត្រ
គហបតី នឹងស្ដេចវិទេហរាជនោះ, យើងទៅកាន់នគរយើង, នោះយើង
វាមិនខ្មាសគេនោះឡើយ, អាចារ្យកេវដ្ដព្រាហ្មណ៍ទូលថា អំពើដូច្នេះនេះ
ហៅគធម្មយុទ្ធ ។ សូម្បីចៅមហោសថពុំដឹងនូវអំពើកំបាំងនេះ ដូចយើង
ស្រដីនោះហោង, ពោធិសត្វអ្នកដឹងមុន ហើយអ្នករំពឹងគិតថា ទោះ
យោបី អាចារ្យកេវដ្ដព្រាហ្មណ៍ផ្ចាញ់អញបានហើយ កុំបីឲ្យអស់អ្នកផង
ហៅអញជាអ្នកប្រាជ្ញឡើយ ។ ព្រះបាទចុលនីព្រហ្មទត្តរាជបន្ទូលថា ហៃ
អាចារ្យអើយ ! រីឧបាយនេះល្អហើយ, យើងធ្វើធម្មយុទ្ធនាស្រុកឯងហោង
ឮដ៏នាអ្នកប្រាជ្ញទាំងពីរ ទោះយោបីចាញ់ ទោះយោបីឈ្នះក្ដី សឹងស្ដែង
ដោយនូវធម៌មែនពិតហោង, នរអ្នកឯណាពុំធ្វើនូវធម្មយុទ្ធ, រីអ្នកនោះ

ហៅតាញ់ហោង, គិតដូច្នោះហើយ ឲ្យសរសេរសំបុត្រប្រើឲ្យជូនទៅស្តេចវិទេហរាជ ដោយនូវការបន្ទិច ។ ស្តេចវិទេហរាជ ស្តាប់ពតិមាននោះហើយ, ស្តេចឲ្យហៅទៅមហោសថមកសំដែងប្រាប់នូវអាថ៌នោះសព្វគ្រប់ ។ រីមហោសថអ្នកដឹងនូវអាថ៌នោះហើយទូលថា ទេវ បពិត្រមហារាជអើយ ! សាធុ ពីពេះពេក, នាព្រឹកស្អែក អម្ចាស់ឲ្យរណ្តាប់មណ្ឌលធម្មយុទ្ធ ដោយការខាងលិចស្រេចហើយ អម្ចាស់ប្រើពតិមានទៅឲ្យលោកមកនាមណ្ឌលធម្មយុទ្ធនោះហោង ។ ព្រះមហាក្សត្រ ស្តាប់នូវពាក្យពោធិសត្វហើយ ស្តេចឲ្យសំបុត្រទៅរាជទូតដែលនាំមកនោះត្រឡប់ទៅវិញហោង ។ លុះព្រឹកឡើងទៅមហោសថថា នាអញនឹងផ្ចាញ់អាចារ្យកេវដ្តព្រាហ្មណ៍នេះ នឹងចំណោះប្រាជ្ញានៃអញហោង, ស្តេចឲ្យរណ្តាប់នូវមណ្ឌលធម្មយុទ្ធ ដោយការឯលិចស្រេច ។ ស្តេចវិទេហរាជបន្ទូលថា អ្នកផងទាំងឡាយ ជាបុរសបច្ចត្ថិកនៃស្តេចមួយរយនឹងមួយ គេនឹងធ្វើម្តេច ៗ ក្តី នរណានឹងដឹងឡើយ ប្រយោជន៍អញឲ្យគេក្រាញ-ចាលចាមហោសថនោះហោង ។ លំដាប់នោះអាចារ្យកេវដ្តព្រាហ្មណ៍មកនាមណ្ឌលធម្មយុទ្ធ នូវបរិវារផងទាំងឡាយ នូវស្តេចមួយរយនឹងមួយ ហើយអាចារ្យកេវដ្តព្រាហ្មណ៍ឯង គេរមិលមើលទៅទិសខាងឯកើតបិតនៅហោង ។

ក្នុងកាលនោះ, ពោធិសត្វសោត អ្នកស្រង់នូវទឹកអប់ ត្រឡប់នីទៅ

នូវគន្ធពិដោរអំពីព្រឹក ហើយបរិភោគនូវភោជនាហារមានឱជារសនោះពិ-
សាស្រេចហើយ អ្នកស្លៀកនូវសំពត់កាសិកពស្ត្រ, ដ៏មានដំឡៃមួយ-
សែនដំឡឹង, ប្រដាប់ដោយគ្រឿងអលង្ការទាំងពួង ទៅដល់ទ្វាររាជវាំង
ស្តេច ព្រមទាំងបរិវារច្រើន ឈរបិតនៅហើយ; ព្រះមហាក្សត្រស្តេច
បន្ទូលថា នែហ៎កូនសំឡាញ់នៃអាពុក ចូរបាមកឯអាយហោង, រីពោធិ-
សត្វអ្នកក៏ចូលទៅហើយ អ្នកថ្វាយបង្គំស្តេចបិតនៅឯដ៏ឋានមួយ, ព្រះ-
មហាក្សត្របន្ទូលដណ្តឹងថា តាត មហោសថ នែបាមហោសថ
អើយ ! នាគជម្ពូទូនោះ មានប្រការម្តេចខ្លះ ៗ ? មួយនិសោត ពេលា
បានហើយហ៎ ? ទៅមហោសថទូលថា ទេវ បពិត្រអើយ ! ពេលានា
អញខ្ញុំនឹងទៅនាគជម្ពូទូមណ្ឌលនោះបានហើយហោង; ស្តេចបន្ទូលថា
ដូច្នេះគួរហោង, អញនឹងធ្វើម្តេច ? ពោធិសត្វទូលថា បពិត្រអម្ចាស់
អើយ មានតែព្រះអង្គស្តេចគង់ក្នុងព្រះដំណាក់ឲ្យស្រៀមហោង; ទើប
ពោធិសត្វទូលថា ទេវ បពិត្រអើយ ! អញខ្ញុំនេះ គួរឲ្យបានមណីរ័តន៍
ពិចិត្រមានថ្នាក់ប្រាំបី អញខ្ញុំមានចំណង់នឹងចង់ល្បួងអាចារ្យកេវដ្ដ-
ព្រាហ្មណ៍នឹងមណីរ័តន៍នេះ ។ ព្រះមហាក្សត្រស្តាប់ហើយបន្ទូលថា តាត
នែបាមហោសថអើយ ! បាទៅហើយ ចូរបារវៀសវៃមកហោង ទើប
ស្តេចឲ្យអាមាត្យយកកែវមណីរ័តន៍ថ្នាក់ប្រាំបីមកឲ្យ ។ ពោធិសត្វនោះ
អ្នកកាន់យកមណីរ័តន៍នោះហើយ អ្នកសំពះស្តេចលាចុះឡើងទៅជិះលើ

រថទះប្រសើរ ទឹមនូវសេះសបរិសុទ្ធ ប្រដាប់នូវគ្រឿងមាសមានដំឡៃនោះ មួយសែនដំឡឹងហើយនឹងយានដែលកើតថ្ងៃមួយព្រមនឹងពោធិសត្វទាំង មួយពាន់នោះមកជាបរិវារ នាពេលាព្រឹកហូបបាយនោះ ទៅដល់ទៀប ទ្វារបន្ទាយនោះហោង ៗ សូម្បីអាចារ្យកេវដ្ដព្រាហ្មណ៍រំពឹងគិតថា ឥឡូវ នេះ ចៅមហោសថ សមនឹងមកហើយហោង, អាចារ្យកេវដ្ដព្រាហ្មណ៍ តែងគយគន់រមិលមើលចៅមហោសថ នាទីងមកបិតនៅ ៗ រីឯកនៃអាចារ្យ កេវដ្ដព្រាហ្មណ៍ ដូចគេដកឡើង លូតតួចហើយវែង ៗ ហេតុនោះឯង ដោយត្រូវកំដៅព្រះអាទិត្យដិត ដំហូរចេញនូវញើសស្រោកសំណាក់ បិតនៅហោង ៗ សូម្បីពោធិសត្វសោត អ្នកលីលាទៅនឹងបរិវារច្រើន ដំឮស័ព្ទសូរគគ្រុកគគឹក ដូចស័ព្ទរលកមហាសមុទ្ទ, ព្រះមហាក្សត្រក៏ភ្ញាក់ ភិតភ្ញាចអំណាចនរនាទនៃកេសរពជសីហ៍ ប្រាសលែងម្រឹគ នឹងភ្ញាក់ព្រឺ សម្បុរឡើង ដល់ហើយឲ្យបើកទ្វារគ្រាលចូលទៅក្នុងព្រះនគរ ដំមាន ដំណើរនោះនរនាទល្អ ដូចដំណើរពជសីហ៍ចេញអំពីគុហាមាស ប្រាស លែងម្រឹគាគណនិករ ៗ ឯអស់ស្ដេចមួយរយនឹងមួយ សឹងតែយល់លំអ ស្រីសួស្ដីរូបនៃពោធិសត្វហើយ រីអស់ស្ដេចទាំងអម្បាលនោះ សឹងស្រ-ដីថា ដូចយើងឮរៀងមកនេះឯង ចៅមហោសថជាកូនសិរីវឌ្ឍកសេដ្ឋី ឈ្មោះចៅមហោសថបណ្ឌិតអ្នកប្រាជ្ញ មានប្រាជ្ញាស្រួចស្រេចផ្ដាច់អស់ ស្ដេចទាំងសកលជម្ពូទ្វីប ឥតអ្នកណាមួយស្មើបាន, អនុត្តរយោ ឥត

អ្នកជាគំរប់ពីរឡើយ, រីឯស់ស្តេចទាំងឡាយ សឹងបង្កើតនូវពាក្យសំដែងសរសើរនោះមួយសែនដង ៗ សោភិ ខោ គឺដោយនូវពិត សូម្បីចៅមហោសថនោះ ប្រាកដដូចជាព្រះឥន្ទ្រាធិរាជ អាចមានពពួកទេវតាផងទាំងឡាយសម្រាប់ជាបរិវារគ្រាកាលមានប្រាជ្ញាឥតអ្នកស្មើ ល្អរុងរឿងពណ្ណរាយនូវឥស្សរសម្បត្តិបិតនៅ មានដៃកាន់មណីរ័ត្ន៍ទៅផ្ដោះត្រង់អាចារ្យកេវដ្តព្រាហ្មណ៍, អហោសិ ស្រេចមានហោង ៗ អាចារ្យកេវដ្តព្រាហ្មណ៍យល់នូវពោធិសត្វហើយ ពុំអាចដើម្បីនឹងទប់អាត្មាភាពបានឡើយ ហើយធ្វើ បច្ចុគ្គមនំ ទៅទទួលក៏ស្រដីនូវពាក្យថាដូច្នេះ បណ្ឌិត មហោសថ ហៃចៅមហោសថអើយ ! រាយើងសឹងជាអ្នកប្រាជ្ញទាំង ២, យើងមកនៅនាឋាននេះ ទឹងចៅលុះក៏នាកាលអម្បាលនោះហើយ សូម្បីមាត្រាគ្រឿងបណ្ណាការ ចៅពុំគប្បីឲ្យដូនយើង, ហេតុអ្វីមកប្រការដូច្នោះហ៎ះ ? ៗ គ្រានោះពោធិសត្វឆ្លើយនឹងអាចារ្យកេវដ្តព្រាហ្មណ៍ថា ចូរព្រះស្តែងរមិលមើលនូវគ្រឿងបណ្ណាការដ៏គួរនឹងចៅនាព្រាហ្មណ៍ជាអ្នកប្រាជ្ញ, ពោធិសត្វថា ដូច្នេះ ឥឡូវនេះ អញយកមណីរ័ត្ន៍នេះគួរហោង, ព្រះស្តែងចូរយកមណីរ័ត្ន៍នេះ, មណីរ័ត្ន៍នេះ ជាលាភ នាបីហៅសភាពបង្គួរដូច្នេះនោះគ្មានឡើយ ៗ លំដាប់នោះ អាចារ្យកេវដ្តព្រាហ្មណ៍ យល់មណីរ័ត្ន៍រុងរឿងពណ្ណរាយនូវរស្មីនាដៃពោធិសត្វហើយ អាចារ្យកេវដ្តព្រាហ្មណ៍គិតថា រីមណីរ័ត្ន៍នេះលាមក នឹងចង់ឲ្យអញ

មែន ។ អាចារ្យកេវដ្តព្រាហ្មណ៍ថា ទោះយោបីដូច្នេះ អញនឹងសណ្ឋក ដៃទៅ ប្រើឲ្យមកអញហោង ។

ពោធិសត្វថា ហៃអាចារ្យអើយ! ចូរអ្នកយកហោង, អញនឹងបោះឲ្យអ្នក ថាដូច្នោះហើយ អ្នកទំលាក់ចុះលើចុងអង្គុលីដៃអាចារ្យកេវដ្ត-ព្រាហ្មណ៍ដែលសណ្ឋកមកនោះ ។ លំដាប់នោះ មណីរ័តន៍នោះ ហេតុតែធ្ងន់ពុំអាចនឹងបិតនៅលើម្រាមដៃអាចារ្យកេវដ្តព្រាហ្មណ៍ ។ មណីរ័តន៍នោះក៏រមៀលធ្លាក់ចុះទៅទៀបព្រះបាទពោធិសត្វក្សូ ។ អាចារ្យកេវដ្តព្រាហ្មណ៍ហេតុតែលោភ ហើយគិតថា អញនឹងយកមណីរ័តន៍នេះ គិតដូច្នេះហើយក៏ឱនក្បាលចុះរើសទៀបជើងពោធិសត្វហោង ។ លំដាប់នោះ, ព្រះពោធិ-សត្វ ក៏ចាប់ច្របាច់កអាចារ្យកេវដ្តព្រាហ្មណ៍នឹងដៃជាប់ មិនឲ្យដោះឡើងបាន, ដៃមួយកាន់ក្រចី ហើយពោធិសត្វថា ហៃអាចារ្យអើយ ! ចូរអ្នកដោះឡើង អញនេះជាក្មេងក្តាត់ហោង, អញនេះគ្រាន់តែជាចៅនៃអ្នកប៉ុណ្ណោះ, ពោធិសត្វអ្នកថា ព្រះស្ដេចកុំឱនចុះសំពះអញឡើយ, ពោធិ-សត្វអ្នកថាអម្បាលនោះហើយ អ្នកឈ្ងើមុខអាចារ្យកេវដ្តព្រាហ្មណ៍ផ្តួលដល់ដី ឈ្ងើទៅវិញទៅមក, អ្នកធ្វើឲ្យចេញឈាមពេញទាំងថ្ពាស, ពោ-ធិសត្វថា ព្រះស្ដេចជាអ្នកខ្វាអន្ធពាល ឲ្យបានទ្រព្យចំអិនទ្រព្យសំកប់នៃអញ, អ្នកកាន់កអាចារ្យកេវដ្តព្រាហ្មណ៍នោះខ្ទប់ ហើយណក់ធ្លាក់ទៅមានចម្ងាយមួយយោជន៍ ឧបដ្ឋាយបលាយិ ដោះឡើងហើយរត់ទៅ ។

រីឯមនុស្សទាំងឡាយជាបរិវារនៃពោធិសត្វ ក៏រើសយកមណីរ័តន៍នោះមកវិញហោង ។ ពោធិសត្តស្ស បន ឧដ្ឋេថ ឧដ្ឋេថ មា មំ វន្ទថាតិ វចីឃោសោ សកលបរិសំ ធាវេត្វា អជ្ឈាសិ ។ ពោធិសត្វអ្នកថា ហៃអាចារ្យអើយ ! ចូរដោះឡើង ចូរដោះឡើង កុំសំពះអញនេះជាអ្នកប្រាជ្ញក្មេង, ម្តេចឡើយអាចារ្យឯងជាចាស់ស្កូវព្រោង ក៏មកសំពះឯអញវិញ ស័ព្ទពោធិសត្វនោះ ក៏ឮខ្ទរទៅដល់អស់បុរសជាបរិវារដែលឋិតនៅឯក្រោយ ។ គេថាដូច្នេះ ឥឡូវនេះ អ្នកអាចារ្យកេវដ្តព្រាហ្មណ៍យើងមិញ គាត់ចាញ់ចុះដល់សំពះបាទជើងព្រះមហោសថហើយ តើយើងនឹងធ្វើម្តេចទៅអេះ ? អស់បរិវារស្តេចមួយរយនឹងមួយសឹងធ្វើបញ្ចេញនូវស័ព្ទនោះព្រមជាមួយផងឡើងហោង ។ សូម្បីអស់ស្តេចទាំងអម្បាលនោះ ទុកស្តេចចុលនីព្រហ្មទត្តរាជជាចាញ់ ដ្បិតយល់អាចារ្យកេវដ្តព្រាហ្មណ៍ ទនចុះសំពះបាទជើងព្រះមហាសត្វហើយ ។ គេថា ឥឡូវនេះ អាចារ្យកេវដ្តព្រាហ្មណ៍ជាអ្នកប្រាជ្ញនៃយើងនេះ គាត់សំពះទៅមហោសថអ្នកប្រាជ្ញហើយ, អស់ស្តេចទាំងឡាយថា ឥឡូវនេះ យើងចាញ់គេហើយហោង, ព្រះមហោសថសមគាត់នឹងមិនទុកជីវិតយើងឡើយ, អស់ស្តេចទាំងឡាយ ខ្លះឡើងជិះសេះអាត្មាទៃ ៗ ត្រោះមុខទៅកាន់ឧត្តរបញ្ចាលនគរនោះហោង ។

( នៅមានត )

# ប្រវត្តិព្រះឥន្ទ នឹង សង្គ្រាមអសុរ

លោក ជល-ធិត នៅពុទ្ធសាសនបណ្ឌិត្យ

និពន្ធជាពាក្យកាព្យតាមសេចក្ដីក្នុងគម្ពីរសារត្ថទីបនី

## វិនយដីកា សមន្តប្បាសាទិកាវណ្ណនា

( តមក )

ប្រវត្តិព្រះឥន្ទ ទេវរាជ
ដែលភិតអំណាច នៅសួគ៌ា
នឹងអសុរយុទ្ធ ដោយយោធា
គូរមិត្រភាល់គ្នា កំណត់ដឹង

ឲ្យគេសេពសោយដោយអាណិត គេមិនពេញចិត្តត្រេកត្រអាល
បែរជាកធ្វើអំពើពាល បណ្ដាលគម្រោលពាលយើងអស់ៗ
មករុំយ ! ពួកយើងកុំរួញនៅ បបួលគ្នាទៅរកកិត្តិយស
សម្លាប់កាប់គ្នាក់ឲ្យអស់ កុំឲ្យរារស់ខ្ពស់សាគល ៗ
ពេលនោះព្រះបាទវេបចិត្តិ បង្ខិតមិត្រក្រុមបង្គំពល
គោះគងខ្ចូងស្គរខ្ទរមណ្ឌល បេលរៀបទ័ពជាប់សង្កាត់ ៗ
នឹកឃើញរឿងដើមដង្ហើមធំ ស្ទើរយំអួលឯកបែកប្រមាត់
ប្រជុំយោធាជាសង្កាត់ សម្បើមពេកក្ដាត់ញ័រប្រឹថពី ៗ

ខ្លះលើកដំបងគងលើស្មា    ខ្លះកងសង្ហាហោះវក់វី
ខ្លះកងសង្គិះផិះសេះញី    ខ្លះលីប៉ូវប៉ៅមើលទៅនាយ ៗ
ខ្លះលើកក្រឆាវកាន់ដាវផ្គាក់    ខ្លះទាញកន្ត្រាក់ធ្នូមកស្ពាយ
ខ្លះខ្វចល្វចមើលព្រើលនាយអាយ    បែរកាយនេបនិត្យផិតស្រើស្រើ ៗ
ខ្លះដកព្រួញចេញពីបំពង់    ផ្គងធ្នូតម្រង់ផ្ចង់ស្មារតី
សាកមើលបន្ទោះដាក់សរបី    ក្រែងពេលក្រក្រើឡដៃចាំ ៗ
ខ្លះលើកព្រះខ័នកាន់សំឡឹង    សំឡក់ឈរធ្មឹងប្រឹងទន្ទ្រាំ
នេត្រប្រាលក្រហមមុខទ្រមជាំ    ក្រឹតធ្មេញញេញញខាំមាំពេកក្រៃ ៗ
ខ្លះលើកដំបងផ្គងដាក់លី    គ្រវាត់គ្រវីខ្វាយព្រឹក្សព្រៃ
ខ្លះឈរកាន់ជ្រែងលំពែងជ័យ    ខ្លះឈរក្តាប់ដៃស្តីក្អេងក្អាង ៗ
ពួកខ្លះទាញសេះដើរតម្រៀប    ឈរត្រៀបទៀបផ្លូវនៅសងខាង
ខ្លះជិះដំរីចងរយាង    រូបរាងក្រអឹតស្អើតក្រអាញ ៗ
កកកើនច្រើនណាស់ដាសពិកពត    សុទ្ធសឹងតែទ័ពយ៉ាំងស្ទាត់ស្ទាញ
ចំណាប់ស្នាដៃក្រៃជំនាញ    ប៉ិនផ្ចាញស្ទួគិតនាក្រៃត្រឹង្យ ៗ
ដៃកាន់អាវុធយុទ្ធកណ្ឌា    រាប់មុឺនកើនពាន់លាន់ទ្រហឹង
កាន់ខែលមាសពេជ្រស្រេចឈរធ្មឹង    សំឡឹងទម្លុះឆ្ពោះសត្រូវ ៗ
លុះរៀបពលផងកងពន្ទឹក    ក្បួនសឹកបាក់ចែកគ្រប់ផ្នែកផ្លូវ
ក៏លើកព្យុហៈយាត្រាទៅ    តម្រូវផ្លូវបែរតប្រយុទ្ធ ៗ

កកកុញរុញឡើងដើងប្រទាក់ ប្រទើសគ្នាបាក់បោកអាវុធ
ប្របៀតជ្រៀតគ្នាក្លាឥតស្កុត ហែកទឹកសមុទ្រផុតដើបប្រាណ ។
ប្រិចប្រិចលេចចេញដូចមេភ្លៀង ដែលគៀងហើរឡើងដំបូកឋាន
កកកើនច្រើនជ្រួសហួសប្រមាណ ក្លាហានគ្មានឈប់គ្រប់ពួកក្រុម ។
រីឯពួកនាគកាគរំងរំខ្ញ ដឹងពិតនិត្យនៅហៅគ្នាជុំ
ប្រុងខ្លួនពួនកាយកាយជាក្រុម ចង្កូមធំធំជាអាវុធ ។
លុះឃើញអសុរក្បួលមកដល់ ក៏ស្ទុះរបល់តាប់ប្រយុទ្ធ
ពួកខ្លះទើបងើបពីសមុទ្រ នាគផុតដោយពិសប៉ុសសាហាវ ។
អសុរបរទ័ពសង្គ្រុបរី នាគចាំងឈ្លោលញ៉ាំក្រួសក៉ាវ
ព្រួសខាំចឹកក្រួតជាប់ខោអាវ អសុរក៏ពៅកាប់សាច់សង ។
រីកសន្ធឹកទឹកបែកបែង បែកចេញជាផ្សែងលាន់គឹកកង
ភ្លៀងផ្គររន្ទះពាសរំពង ពលផងមុះមុតប្រយុទ្ធទាក់ ។
បាញ់កាប់ចាប់វាយប្រញាយញឹក តគ្រឹកតគ្រែងជ្រែងទាត់ធាក់
ប៉ុន្តែគ្រប់គ្នាស្ងប់ម្នាក់ មិនមានគ្រោះថ្នាក់បាក់បែកសោះ ។
គឺគ្មានអ្នកណាត្រូវស្បែកដាច់ ឬមុតធ្លុះសាច់ដាច់ស្បែកពោះ
ឬចេញលោហិតឲ្យហ្មងមោះ គ្មានបន្តិចសោះគ្រប់ៗប្រាណ ។
គ្រាន់តែតក់ស្លុតរន្ធត់ចិត្ត ចង់ដាយចង់មឹតបករកឋាន
ដូចជាកូនក្មេងលេងកំសាន្ត ឥតមានហ្មងមោះគ្រោះថ្នាក់ឡើយ ។

នាគរាប់កោដិលានគ្មានតក់ស្លុត    ប្រយុទ្ធទប់ទល់មណ្ឌលត្រើយះ
វាយប្រានសត្រូវឡេរវើយ    ឡេរស្បើយរត់បករកកន្លែង ។
ឯពួកអសុរកំរុលខ្លាំង    ធ្វើយុទ្ធប្រឆាំងច្បាំងឥតក្រែង
គ្រវៃដំាងពីរខំប្រឹងប្រែង    សំដែងឫទ្ធិរៀងៗខ្លួន ។
តែពួកអសុរពលជោគជ័យ    ច្បាំងបានថ្លៃដៃយ៉ាងមាំមួន
សំពងពួកនាគឡើកខ្លួន    ប្រាសព្រាត់រត់ពួនអស់ពីផ្លូវ ។
ហើយនាំគ្នាគ្រងគម្រង់ចំ    ស្ទុះស្រឡើងគ្នាំពុំអាស្រូវ
ច្រើនពេកមេឃដិតងងឹតផ្លូវ    តម្រូវតម្រង់គ្រង់សួគ៌ា ។
លុះឆ្លងពីនាគឆ្ងាកទៅផុត    ស្រាប់តែពើបយុទ្ធនឹងគ្រុឌា
ប្រឹងចាត់ស្កាត់ផ្លូវនៅត្រៀបត្រា    ច្រើនឥតគណនាគ្នាណែនណាន់ ។
ក្រញៅក្រញាំជើងក្របួច    ចំពុះមុតស្រួចដូចព្រះខ័ន
ជើងគាបស្ទាបកាងកងរួសកន់    ពប់ពាន់ពប់ម៉ឺនកើនកោដិលាន ។
លោះហើរប្រឹងប្រៀបរៀបក្បួនសឹក    គគ្រឹកគគ្រែងវែងក្លាហាន
លុះឃើញអសុរត្បូលដល់ហាន    គ្រប់ប្រាណចាប់បើកធាកប្រយុទ្ធ ។
ស្ទុះហោះផ្ទោះចឹកជីកស្កាត់ណាស់    ហើរប្រាសអមិត្រឥតមានស្លុត
អសុរកំសបវាយតបគ្រុឌ    ប្រយុទ្ធដណ្ដើមសម្បើមក្រៃ ។
ហោះផ្ទាំងគោងជើងឡើងជះជាប់    ចុករុកចាក់កាប់បង់ឡក្បៀយ
ខ្ទះបាញ់ធ្នូសរខ្ទរពេញព្រៃ    វិស័យដូចផុសព្យុះសង្ស្រាក ។

មហាមេឃងងឹតបិទបាំងអស់ ដោយការចំបាប់កាប់ចាក់គ្នា
រលំព្រឹក្សព្រៃផ្កាក្រឡា ពសុធាខ្ទរខ្ទរញ័រទទាក់ ។
អសុររុលបុករុកខ្ចាយ ទម្លុះធ្លុះធ្លាយរាយខ្ទាក់
ពួកគ្រុឌពប់មុនកើនកោងធ្លាក់ ចាញ់បាក់បបោចអំណាចឫទ្ធិ ។
លុះឃើញពួកគ្រុឌរត់ដោះដៃ ចូលព្រៃលខ្លួនពួនភ័យភឹត
ស្រេចទើបព្រះបាទវេបចិត្ត បង្គិតមិត្រខ្លួនផ្ទួនទៅទៀត ។
ឲ្យរត់ទៅមុខសម្រុកចូល ពលផងក៏មូលចូលជ្រែកជ្រៀត
តាមផ្លូវទៅក្ដុំចង្អៀត ជល់បៀតតំបន់កុម្ភណ្ឌសឹក ។
ស្រាប់តែពើបពក់អ្នកកុម្ភណ្ឌ ច្រើនមុនច្រើនពាន់ឈរដូចស្ដឹក
កាន់ដាវលំពែងសំដែងឫក ស្ទាត់ថ្មិកសឹកសាមសង្គ្រាមជ័យ ។
អសុរឃើញហោះកំពុះពារ ឥតឲ្យយូរយោរការតដៃ
សំពងកុម្ភណ្ឌជាន់បែកព្រៃ វិស័យដូចខ្លាហាមាំក្ដាន់ ។
កុម្ភណ្ឌក៏គ្រាន់គ្មានវេត គ្មានថយគ្មានរត់ស្ទុះរសេកន់
ចាក់សេបតបសាប់កាប់ជន្ទាន់ សន្ធឹកខ្ទរឈាន់ដូចរន្ទះ ។
អាខ្លះដៃដែកគ្រាប់ភ្លុកប្រាក់ ក្បាលដូចកងចក្រវិលពង្រះ
ចេញភ្លើងឡើងភ្លឺស្មើរន្ទះ ពោលជះទៅចំក្រុមសត្រូវ ។
អាខ្លះចុងសក់ដូចលំពែង គ្រវែងគេសាការពារផ្លូវ
អាខ្លះភ្លុកលៀនមុខក្រញូវ ឆាកត្រូវដបស្រោស្រេកផឹក ។

មានកងស្បែកស្ពាន់ច្រើនពាន់នាក់ ញ័រញាក់លាក់ខ្លួនតាមក្បួនសឹក
ក៏ស្ទុះមកកាប់ស័ត្វស្ទឹក គគ្រឹកគគ្រេងរង្វើងគ្នា ៗ
ឯពួកព្រះបាទវេបចិត្តិ គ្មានគិតគិតក្រោយថយរួញ
សំពងកុម្ភណ្ឌទន់ទេព្ដា កុម្ភណ្ឌរុញគ្នារត់ពារព្រៃ ៗ
រត់ពារប្រពន្ធជាន់កូនតូច រត់ផុចចូលផ្លូវនៅតែភ័យ
អសុរដេញពាន់ផ្គូលជាន់ថ្ងៃ កុម្ភណ្ឌទន់ដៃផ្ទាស្រប៉ាប់ ៗ
អាខ្លះភ័យហួសជ្រួសធ្លាក់ជ្រោះ អាខ្លះគេចហោះផ្លោះពាបពាប
ភ័យក្រែងអសុររុលធ្វើបាប កម្លាំងថយជាប់ធ្លាក់មកដី ៗ
បែកខ្ចែកប្រាស់ព្រាត់រត់ព្រោងព្រាត ចូលព្រៃញាតស្បាតលែងគប់ស្ដី
វន្ទក់ស្ទុតស្ទាំងកាំងស្មារតី ខ្លាចបុណ្យបារមីបច្ចាមិត្រ ៗ
លុះបានឱកាសឈ្នះកុម្ភណ្ឌ អសុរច្រើនពាន់ក៏បង្គិត
បង្ខំទ័ពខ្លួនផ្លូនទៅជិត គ្មានគិតគិតភ័យលែងតែស្ទៀត ៗ
ឡើងស្រលើកខ្នំខំសម្រុក ចូលបុកបើកផ្លូវតទៅទៀត
មាតាំភកាន់ណាន់ចង្អៀត ចូលជ្រៀតបៀតដល់យល់សួតាំ ៗ
ខ្លះហោះខ្លះហើរខ្លះដើរដី ខ្លះជិះដំរីជិះសេះលា
ខ្លះវេចសំពាយស្ពាយដបស្រា ខ្លះស្រែកឡូឡាខ្លាវមណ្ឌល ៗ
កំពុងតែលើកបើកសមយុទ្ធ ចេញផុតកុម្ភណ្ឌទន់ឥទ្ធិពល
ស្រាប់តែថែរនេត្រក្លែតទៅយល់ ពួកពលយក្សយន់ពង្សក្លាហាន ៗ

ឈរកាន់លំពែងដ្រែងជើងតាំ    មាឌមាំសមសួនចំនួនលាន
កោដិសែនមុនកាន់ដាវទប់ប្រាណ    ឥតមានញញើតដើតភ័យសោះ។
នៅរបៀបរង់បង្អង់ស្កាត់    ការពារសង្កាត់ទ័ពបួននោះ
ខ្លះយាមក្នុងដីខ្លះលៃហោះ    ហើរផ្លោះជ្រោះជ្រៅកំផ្ទូវថ្កាន ៗ
ឈរជ្រៀតបៀតប្រកកកស្រពាប់    សន្ធឹកសន្ធាប់កប់មិនបាន
ខ្លះមាឌធំខ្ពស់ហួសប្រមាណ    ក្លាហានប្រឹងលោតរបូតក្បៀន ៗ
ខ្លះកងធំណាត់មាត់សំញើញ    កញ្ជើញរើកស្បែះស្ពាយផុទិន
ក្លាត់ជួលក្រឡប់ផ្កាប់ក្រឡៀន    សង្កិនស្រមោចហ៊ានហោចអស់ ៗ
ខ្លះបេញចង្កូមពេមស្រម៉ូវ    មុខខ្មីក្រញូវមិនសូវស្រស់
ដេញតាប់ខ្លាញីស៊ីតាំងរស់    ខ្លះតាប់បានពស់មកព័ទ្ធខ្លួន ៗ
ក្បាលដែកក្ដែកប្រាក់សក់ទង់ដែង    ពេមដុះវែងវែងល្មមចូលពួន
ខ្លះមានសាច់ដុំធំមាំមួន    ក្រអួនសម្បែកស្រែកក្រអៅ ៗ
ខ្លះកាចផ្ទុសល្អចំណាប់    ខ្លះតាប់តាញព្រួញរួញខ្លួននៅ
ខ្លះកាន់ដំបងផ្គងប៉ូវថៅ    ខ្លះបញ្ចេញភ្លៅសុទ្ធតែយ័ន្ត ៗ
ឯពួកអសុរពលអសោច៍    ច្រើនដូចស្រមោចគ្មានបង្អង់
ឃើញយក្សបោល់ចូលដូចគ្រាប់មន្ត    ប្រឹងគន់កែកាប់សព្វប្រញាយ ៗ
បរសេះដំរីដើរញាក់ញ័រ    ខ្ទារខ្ទ័រគ្រឹកសន្ធឹកខ្ចាយ
ចូលបុករុកទាក់ឥតលាក់កាយ    ខ្លះប្រាយមិតបករកគ្នា ៗ

យក្សក៏ប្រឹងកាច់សាប់សំពង ខ្លះរេងខ្លះរុលត្បុលឥតគា
ខ្លះបាញ់ផ្លូងផាំងខ្ទាំងមហិមា ពសុធាកក្រើករំពើកក្រៃ ។
ស្មើរនឹងក្រឡាប់ផ្កាប់រលំ រលើងអស់គុម្ពក្រុមព្រឹក្សព្រៃ
ទ័ពទាំងសងខាងពឹតអស់ដៃ ដណ្ដើមយកជ័យរក្សាទី ។
ពួកយក្សកំណាចកាចដូចភ្លើង សុទ្ធតែជាជើងពួកអាន់ជ្រី
ប្រឹងពឹតចំបាច់កាប់វក់វី ប្រឹថពីរំដួលច្រួលច្របល់ ។
ប៉ុន្តែដោយគុណបុណ្យឥទ្ធិរិទ្ធិ នៃវេបចិត្តិអង្គិចមពល
យក្សខ្ទាំងពួកបែរស្រងល់ មិនអាចទប់ទល់តប្រឆាំង ។
អស់ឫទ្ធិឥតបុណ្យគុណវិបត្តិ ពលយក្សខ្ចាយខ្ចាត់ទទន់កម្លាំង
អសុរបានចិត្តរឹតតែខ្លាំង យក្សតាំងរាំងកាយរាយមិនបែក ។
ដោះខ្លួនរប៉ុយដូចរុយហើរ ខ្លះទេរឈើព្រៃភ័យហួសពេក
ខ្លះត្រូវអសុររុលចំក្អែក ខ្លះដេកស្រពាងខាងជើងភ្នំ ។
បក្សពួកអសុរជ្រុលជើងដេញ ដួលផ្ងើមាត់ស្ញេញឈឺចង់យំ
យក្សខ្លះភ័យពេកដេកសម្ងំ ទឹកព្រួយបារម្ភក្រែងគេតាម ។
លុះពួកអសុរចូលតដៃ ដណ្ដើមយកជ័យពីយក្សយាម
បានហើយនាំគ្នាចេញទៅក្វាម លើកទ័ពរុកតាមឋានបពិត ។
ហោះហើរដើរឡើងទៅជើងភ្នំ ច្រើនក្រុមច្រើនកងធ្ងន់ជនបទ
ដោយបុណ្យកុសលដល់កំណត់ គ្មានហត់គ្មានអន់ទន់កម្លាំង ។

លុះឡើងដល់ភ្នំពិភព(១)　　មកប៉ះសឹកទប់ទល់ប្រឆាំង
មួយទៀតក្លាហានមានកម្លាំង　　តតាំងជណ្ដើមសម្បើមក្រៃ ។
ខណ៍នោះគឺគង់ព្រះមហាពជ　　ទាំងប្អូនអំណាចរួមព្រួតដៃ
មានពលយោធាគ្នាច្រើនក្រៃ　　ពឹតដៃប្រយុទ្ធបើកឈុតច្បាំង ។
មហាពជទាំងប្អូនផ្ទួនតែយិត　　ច្បាញ់ដោយឫទ្ធិស្បូរជាំង ៗ
កងពលក៏បុកចូលរុកច្បាំង　　ប្រឆាំងរៀងខ្លួនយ៉ាងមួនម៉ាំ ។
ប៉ុន្តែមហាពជមិនអាចតាត់　　ការពារសង្កាត់ទ័ពទីប្រាំ
ពួកពលក្រាសក្រៃលដែលប្រចាំ　　សង្កាត់ទីប្រាំក៏ធ្លាយទៀត ។
អសុរបានចិត្តរឹតតែដេញ　　ទឹកជាចំណេញពេញមានស្នៀត
លើកពលបរដល់ឋានសួគ៌ទៀត　　ជ្រែកជ្រៀតរឹតជាន់ទេពទន់ខ្សោយ
ទេវតាចុងកាត់បិតមាត់ញក　　រត់ជ្រករកពួនខ្លួនឥតឈ្លោយ
អសុរដេញតាប់តាមពីក្រោយ　　ទេពតាខ្សត់ខ្សោយភ័យញ័រញាក់ ។
កើតក្ដៅក្រហាយខ្វាយមេពេត　　ពេញទាំងទេវលោកស្ទើរទីងធ្លាក់
នៅស្រុកទេវតាកើតភ័យភ្ញាក់　　គ្រោះថ្នាក់អសុររុលរុកពន ។
ឯព្រះលោកបាលទាំងប្អូនអង្គ　　ត្រូវបង់ជោគជ័យក្ដីក្លាហាន
ទប់ទល់កម្លាំងច្បាំងពុំបាន　　ក៏ប្រោយប្រាសប្រាណឥតបង្អង់ ។

---

១ ភ្នំដែលនៅជុំវិញភ្នំព្រះសុមេរុ មានភ្នំឈ្មោះយុគន្ធរជាដើម ដែលជាឋានរបស់ចតុលោក-
បាលមហារាជ ។

ទៅទូលព្រះឥន្ទពិនពិភព ជាមួយបារមីថ្លៃថ្នូន
បញ្ជាក់ប្រាប់ហេតុការណ៍តាមត្រង់ ទូលគៀនព្រះអង្គឲ្យប្រញាប់ ។
ព្រះឥន្ទបានស្តាប់សកទង្ការ នៃទេវក្នាក់ការដែលបានប្រាប់
ស្តេចឡើងវេជយន្ត.. ប្រញាប់ បន្តាប់យោធាបញ្ជាទៅ ។
ឃើញពួកអសុររុលឥតខ្លាច ដេញពួកមហាកដទោលលំនៅ
ទ្រង់គៀនយោធាឲ្យចូលទៅ សំដៅតតាំងប្រឆាំងទល់ ។
អសុរពេលនោះគ្រោះថ្នាក់ធំ ត្រូវមាំក្រំខ្លួនជួនអំពល់
ព្រះឥន្ទតាប់បោកឥតយោគយល់ ក្រហល់បកក្រោយថយប្រយុទ្ធ ។
ជ្រុលល្បិចគេចខ្លួនពួនមិនទាន់ ព្រះឥន្ទរួសរាន់កាន់អាវុធ
តាប់ដេញត្រាត់ក្នុងសមុទ្រ ធ្លាក់ស្រុតផុតពីទិសសួគ៌ឋាន ។
ជ្រុះចុះរបុំយដូចរុយធ្លាក់ គ្មាននៅសល់ម្នាក់ទាំងម៉ឺនលាន
ពួកពលអសុរអន្តរធាន អស់ពីវិមានសួគ៌គ្មានសល់ ។
រួចស្រេចទើបស្តេចត្រាច់យានយាត្រ វិលចូលប្រាសាទស្អាតនិម្មល
សោយសុខសម្បត្តិសម្បើមផល លែងព្រួយអំពល់ខ្វល់ហឫទ័យ ។
ឯពួកអសុរជ្រុលខ្លួនធ្លាក់ រងាញ័ររញាក់ភ្ញាក់គិតភ័យ
ដើមប្រាណបានពីផលាស័យ រត់ផាសដើរដៃចូលពិភព ។
បិទទ្វារនគរយ៉ាងមាំមួន ប្រុងការពារខ្លួនទាំងថ្ងៃយប់
ទើបអស់ហឫទ័យភ័យចំប្រប់ សោយសុខក្នុងភពដូចធម្មតា ។

តាំងតែពីនោះលុះឥឡូវ　　តែដល់រដូវប្រទៀនផ្កា
ចិត្តពួកអសុរក៏ហានក្លា　　ឡើងកាប់ទេវតាតែរាល់ដង ៗ
ប៉ុន្តែដូនកាលមិនហ៊ានរុក　　ចូលលុកដល់ឋានសួគ៌នេះផង
ព្រោះខ្លាចព្រះឥន្ទ្រចេញសំពាង　　ឲ្យហ្នងដូចមុនស៊ុនខ្លួនឡើយ ៗ
ឯព្រះឥន្ទ្រវិញពេញជាប្រាជ្ញ　　ដឹងថាគេខ្លាចដូច្នេះហើយ
ពេលច្បាំងមិនទៅខ្លួនឯងឡើយ　　នៅស្រណុកដោយតែគង់វាំង ៗ
ប្រើតែបុត្រម្នាក់សក្តិសមសួន　　ជាតំណាងខ្លួនទៅតតាំង
ឯពួកអសុរពុំហ៊ានច្បាំង　　សំកាំងមិតបករកឋានខ្លួន ៗ
មួយទៀតព្រះឥន្ទ្រនិម្មិតប្រាណ　　ឲ្យនៅទីឋានទ្វារទាំងបួន
បើពួកអសុរជ្រុលរុកកួន　　ថែរខ្លួនឆាកយល់រចល់រត់ ៗ
ព្រោះខ្លាចព្រះឥន្ទ្រសង្កិនណាក់　　ចាប់បោកទម្លាក់ធ្លាក់ទឹកហ្វត់
ខ្លាចនេះខ្លាចឆាប់ជាប់ជាល្បត់　　ខ្លាចហួសកំណត់ព្រោះបារមី ៗ
ទោះបីយ៉ាងនេះក៏អសុរ　　រុករុលចង់ពៀរជាប្រក្រតី
តែងតែនាំពលឡើងផែនដី　　ទារសិទ្ធិសេរីពីទេវតា ៗ
ប្រសិនពួកគេមានកម្លាំង　　ក៏អាចតតាំងច្បាំងសេនា
នៃនាគគ្រុឌយក្សកុម្ភណ្ឌ　　នឹងមហារាជាទាំងបួនបាន ៗ
សម្រុកលុកដេញទេពនិករ　　រឹកវិប្រចល់ពេញសួគ៌ឋាន

តាល់តែព្រះឥន្ទសំពន់ប្រាណ ទើបតវិលថ្កានគ្មានសេសសល់ ៗ
ប្រសិនជាខ្សាយថយកម្លាំង កងទ័ពចម្បាំងចុះទុព៌ល
ចូលដល់ត្រឹមនាគគំរបល់ ច្របល់គេចថយក្រោយគ្រប់គ្នា ៗ
ដូនបានឈ្នះនាគង៉ាកបាញ់គ្រុឌ ប្ដូបាញ់ប្រយុទ្ធកុម្ភណ្ឌ
ឬក៏ផ្កាយដល់ពលយក្ស ឬបាញ់ភជាទាំងបួនអង្គ ៗ
ក៏វិលមឹតបករកកន្ទ្វង វាន្ទ្វងព្រាត់ប្រាសវិនាសបង់
រត់ចូលនគរគ្មានបង្អង់ តម្រង់ប្រមូលគ្នាចូលទី ៗ
បើតាមសំនួនក្បួនតម្រា ដីកាសារត្ថទីបនី
ពោលដល់ប្រទេសទ្វភាគី ដែលជាឋានទីទាំងពីរពិត ៗ
គឺទាំងអសុរទាំងទេវតា មានដែនសីមាជាពិសិដ្ឋ
មានភជឋានទីកំពែងជិត ទ្វារបិទឥតល្បើកលើកពុំបាន ៗ
បើពួកអសុររុលសម្រុក ចូលលុកបុកឆ្លាយដល់សួគ៌ឋាន
អស់ពលទេវតាទាំងប៉ុន្មាន ប្រាយប្រាណប្រាសចូលក្នុងនគរៗ
តែបិទជិតទ្វារនាក់ពែង ស្រេចហើយក៏លែងក្រែងភ័យរណ៍
ទុកជាអសុរប្រឹងត្រដរ ក៏ចូលនគរពុំបានឡើយ ៗ
ឯអសុរវិញក៏ដូច្នោះ ប្រសិនមានគ្រោះមកដល់ហើយ
គឺបើចម្បាំងកម្លាំងស្បើយ ក៏មឹតរកក្រោយទីពឹងខ្លួន ៗ

ប្រាសប្រាណរត់បោលចូលខាងក្នុង កំពែងទីក្រុងដ៏មាំមួន
ទ្វារបិទជិតជាប់គ្រប់ទាំងបួន ស្រេចហើយរួចខ្លួនជាក្សេមក្សានៗ
ទោះបីទេវតាកប់កោងធ្នូ ក៏នឹងខ្មាយទៅពុំបាន
ដូច្នេះនគរទាំងពីរបាន ឈ្មោះថាសុខសាន្តគ្មានចម្បាំង ៗ
គឺក្សេមទាំងប្រាណក្សាន្តទាំងភព គ្មានព្រួយពីទប់ទល់ប្រឆាំង
បើចង់រុះរើធ្វើចម្បាំង លុះណាតែតាំងទ័ពចេញក្រៅ ៗ
បើនៅទីក្រុងក្នុងកំពែង អស់ភីតគិតក្រែងលែងក្តួលក្តៅ
សប្បាយកាយចិត្តឥតហ្មងសៅ សប្បាយនិត្យនៅដៅសុខសាន្តៗ
រឿងនេះស្មេះចប់បញ្ចប់ស្តី សូមលោកប្រុសស្រីមិត្រអ្នកអាន
យកជាអារម្មណ៍ផ្សំកំសាន្ត ខ្ញុំបន្ទន់ប្រាណលាសិនអើយ ។

-ចប់-

ផ្នែកអក្សរសាស្ត្រ

# ភាសាសាស្ត្រ និង អក្សរសាស្ត្រខ្មែរ

រៀបរៀងដោយ ឌ. គាម

(តមក)

អក្សរសាស្ត្រខ្មែរ ខ្មែរគួរថែថួន
ឲ្យបានខ្ជាប់ខ្ជួន គង់វង់គត់មត់ ។
ព្រោះអក្សរជាតិ គោលជាតិប្រាកដ
អក្សររលត់ ជាតិក៏រលាយ ។

ប.ព.

## ជំពូកទី ១

## តារាងភាសាជំពូកនេះខ្លះ

| ភាសាអារក្ស | ភាសាសាមញ្ញ |
|---|---|
| កាប៉ាំង | ប្រាក់មួយរៀល |
| គន្ទូន់ឆាក់ក | បេក |
| អការសាហារ | ស្រា |
| ក្ដូនបាប | មនុស្សឈើ |
| កន្ទ្រើញ | សាច់ជ្រូក |

*ការសិក្សាខ្លះភាសាអារក្ស មានច្រើនទៅទៀត តែពេលនេះ ខ្ញុំលើកយកតែប៉ុណ្ណោះមកជាឧទាហរណ៍ ។*

*១)– ចំណែកមន្តអាគមភាសា ក៏នៅមានប្លែកពីភាសាអារក្សដែរ ៗ*

មុនគេសេកជាសំមន្តអាគមអ្វីមួយគេថា ឱម សិន ដែលជាតំណាង ឈ្មោះ ព្រះវិស្ណុ-សិវ និងព្រះនាកយណ៍ ។

ភាសាចំពូកនេះ មិនមែនមានត្រឹមតែសម័យព្រាហ្មណ៍សាសនាចូលមកប្រទេសយើងទេ ឬក៏តាមតែការនឹកឃើញរបស់មនុស្សទេ សូម្បីតែនៅក្នុងពុទ្ធសម័យ ក៏នៅតែមានដែរ តែមន្តអាគមរបស់ព្រះពុទ្ធ មិនមានប៉ះពាល់ដល់ជីវិតសត្វណាមួយឡើយ ។

៙. កឹ ការណំ យជេសិ យជេសិ អហម្បិ តំ ជាជាមិ ។

ចុះភាសាមន្តអាគមមានតែខ្មែរ ឬសាសន៍ដទៃទៀតមានដែរ? មានស្ទើរតែគ្រប់ភាសា ។ អាមេរិកាំង សៀម, យួន, ចិន, ឥណ្ឌា មានដូចគ្នា តែខ្ញុំមិនយកពាក្យទាំងនោះមកជូន ព្រោះមិនសូវមានការសំខាន់ ។

## ៨- សិល្បភាសា (Art of Language)

សិល្បភាសា សំដៅយកសិល្បដែលចំនួសភាសា ។ សិល្បបែបនេះ គេមិនបាច់សរសេរតួអក្សរប្រាប់ដល់ទស្សនជនទេ ព្រោះថាសិល្បនោះ អាចសំដែងប្រាប់សិល្បនេះ មានន័យយ៉ាងនេះ សិល្បនោះមានន័យយ៉ាងនោះ ។

ប្រទេសកម្ពុជា ជាប្រទេសកាន់ព្រះពុទ្ធសាសនា សិល្បករកេសាងព្រះពុទ្ធរូប មិនបាច់ចារឹកអក្សរប្រាប់គេថា នេះជាព្រះពុទ្ធទ្រង់បិណ្ឌបាត្រ នេះសំដែងធម្មចក្រ គេគ្រាន់តែកសាងឲ្យទៅតាមពុទ្ធចរិត គេអាចយល់

បានថាព្រះពុទ្ធរូបនេះ គេធ្វើតំណាងព្រះអង្គតាមពុទ្ធចរិតនោះ ឬក៏តាមពុទ្ធប្រវត្តិនោះ ។

ដូចគួយ៉ាងព្រះពុទ្ធរូបគង់ពត់ព្រះភ្លៅ មានព្រះហស្តស្តាំនៅលើព្រះហស្តឆ្វេងដាក់នៅលើព្រះភ្លៅ ។ ព្រះពុទ្ធរូបបែបនេះ អាចសន្មតបានថា ព្រះពុទ្ធរូបទ្រង់សមាធិ ឬ វិតិកមុទ្រា ។

ការកសាងព្រះពុទ្ធរូបមាន ៨ បែប តែខ្ញុំលើកយកតែការកសាងព្រះពុទ្ធរូបមួយនេះជាឧទាហរណ៍ ។ ការរចនាព្រះពុទ្ធរូបបែបនេះគេអាចសំគាល់បានថា ព្រះពុទ្ធទ្រង់សមាធិ ចុះម្ដេចបានតែគេស្គាល់ថា "ទ្រង់សមាធិ" ? មកពីសិល្បបង្ហាញប្រាប់ព្រះនាមព្រះពុទ្ធ ។

មួយទៀតសិល្បខាងល្ខោន គួយ៉ាងដូចមុខយក្ស មុខឥសី តើគេមានសរសេរអក្សរប្រាប់ថា នេះមុខយក្ស នេះមុខឥសីឬទេ ? អត់មានទេ ។ ចុះម្ដេចបានតែគេស្គាល់ថាមុខយក្ស មុខឥសី ? មកពីសិល្បៈប្រាប់ឲ្យស្គាល់ថា មុខដែលគួរឲ្យខ្លាចក្រវើមក្រវ៉ម គេថា « មុខយក្ស » ។ បើឃើញមុខញញឹមរួចបែកខ្នែងដូចកន្ទុយត្រីប្រា គេស្គាល់ច្បាស់ថា « មុខឥសី » ។ បើឃើញមុខ ៤ គេអាចថាមុខ "ព្រហ្ម" ។

សិល្បកម្ម (Ballet) ដូចរបាំព្រះរាជទ្រព្យ បញ្ចេញកាយវិការ គេអាចដឹងថា ល្ខោនរាំរឿងនេះ ឬស្ដែងរឿងនោះៗ គេមិនសូវប្រកាសឈ្មោះរឿងដែលត្រូវរាំនោះទេ តែសម័យក្រោយមក មនុស្សយើងមិនសូវយល់

សិល្បកាសា ម្ល៉ោះហើយគេបោះពុម្ពកម្មវិធីចែក ។

សិល្បសាកាខាងព្រហ្មញ្ញសាសនាវិញ ដូចជាស្លាធម៌ដូង សាជម ជាដើម គេគ្រាន់តែឃើញវត្ថុតាំងនោះ គេអាចឲ្យឈ្មោះថា " ស្លាធម៌សាជម " ។

ការលើកយកឧទាហរណ៍មកជាឧស្សាហ: ក៏គួរយល់បានថា សិល្បរចនាតាំងនេះ គេអាចយល់បានដោយមិនបាច់មានពាក្យសំដីប្រាប់ឡើយ ដោយហោចទៅទៀត គេអាចសំគាល់បានមនុស្សសាសន៍ប្លែក ។ គ្នា ដោយគេមើលសំលៀកបំពាក់គ្រឿងអលង្ការ ។

## ជំពូកទី ២

## ភាសាខ្មែរតាមនិរុត្តិសាស្ត្រ

ដូចខ្ញុំបានបរិយាយមកក្នុងជំពូកទី ១ រួចខ្លះមកហើយ អំពីកំណើតភាសាខ្មែរ តែខ្ញុំមិនបានបរិយាយឲ្យច្បាស់លាស់ ។ ឥឡូវខ្ញុំសូមបែរទៅខាងភាសាសាស្ត្រខ្មែរវិញ ។ ដើម្បីឲ្យស្រួលវិនិច្ឆ័យនូវបញ្ហាភាសាសាស្ត្រខ្មែរ ខ្ញុំសូមលើកប្រស្នាមួយ ព្រោះខ្មែរយើងមានចំនួនច្រើនថាភាសាខ្មែរមានដើមកំណើតមកពីភាសាបាលី និង សំស្ក្រឹត បើលោកអ្នកយល់ឃើញថា ដើមកំណើតភាសាខ្មែរយកមកពីបាលី-សំស្ក្រឹត ចុះតើជនជាតិឥណ្ឌាដែលនាំអារ្យធម៌ចូលមកប្រទេសខ្មែរ សម័យគោកធ្លក

នៅសតវត្សទីប៉ុន្មាន ? ចុះជនជាតិគោកធ្លក មានមុនឥណ្ឌាចូលមក ឬខាងក្រោយ ?

បញ្ហានេះអាចបញ្ជាក់ឲ្យយល់ច្បាស់ថា ឥណ្ឌានាំអារ្យធម៌ចូលមកប្រទេសកម្ពុជាសម័យសតវត្សទី ២ ក្រោយសម័យកៅណ្ឌិន្យ តាំងអាណាខេត្រនៅនគរភ្នំ ។ ជនគោកធ្លក គេមានភាសានិយាយរួចទៅហើយ តែនៅមិនទាន់មានអក្សរសរសេរនៅឡើយទេ ។ ចុះគេនិយាយភាសាអ្វី ? ពិតជាភាសាខ្មែរ ។ បើសិនជាជនគោកធ្លក មានក្រោយជនជាតិឥណ្ឌានាំអារ្យធម៌មកនោះ ខ្ញុំហ៊ានថាយថា ប្រែបគ្មានជាតិកម្ពុជាទេ ឬប្រហែលជាសព្វថ្ងៃនេះ ខ្មែរយើងនិយាយភាសាដូចឥណ្ឌា ។ តែថាសម័យឥណ្ឌានាំអារ្យធម៌មកប្រទេសខ្មែរជនជាតិខ្មែរ ក៏ទទួលយកអារ្យធម៌នេះ មកធ្វើជាអារ្យធម៌ខ្មែរឡើង ហើយទើបភាសាបាលី សំស្រ្កឹត ផ្សាយឥទ្ធិពលលាយឡំចូលជាមួយភាសាខ្មែរឡើង ។

ដល់ប្រទេសកម្ពុជាមានភាសាហើយ តែមិនទាន់មានអក្សរជារូបរាងទុកឲ្យងាយស្រួលកត់ត្រាចំណាំទេ ។ ចុះសម័យនោះខ្មែរយើងយកអ្វីជាអក្សរសាស្រ្តសំរាប់កត់ចំណាំ ? នេះតាមអ្នកនិរុត្តិសាស្រ្ត (etymologists) ថា គេច្រើនតែយកវត្ថុ ឬការគ្រឹត ធ្លាក់ចំណាំចំពោះរឿងហេតុអ្វីៗ ។ យើងពិនិត្យមើលខាងព្រះពុទ្ធសាសនា ដែលយើងមិនទាន់មានអោងប្រើ តើគេអាចចំណាំមោងដូចម្តេច ? គ្រងនេះគេយក

ស្រមោលជាឆាយាលក្ខណ៍ ដូច្នេះហើយបានជាព្រះសង្ឃមាន «កាត្រ» ជាគ្រឿងសំគាល់ ដែលសព្វថ្ងៃគេហៅថា "ឆាយា" ។

មួយទៀត យើងឮគេនិយាយឬទេ? ដូចគេសួរគ្នាគេថា:

មីងយុះ: យ៉ី! យ៉ាន់! យ៉ាន់! កូនពូសុខទៅគេបួសកើតខែណាទេ, យ៉ាន់ឯងចាំឬទេ?

មីងយ៉ាន់: យូ! ឯងគិតមើល គ្នាដូចជាភ្លេចដែរ តែមើលឆ្នាំទៅ គេធ្វើបុណ្យបញ្ចុះសីមាវត្តចំបក់ឆ្នាំជូត ក៏មិនហ៊ានទៅមើលពិធីបុណ្យនោះទេ ក៏ខ្លាចក្រែងធុង ។

មីងយុះ: មែនហើយ ក៏កើតឆ្នាំជូតមែន ខែដែលយើងទៅបេះត្រកួនទៅត្រពាំងព្រីងនោះណា ។

ឃើញថា ស្រីទាំងពីរនេះ យកពិធីបុណ្យបញ្ចុះសីមា យកការបេះត្រកួន កំណត់ពេលវេលា (ខែឆ្នាំ) ។

មួយទៀត តាមពាក្យបកមកថា(សូមកុំយកជាការប្រមាណ គ្រាន់តែជាគ្រឿងពិចារណា) គេជាពួង យកការក្រិតឈើ ឬ ឫស្សីជាគ្រឿងចំណាំជំនួសអក្សរ ដូចជាគេផ្ញើសំបុត្រទៅទារលុយគេ គេត្រូវផ្ញើ "ឫស្សីមួយកំណាត់" បានន័យថា " ទារលុយ " រួចអ្នកជំពាក់បំណុលមិនទាន់មានលុយសង គេត្រូវដុតចុងឫស្សីម្ខាងផ្ញើទៅម្ចាស់លុយវិញ ដោយសំដៅយកន័យថា " គ្មានលុយទេ " បើម្ចាស់លុយបន្ធូរតារឲ្យខានតែ

បាន ត្រូវដុតចុងម្ខាងទៀត ហើយផ្ញើទៅកូនបំណុលដែលបានន័យថា "ត្រូវតែសង" ។ ការស្មានរបស់ខ្ញុំ ដូចជាត្រូវដែរ តែការលើកយកឧទាហរណ៍មកជូននេះ សូមលោកទុកថាជាល្បាយផ្សំក្នុងការស្រាវជ្រាវអក្សរសាស្ត្រខ្មែរទៅចុះ ចាំថ្ងៃណាយើងដឹងពិតថា ពួកពួងគួយ គេប្រើរបៀបនេះជាអក្សរសាស្ត្រ ដូចខ្ញុំបានអធិប្បាយមកខាងលើនេះ សូមយកជាការទៅចុះ ព្រោះសម័យឥឡូវ យើងមិនទាន់មានអ្នកបច្ចេកទេសខាងការស្រាវជ្រាវអក្សរសាស្ត្ររបស់ជនជាតិពួងគួយ តាមរបៀបរូបអក្សរសាស្ត្រ (Pictography) ដូចជាតិអេហ្ស៊ីបជាដើម ។

ខ្ញុំសូមលើកយកអក្សរបែបអេហ្ស៊ីបមកធ្វើជាឧទាហរណ៍រូបនេះ  អេហ្ស៊ីបថា "ខា" (Kha) ប្រែថាផ្កាឈូក ហើយគេធ្វើដូចរូបផ្កាឈូក ឬមានន័យថាលេខ ១.០០០ ។ ពាក្យថាជេបា ( dje ba ) មានន័យថា ម្រាមដៃ ឬលេខ ១០.០០០ រូបគេធ្វើម្រាមដៃ  ។ ពេលដែលគេត្រូវសរសេរផ្សំជាពាក្យជាសេចក្តីមួយ ដូចជាឧទាហរណ៍នេះ(១)

 បានន័យតាមទស្សនិយមថា "គោ

---

១– រូបអក្សរនេះ ចម្លងចេញមកពីសៀវភៅ ( The Gift of Language by Margaret Schlauch P. 38)

ស្រោមដៃ ៣ ផ្កាឈូក ២" តែដូចខ្ញុំបានពោលរួចមកហើយថា ស្រោមដៃ ១០.០០០ ផ្កាឈូក ១.០០០ដូច្នេះត្រូវអានថា «គោ ៣២.០០០ក្បាល»

ឯរូបអក្សរសាស្ត្ររបស់ជនជាតិអាមេរិកាំងស្បែកក្រហម នៅរដ្ឋ-មិស្សួរីខាងលើ (Tribes of the Upper Missouri) សរសេរដូច្នេះថា(១)




Reading: We are in a camp of thirteen lodges (1); encamped on a creek above the forks (2); started hunting with eight horsemen (3); (each symbol ɔ represents one horseman); on the way slept out two nights (4); traveled in the direction indicated by . . . ɔ (5); found buffalo (6); behind the second creek from the camp; killed some and made travois, or sledges (7); and slept but one night (8) on our return home.

អានថា: លេខ១ យើងនៅក្នុងជំរំដែលមានបង្ហា១៣ ។ លេខ២ យើងបោះជំរំនៅក្បែរប្រឡាយទឹកមួយ ។ រូបលេខ ៣ ចាប់ផ្តើមបរបាញ់ជាមួយអ្នកជិះសេះ ៨ នាក់(សញ្ញា ɔ នេះមួយៗ ជំនួសអ្នកជិះសេះម្នាក់) ។ រូបលេខ ៤ទៅតាមផ្លូវ ដេកផ្លូវ ២ យប់ ។ រូបទី៥ ធ្វើដំណើរឆ្ពោះទៅកាន់ទិសដោយប្រើសញ្ញា....ɔ ។ លេខ ៦ ប្រទះសត្វក្របីនៅខាងក្រោយ

១– រូបនេះ ចម្លងចេញមកពីសៀវភៅ Man Culture and Society P. 217 ។

ប្រឡាយទឹកទី ២ ពីជំរៅ ។ លេខ ៧ សម្គាប់ក្របីខ្វះ ហើយខ្វះទៀត យកធ្វើជាគាវ ។ លេខ ៨ ហើយដែកថ្ពវមួយយប់ដល់ ពេលដែលយើង ត្រឡប់មកផ្ទះវិញ ។

សូមពិនិត្យមើលសញ្ញានេះមួយទៀត ។



ស្នាមគំនូសនេះ ចិនយកប្រើថា «ភ្លើង» បើចិនចង់ សរសេរថាភ្លើង ត្រូវសរសេរដូច្នេះ ។ ពាក្យនេះ ចិន ថាភ្លើង សមណាស់ ដោយយើងមើលឃើញអណ្តាត ភ្លើងព្រោលឡើងលើ ។

ឥឡូវយើងបែរមកអក្សរសាស្ត្រខ្មែរវិញ ។ តាមប្រភពខ្លះថាអក្សរ ខ្មែរយកបែបមកពីឥណ្ឌា ខ្លះថាយកអក្សរបែបឥណ្ឌាមកកែច្នៃឡើង ហេតុ ទាំងពីរនេះមិនខុសគ្នាប៉ុន្មានទេ តែអក្សរបែបឥណ្ឌាមានច្រើនយ៉ាង ។ នៅប្រទេសឥណ្ឌាប៉ែកខាងជើង គេប្រើអក្សរមួយបែបកន្ទ្រុំ ដែល ជាកំណើតនៃអក្សរទេវនាគរី ឯអក្សរដែលជាខ្មែរយកលំនាំតាមនោះមាន រូបទ្រង់ទ្រាយមូល ជាអក្សរដែលគេប្រើនៅឥណ្ឌាប៉ែកខាងត្បូង(ទក្ខិណា. បថ) Deckan ឬជាអក្សរ «ព្រាហ្មី» នៅក្នុងសតវត្សទី ៦ ។

គេនឹកឆ្ងល់ថា ភាសាសំស្ក្រឹតជាភាសាសំរាប់ជនជាតិឥណ្ឌា ដែល ជាអំបូរ ឥណ្ឌូ-អឺរ៉ុប (Indo Europrean) ដែលជាមូលហេតុ ។ ចុះ ភាសាខ្មែរម៉េចមិនចូលទៅក្នុងអំបូរ ឥណ្ឌូ-អឺរ៉ុប ផង? លោក អៀ:-

គេក៏សរសេរថា "ភាសាខ្មែរ មានពាក្យសំស្រ្កឹតនិងបាលីលាយបញ្ចូលផងជាច្រើនក្រៃលែង ប៉ុន្តែភាសាយើងមិនមែននៅក្នុងអំបូរ វណ្ណ-គឺរូបទេ ព្រោះរបស់ដែលយើងមានដូចខ្វះនឹងភាសាក្នុងត្រកូលនេះ គ្រាន់តែជាទី-យណ្ឌសាស្រ្ត (Sémantique) គឺខាងសេចក្តីរបស់ពាក្យ (Vocabulaire) តែខុសគ្នាខាងសូរសាស្រ្ត (phonétique) គឺខាងការបញ្ចូលសំឡេង វិធីការហើយខុសគ្នាខាងរូបសាស្រ្ត (morphologie) គឺវិធីប្រើពាក្យ សំរេចរូបពាក្យ គឺខាងវេយ្យាករណ៍ (Grammaire) ។

ភាសាខ្មែរយើងនៅក្នុងអំបូរភាសាមួយហៅថា អំបូរ-មនខ្មែរ (Le Cambodgien appartient à la famille des parlers indochinois appelés Mon-Khmer) (France Asie numéro spécial 114-115-P 428.

យើងអាចសន្និដ្ឋានបានថា **ភាសាខ្មែរពិតជាភាសាខ្មែរ មិនទទួលពីគេ តែបើអក្សរខ្មែរមានលំនាំតាមតំណៀ ។**

ដើម្បីឱ្យយល់ច្បាស់នូវភាសាសាស្រ្តខ្មែរ យើងត្រូវតែសិក្សាអក្សរសាស្រ្តឲ្យជ្រៅជ្រះដែរ ។ ចុះការសិក្សាភាសានេះមានប្រយោជន៍ដូចម្តេច? ពាក្យថាភាសា ខ្ញុំបានពន្យល់ពីមុនរួចមកហើយ តែពេលនេះខ្ញុំនិយាយពីភាសាទៀតដោយយល់ឃើញថា ភាសានិងអក្សរទាក់ទងគ្នា ។ ខ្ញុំសូមលើកយកពាក្យថា " សេះ " ខ្មែរយើងមានសំឡេងថា " សេះ" បារាំងថា (Cheval) ឯអង់គ្លេសថា «Horse» ភាសាទាំង ៣ នេះ មាន

លំនាំសំឡេងផ្សេងៗគ្នា មានលំនាំអក្សរផ្សេងៗគ្នា តែសំដៅយកសត្វតែមួយ ដែលខ្មែរឲ្យឈ្មោះថា « សេះ » តែសំឡេងនឹងលំនាំពាក្យរបស់មនុស្សទាំងពួកក្រុមនេះផ្សេងៗគ្នា ។ ការសិក្សានូវភាសាត្រូវកំណត់ដូច្នេះ ៖

១- ភាសាសាស្ត្រ (Philologie) គេរៀនភាសាសាស្ត្រ ដើម្បីឲ្យយល់ច្បាស់នូវវប្បធម៌របស់ជាតិ គឺអក្សរសាស្ត្រ·ភាសាឬក៏សាសនា ។ ដូចគេរៀនភាសាបារាំង អង់គ្លេស គេមុខតែបេះយល់នូវអារ្យធម៌របស់សាសន៍នោះ ។ បើយើងរៀនភាសាយល់ច្បាស់នូវឫសគល់ភាសាហើយ យើងមុខជាបានជំនាញខាងភាសា (Linguistic) ។ ការជំនាញខាងភាសានេះ គេសន្មតថាជាអ្នកជំនាញខាងវិទ្យាសាស្ត្រនឹងភាសាសាស្ត្រ ។

២- វចីភាសាសាស្ត្រ (Linguistic) ការសិក្សាឲ្យស្ទាត់ជំនាញខាងសំដីនិយាយរបស់មនុស្ស ហើយនឹងសោភណភាសា ។ ការសិក្សាខាងវចីភាសាសាស្ត្រនេះ គឺសំដៅយកការសិក្សាដើមកំណើតភាសា ធម្មជាតិភាសា វេយ្យាករណ៍ភាសា របៀបនឹងការប្រែប្រួលនៃភាសា ការសំខាន់បំផុតក្នុងវចីភាសាសាស្ត្រ គឺត្រូវសិក្សាឲ្យយល់ច្បាស់នូវស័ព្ទវិទ្យា, សព្ទសាស្ត្រ សណ្ឋានវិទ្យា មូលវិទ្យា នឹងវេយ្យាករណ៍ ។

ក)- ស័ព្ទវិទ្យា ឬ សូរសាស្ត្រ (Phonétique) សូមកុំច្រឡំនឹងពាក្យថា ស័ព្ទសាស្ត្រ ។ ស័ព្ទវិទ្យា ការសិក្សានូវការបញ្ចេញសំឡេងភាសា នឹងវិញ្ញាណណាខ្លះ ដែលទាក់ទងក្នុងការបង្កើតឲ្យចេញសំឡេង

ព្យញ្ជនៈ ឲ្យស្រួលយល់ច្បាស់ដល់សោតប្បសាទអ្នកស្តាប់ ។ ឧបមាថា ព្យញ្ជនៈ កើតក្នុងឋាននៈនេះ ឋាននៈនោះ ដូចជាកណ្ឋជៈ តាលុជៈជាដើម ។

១)- ស័ព្ទសាស្ត្រ (Phonologie) ការសិក្សាខាងសំឡេងរបស់ភាសាដែរ តែជាមានការសិក្សាពិសេសដូចជាសាតែភាសាទីផ្ទើស្តីភាសា ដែលសំឡេងភាសាត្រូវប្រែ ឬសម័យណាគេប្រែពាក្យ ។ ការសិក្សានូវសំឡេងភាសានេះ បាននិយាខាងអត្ថាពិវឌ្ឍដូចគ្នា តែដល់មានផ្សេងគ្នាទៅវិញ ឧបមាដូចជាប្រយោគខ្ញុំនេះ ៖

" ទិញកន្ត្រលប្រគេនលោកនេន "

អ្នកខេត្តធំ (នៅខាងចកណ្តាល) មានប្រយោគនេះថា

" ទិញកន្ត្រើលប្រគើនលោកនើន "

អ្នកខេត្តជ នៅឃុំព្រែកប្រសប់ ស្រុកឆ្លូង ខែត្រក្រចេះ មានប្រយោគនេះ

" ស៊ីនំបញ្ចុករូប ចុកហ៊ឹម្នួយដក ទៅអង្គុយក្បែរព្រែក " ថា ៗ

" ស៊ីនំប៉ាជិករូប ជិកហ៊ឹមមួយឈ្មក់ ទៅអង្គុយក្បែរព្រាក "

នេះហើយដែលជាស័ព្ទសាស្ត្រ ប្លែកពីស័ព្ទវិទ្យា ។ បើអធិប្បាយឲ្យវែងឆ្ងាយទៅទៀតទៅ មុខតែចូលក្នុងវេយ្យាករណ៍ ដូច្នេះខ្ញុំទីងផ់កបនៅក្នុងវេយ្យាករណ៍ ។

ការសិក្សានូវសំឡេងអក្ខរវិធីដែលមានដូចគ្នា គេអាចនិយាយថា អក្ខរវិប្បលាស គឺការប្រែប្រួលនៃអក្សរ ។

## ការប្រែប្រួលមានដូចតទៅនេះ:

| ស្រះដើម | ប្រែជា | ឧទាហរណ៍ | អានថា | សង្គមភាសា |
|---|---|---|---|---|
| ិ | េ | សិរ | សេរ | |
| ិ | ី | បិតា | បីដា | |
| ឹ | េ | សឹរ | សេរ | |
| ុ | េា | ខុរ | ខោរ | តាមសំដីអ្នកសៀមភាគខ្លះ អានចេញសំឡេង- , រ និងដែល |
| ព្យញ្ជនៈ | ប្រែជា | ឧទាហរណ៍ | អានថា | |
| ត | ដ | បិតា | បីដា | |
| រ | ន | មេរុ៍ | មេន | តាមសំដីសៀម |

តែចំពោះពាក្យឯទៀត ៗ និងបញ្ហាអក្ខរាវិរុទ្ធឯទៀត ៗ ស្រេចតែសម្រួលទៅតាមវេយ្យាករណ៍ ដូចជា ឃោសៈ អឃោសៈជាដើម ។ បើគួរពិនិត្យខ្លះដូចពាក្យថា "អញ" ហាក់ដូចជាសរសេរថា "អាញ់" មួយទៀត ដូចពាក្យថា "ឲ្យ" តាមក្បួនវេយ្យាករណ៍ មិនត្រូវតម្រូវតាមវិធីដូច្នេះទេ តែគ្រប់ភាសា នៅក្នុងវេយ្យាករណ៍ គេមានពាក្យមួយថា "អញ្ញត្រស័ព្ទ" (Exception) ។

គ)- សណ្ឋានវិទ្យា ឬ រូបសាស្ត្រ (Morphologie) ការសិក្សានូវទ្រង់ទ្រាយភាសា គឺការរៀនឲ្យចេះភាសា តាមក្បួនវេយ្យាករណ៍ ដែលនឹងសរសេរឲ្យបានត្រឹមត្រូវ ដូច្នេះនឹងមានពន្យល់នៅក្នុងវេយ្យាករណ៍ ។

ឃ)- មូលវិទ្យា (Sémantique) តាមគណៈកម្មការវប្បធម៌ នឹងនៅក្នុងសៀវភៅ « ភាសាខ្មែរ » របស់លោក អៀវ-កើស ប្រែ (Sémantique) ថានិរុត្តសាស្ត្រ ។

ការសិក្សានូវពាក្យដែលប្រែប្រួលទៅតាមទ្រឹស្ដី នឹងសាវតារអក្សរសាស្ត្រដូចជាមានពាក្យមួយថា « លោះ » ។ លោះជាឈើស៊ីផ្លែតែដល់សម័យសព្វថ្ងៃនេះ គេប្រែថា « ដើមបំពេញរាជ្យ » ទៅវិញ នេះតាមទ្រឹស្ដីអក្សរសាស្ត្រ ឯតាមសាវតារអក្សរសាស្ត្រថា « ព្រះបាទសម្ដេចឧទ័យរាជា ទ្រង់សព្វព្រះរាជហឫទ័យនឹងផ្លែឈើនេះ ព្រះអង្គក៏ប្រោសព្រះរាជទានឲ្យហៅថា « ដើមបំពេញរាជ្យ » ។ ទ្រឹស្ដីអក្សរសាស្ត្រមួយទៀត ដូចជាពាក្យថា « បន្ទន់ » ពីដើមគេថា « បាំងគន់ » គឺបិទបាំងកុំឲ្យគេគយគន់ » ។

ង)- វេយ្យាករណ៍ ត្រង់នេះខ្ញុំស្ទើរតែមិនបាច់ពន្យល់ទេ ព្រោះសៀវភៅជាច្រើនបានសរសេរអំពីវេយ្យាករណ៍ខ្មែរ តែខ្ញុំបានដកបទៅក្នុង

សណ្ឋានវិទ្យាថា ខ្ញុំនឹងអធិប្បាយទៅក្នុងវេយ្យាករណ៍ ។ វេយ្យាករណ៍ខ្មែរដែលមើលទៅឃើញឆ្គងជាទីបំផុតនៅត្រង់ "សេចក្ដី" និង "ការ" ដូចពាក្យថា :

ដើរ - ស៊ី

ដល់ការកនាម ឬ ក្រិតនាម យើងប្រើថា "ការដើរ, ការស៊ី" តែបើយើងថា "សេចក្ដីដើរ, សេចក្ដីស៊ី" ដូចជាឆ្គងណាស់ ។

របៀបប្រើ ការ, សេចក្ដីនៅមុខនាមក្រិត ឬ ការកនាមកុំឲ្យឆ្គងនោះ ត្រូវយល់ថា បើអំពើ ឬ នាមជារូបី (nom concret) ត្រូវប្រើ "សេចក្ដី" នៅមុខ បើនៅមុខនាមក្រិត ឬ ការកនាមជាអរូបី (nom abstrait) ត្រូវប្រើ "ការ" ។

ការសិក្សានូវវេយ្យាករណ៍នេះ គេត្រូវរៀនឲ្យជ្រះទៅតាមជំនាន់វេយ្យាករណ៍ ដែលប្រែប្រួលទៅតាមជំនាន់សាវតារ (Grammaire historique) ។

វេយ្យាករណ៍ខ្មែរ ដែលឃើញមានប្លែកគ្នាបន្តិចបន្តួចដូចជានៅតាមសង្គមជនបទភាសាខ្លះ ដែលនិយាយផ្ទុយគ្នា ដូចជាអ្នកនៅបាត់ដំបង ពោធិសាត់ជាដើម :

១. "បេកខ្ញុំ" ថា "ខ្ញុំបេក"

បើពិនិត្យទៅ ដូចជាភាសាអង់គ្លេស ឬ ដូចបាលីដែរ ។

(នៅមានត)

# ពាក្យខ្មែរប្រែពីបរទេស

## ដោយគណៈកម្មការជាតិនៃការសិក្សា ផ្នែកអក្សរ " ក "

( តមក )

---

| | |
|---|---|
| Section (n.f.) | ផ្នែក (ព-ច្ប-) : ចំណែកនៃបំពួក ។ |
| Séance préliminaire | សម័យប្រជុំប្រារព្ធ ។ |
| Tome (n.m.) | កណ្ឌ (កាន់) |
| Titre (n.m.) | មាតិកា : មេសេចក្តីដែលដាក់នៅខាងដើមនៃបំពួក ។ ចំណែកនៃគន្ថី ។ |
| Volume (n.f.) | ក្បាល ( សៀវភៅ ) ។ |

x x x

| | |
|---|---|
| Abandonner le domicile conjugal | បោះបង់លំនៅសង្វាស ។ ពច្ប ។ |
| Abandon du domicile conjugal | ការបោះបង់លំនៅសង្វាស ។ពច្ប។ |
| Abroger (v.t.) | ធ្វើនិរាករណ៍ : ធ្វើនិរាករណ៍នូវអត្ថបទ គឺបដិសេធអត្ថបទនេះទៅអនាគត បានសេចក្តីថាលែងឲ្យមានផលចាប់ពីពេលនិរាករណ៍ ។ពច្ប ។ |
| Absence du consentement | ការគ្មានសេចក្តីព្រមព្រៀង ។ពច្ប។ |
| Acquérir la nationalité cambodgienne | បានសញ្ជាតិជាខ្មែរ ។ |
| Acquisition la nationalité cambodgienne | ការបានសញ្ជាតិជាខ្មែរ ។ |
| Acquérir à titre onéreaux | បានដោយចេញថ្លៃ ។ ពច្ប ។ |
| Acquisition à titre onéreaux | ការបានដោយចេញថ្លៃ ។ពច្ប ។ |

( នៅមានត )

# វចនានុក្រមសំស្ក្រឹត-ខ្មែរ

*ព្រះមហា ចាំង - ខាត់ រៀបរៀង*

( តមក )

អតិវ្យយ  បុ. កិរិយាអស់ទៅក្រៃលែង, អន្តរធាន ។

អតិវ្យសនិន៑  គុ. ដែលវិនាសក្រៃលែង ។

អតិវ្យាធិន៑  គុ. ដែលចាក់ក្រៃលែង, ដែលមុត . . . ។

អតិវ្រជ៑  ធាតុ. ដើរទៅក្រៃលែង, ឆ្លងកាត់ ។

អតិវ្រត  គុ. ដែលមានព្រតក្រៃលែង, ដែលជ្រះថ្លាក្រៃលែង ។

អតិឝក្ត  គុ. ដែលអង់អាចក្រៃលែង, ដែលមានអំណាច ។

អតិឝក្រ  គុ. ដែលជាឥន្ទ្រៈក្រៃលែង, ដែលជាព្រះឥន្ទ្រប្រសើរ ។

*អតិឝក្រគេតិន៑* គុ. ដែលល្អជាងព្រះឥន្ទ្រដោយក្រៃលែង ។

អតិឝង្ក៑  ធាតុ. សង្ស័យក្រៃលែង ។ *អតិឝង្កិត* គុ. ដែលរង្កៀកក្រៃលែង ។

អតិឝង្កា  ស្ត្រី. សេចក្តីខ្លាចក្រៃលែង ។

អតិឝង្កិតវ្យ  គុ. ដែលគប្បីរង្កៀកក្រៃលែង ។

អតិឝប  គុ. ដែលម្រវញូទក្រៃលែង ។

*(នៅមានតក)*

# រឿងសាមកុក

## កណ្ឌទី ៤៨

ឧកញ៉ាវិបុលរាជសេនា ញ៉ុក-ថែម ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកកងវៃឆ្លាសបើបានអាន
នឹងចេះចាយកលចំណាន
ទាំងមានសន្តានស្នេហាជាតិ

យូរ-អ៊ុន

ម៉ាថេងទឹងណាស់ ស្រែកជេរអ៊ុយកុយថា អាមនុស្សកំឡៅធ្វើឲ្យខូចការអញអស់ទៅ ទោះបើខ្លួនអញនឹងស្លាប់ អញក៏មិនស្តាយជីវិត តែមកគិតគួរចិត្តថា នឹងរំលាងអាសត្រូវពេជសម្បត្តិចេញ ដើម្បីនឹងជួយទំនុកបំរុងផែនដីឲ្យបានសុខ ក៏មិនសមប្រកបតាមគំនិតគិត ចូឆ្លូក៏ឲ្យយកខ្លួនម៉ាថេង ម៉ាហ៊ុវ នឹងអ៊ុយកុយទៅប្រហារជីវិតក្នុងខណៈនោះ ម៉ាថេងក៏ស្រែកជេរចូឆ្លូមិនដាច់ពីមាត់ទាល់តែពេជ្ឈឃាតចុះដាវប្រហារជីវិតក្ស័យ ៗ ចូឆ្លូក៏និយាយនឹងបៀវគេកថា ខ្លួនអ្នកមានសេចក្តីគាប់ប្រសើរដល់យើងជាច្រើនណាស់ អ្នកចូរប្រាថ្នាចុះ បើចង់បានប្រយោជន៍អ្វី យើងនឹងឲ្យបានតាមចិត្ត ៗ បៀវគេកឆ្លើយថា ខ្ញុំបាទនឹងបានស្រឡាញ់យស

បណ្តាសក្តិក៏ទេ គឺវេលានេះ ខ្ញុំបាទសុំឲ្យបានតែខ្លួននាងលីស៊ុនអៀន ដែលជាប្រពន្ធចុងអ៊ុយកុយយកមកធ្វើជាភរិយាខ្ញុំបាទ ។

ចូឆូជា នាងលីស៊ុនអៀននោះ ជាមនុស្សអាក្រក់មិនដឹង មិនស្គាល់គុណាស្រ័យនៃស្វាមី ដែលជាបងថ្លៃអ្នកឯង ១ ទឹងស្លាប់ក៏ពីព្រោះមាត់វា ដែលអ្នកនឹងយកវាមកចិញ្ចឹមធ្វើជាភរិយានោះមិនគួរទេ ។ បៀវតេកបាន ស្ដាប់ដូច្នោះហើយ ក៏ទឹកបារម្ភខ្លាចក្រែងចូឆូនឹងសម្លាប់នាងលីស៊ុនអៀន អសារបង់ ទើបថ្លែងពតិទាសេចក្តីដែលខ្លួននឹងនាងនោះ បានលបលាក់លួចសហាយនឹងគ្នាពីថ្ងៃមុនមក ហើយវះគិតប្រើគិទតព្រាងទឹងប្រហារជីវិតអ៊ុយកុយជាបងថ្លៃចេញ ព្រោះចិត្តស្នេហ៍ស្រឡាញ់ស្រីម្នាក់នេះ ឲ្យចូឆូស្ដាប់គ្រប់ប្រការ ។

ចូឆូបានឮដូច្នោះ ក៏ខឹងក្រេវក្រោធស្រែកថា ខ្លួនឯងជាប្អូនភរិយាគេ ហ៊ានលបលួចសហាយស្មន់នឹងប្រពន្ធចុងរបស់បងថ្លៃ ហើយឡើងគិតសំលាប់បំផ្លាញជីវិតប្ដីគេទៀត ឯងនេះពេញជាមនុស្សពាលមៀកចិត្តអាក្រក់ពន់ប្រមាណ គ្មានសេចក្តីសត្យកតញ្ញូសោះ វេលានេះ បើយើងមិនយកទោសឯង មនុស្សទាំងពួងយកតម្រាប់តាម ខូចច្បាប់ទម្លាប់ស្រុកអស់ ។ ចូឆូជាតែប៉ុណ្ណោះ ក៏ប្រើពាហានឲ្យចាប់បៀវតេក នឹងស្នេហ៍បក្សពួកបងប្អូនបៀវតេកទៅសម្លាប់ព្រមគ្នា ជាមួយនឹងបុត្រភរិយាបក្សពួកអ៊ុយកុយ ហើយចូឆូឲ្យប្រកាសបញ្ចុះបញ្ចូល ពួកទាហានម៉ាថេងថា

ម៉ាថេងនឹងម៉ាហ៊ុវប្រព្រឹត្តអំពើខុស គឺមានគំនិតប្រទូសរ៉ាយនឹងមហាឧប-រាជ ។ ឲ្យសម្លាប់ចេញហើយ អ្នកពល់គ្នាជាសេនាទាហាន មិនបានដឹងឃើញចូលរួមគំនិតជាមួយគ្នា មិនត្រូវមានទោសអ្វីទេ បើនឹងស្ម័គ្រចូលចិត្តទៅធ្វើរាជការជាមួយនឹងមហាឧបរាជក៏ឲ្យចូលទៅចុះ មហាឧបរាជនឹងដប់លៀងតាមសមគួរ ហើយមានសំបុត្រទៅកាន់ទីទាំងពួងថាម៉ាថេងប្រែចិត្តក្បត់ផែនដី រាជការឲ្យចាប់ខ្លួនសម្លាប់ទាំងពុកនឹងកូនអស់ហើយនៅសល់តែម៉ាតាយជាក្មួយ ឲ្យផងទាំងពួងស៊ើបចាប់ខ្លួនម៉ាតាយបញ្ជូនទៅស្រុកក្រុងឲ្យបាន នឹងឲ្យបំណាច់រង្វាន់ ។

ខណៈនោះ ម៉ាតាយបាននាំទាហាន ១ ពាន់ លើកជាទ័ពមកជួយម៉ាថេង លុះលើកមកដល់ក្រុងហ៊ូតោ ប្រទះនឹងពួកទាហានម៉ាថេងដែលរត់បែកខ្ញែកទៅជួបកណ្ដាលផ្លូវ ។ ទាហានទាំងនោះក៏ពណ៌នារឿងរ៉ាវឲ្យស្ដាប់ ។ ម៉ាតាយឮដូច្នោះ ក៏ភ័យតក់ស្លុតក្នុងចិត្ត ទើបគិតក្លែងខ្លួនជាកូនឈ្មួញអ្នកលក់ទំនិញតែគេចចេញត្រឡប់ទៅស្រុក ។

## សាមកុកខ្សែ ៤៩

តាំងពីបួធូសម្លាប់ម៉ាថេង ហើយគិតលើកទ័ពទៅវាយស្រុកតាំងតាំង រហូតដល់បួធូច្បាំងនឹងម៉ាឈៀវមានជ័យជំនះ ចាប់បានទាហានម៉ាឈៀវមកជាឈ្លើយ ។

---

ឯបួធូលុះសម្លាប់ម៉ាថេងបានហើយ ក៏រិះគិតនឹងលើកកងទ័ពទៅច្បាំងនឹងស៊ុនគួនហើយនឹងទៀតភី ទទួលបំរើទាហានដែលទៅស៊ើបស្ដាប់

ការកជការនោះ ត្រឡប់មកប្រាប់ចូចូថា ឡៅពីរៀបចាត់ចែងទ័ពនឹង លើកទៅច្បាំងយកស្រុកសែឈួន ។

ចូចូឮដូច្នោះ ក៏ទឹកភ័យ ទុះម្ភណាស់ ទើបនិយាយថា បើប្រសិនឡៅពីទៅវាយបានស្រុកសែឈួនមែនហើយ ក៏គង់នឹងប្រមូលពលទា.ហាននឹងស្បៀងអាហារបានយ៉ាងច្រើន បើយើងលើកទ័ពទៅតនឹងឡៅ.ពីវេលាណា ឃើញថាជាការលំបាក ៗ ក៏នគុយទីប្រឹក្សាឆ្លើយតបនឹងចូចូថា សេចក្ដីនេះ សូមកុំឲ្យមហាឧបរាជព្រួយឡើយ ខ្ញុំបាទនឹងរិះគិតជាកលឧបាយមួយយ៉ាង ឲ្យស៊ុនគួននឹងឡៅពីត្រឡប់ខុសចិត្តគ្នាទៅវិញ មិនឲ្យរួមគំនិតជាមួយគ្នាបាន ដើម្បីនឹងឲ្យស្រុកទាំងពីរនេះ ជាសិទ្ធិទៅក្នុងកណ្ដាប់ដៃលោកតទៅ ៗ

ចូចូបានឮដូច្នោះ ក៏មានអំណរណាស់ ត្រឡប់សួរថាតម្រិះអ្នកនឹងគិតកលឧបាយនោះប្រការម្ដេច ? ៗ ក៏នគុយឆ្លើយថាសព្វថ្ងៃនេះឡៅពីនឹងស៊ុនគួនជាបងប្អូនថ្លៃនឹងគ្នា ចិត្តនឹងគំនិតគិតរួមជាមួយគ្នា លោកនឹងរំលាងចេញដោយកម្រណាស់ គ្រានេះឡៅពីគិតនឹងលើកទ័ពទៅវាយស្រុកសែឈួនហើយ សូមឲ្យលោកកេណ្ឌកងទ័ពទៅក្លាប់គ្នានឹងទៀវលៀវទៅស្រុកហ័បបាំ លើកទៅវាយស្រុកកាំងតាំង ខាងស៊ុនគួនគង់នឹងឲ្យទៅសុំកងទ័ពឡៅពីមកជួយ ឯឡៅពីកំពុងរៀបចំដំណើរទ័ពទៅវាយយកស្រុកសែឈួន នោះនឹងមិនព្រមឲ្យកងទ័ពទៅជួយទេ យើងគង់

បានស្រុកកាំងតាំងដោយងាយ បើស្រុកកាំងតាំងបានមកយើងហើយ យើងត្រូវលើកកងទ័ពត្រឡប់ទៅវាយយកស្រុកកេងជីវ នឹងស្រុកសៃឈួនទៀត ផែនដីយើងក៏នឹងបានរាបទាបជាសុខតទៅ ។

ចូឆូយល់ឃើញត្រូវ ទើបនិយាយថា គល់ឧបាយយ៉ាងនេះល្អណាស់ ត្រូវនឹងគំនិតដែលយើងគិតទុកគ្រប់ប្រការ ។ ខណៈនោះ ចូឆូក៏ឲ្យកេណ្ឌកងពលបាន ១ សែននាក់ ហើយឲ្យលើកទៅស្រុកហ័បប៉ា រួចបង្គាប់ថា ឲ្យទៀវលៀវដែលនៅរក្សាស្រុកនោះ ចាត់ចែងស្បៀងអា-ហារលើកមកបញ្ចូលគ្នា ទៅវាយយកស្រុកកាំងតាំង យើងនឹងលើកទាហានបញ្ជូនទៅជួយទៀត នាយទ័ពនាយកងក៏លាចូឆូលើកទ័ពទៅដល់ស្រុកហ័បប៉ា ក៏ចូលទៅប្រាប់ទៀវលៀវតាមបណ្តាំដែលចូឆូបង្គាប់មកនោះគ្រប់ប្រការ ។ ទៀវលៀវក៏ចាត់ចែងកេណ្ឌទាហាននឹងស្បៀងអាហារត្រៀមទុកជាស្រេច ដើម្បីនឹងលើកទៅវាយស្រុកកាំងតាំង ។

ខណៈនោះ បំរើសេះក៏នាំយកសេចក្តីទៅប្រាប់ស៊ុនគួន ។ ក៏ឲ្យហៅប្រជុំទីប្រឹក្សាមកពិគ្រោះការរាជការថា ឥឡូវ ចូឆូ ប្រើ ទៀវ-លៀវ ឲ្យធ្វើជាមេកងទ័ពនឹងលើកមកវាយយកស្រុកយើង អ្នកកល់គ្នានឹងរិះគិតការពារប្រការម្តេច ? ។ ទៀវចៀវឆ្លើយថា សូមឲ្យលោកប្រើឡោសុកធ្វើសំបុត្រទៅឯកេងជីវ សុំកងទ័ពឡៅពីមកជួយ ឡៅពីជាប្អូនថ្លៃលោកស្រាប់ហើយ ឡោសុក ក៏មានគុណនឹងឡៅពីដែរ មុខជាឡៅពី

មិនបង្អង់ខាន គង់នឹងលើកទ័ពមកជួយធ្វើការសឹក ។ ស៊ុនគួន ឮដូច្នោះ ក៏យល់ឃើញត្រូវ ទើបប្រើបំរើឲ្យទៅប្រាប់ឡោសុក ឯស្រុកឆសង់គុន ឲ្យឡោសុកធ្វើសំបុត្រទៅដល់ឡៅតី តាមដំណើរ លុះឡៅតីបានទទួលសំបុត្រដឹងសេចក្តី ក៏ឲ្យទៅអញ្ជើញខុងបេងពីស្រុកឡាំគុនមក ហើយយកសំបុត្រឡោសុកបង្ហាញឲ្យខុងបេងមើល ។

ខណៈនោះ ខុងបេងក៏និយាយនឹងឡៅតីថា លោកកុំព្រួយចិត្តឡើយ ខ្ញុំនឹងគិតកលឧបាយម្យ៉ាង កុំឲ្យទាហានស្រុកយើងលើកទៅជួយស៊ុនគួន ឯទាហានស៊ុនគួនក៏កុំឲ្យលើកទៅច្បាំងនឹងចូចូ ស្រុកកាំងក៏ឲ្យបាននៅជាសុខ មិនឲ្យចូចូមើលងាយយើងបាន ហើយខុងបេងក៏បង្គាប់អ្នកកាន់សំបុត្រនោះថា អ្នកឯងចូរវិលត្រឡប់ទៅប្រាប់ ស៊ុនគួន ចៅហ្វាយអ្នកឯងចុះថា កុំឲ្យព្រួយចិត្តឡើយ ឲ្យស៊ុនគួននឹងអ្នកស្រុកកាំងតាំងដេកធ្មេចភ្នែកឲ្យលុកជាសុខសំកនទៅចុះ បើប្រសិនជាកងទ័ពចូចូលើកមកដល់វេលាណា ភ្នាក់ងារខ្ញុំយើងនឹងចេញជាធុរៈឯង ។ បំរើស្តាប់ឮដូច្នោះ ក៏លាឡៅតី ខុងបេងត្រឡប់ទៅស្រុកស៊ុនគួនឯស្រុកកាំងតាំងវិញ ។

ក្រោយនោះ ឡៅតីក៏និយាយប្រាប់ខុងបេងថា ឥឡូវឮថាចូចូកេណ្ឌកងទ័ពមកបញ្ចូលគ្នាជាពីរមណ្ឌល ចំនួនពលដល់ ៥០ ម៉ឺន នឹងលើកមកវាយស្រុកកាំងតាំង ដែលលោកប្រុងនឹងជួយស៊ុនគួននោះ កលឧបាយរបស់លោកនឹងធ្វើដូចម្តេច ។ ខុងបេងឆ្លើយថា កាលពីដើមស្រុកដែល

នៅក្រោមបង្គាប់ចូឆូនោះ  ក៏ទឹកញាញើតតែថ្ងៃដទាហានស្រុកសៃលៀវ ឥឡូវចូឆូសម្លាប់ម៉ាថេងទៅហើយ នៅតែម៉ាឈៀវជាកូនកំពុងទាហាននៅរក្សា ស្រុកសៃលៀង  គង់ទឹងចិត្តគិតសងសឹកចូឆូវិញជាដរាប  សូមឲ្យលោក មានសំបុត្រទៅដល់ម៉ាឈៀវ  ឲ្យស្រូតរូតលើកទាហានទៅវាយស្រុកហ៊ូ តោចុះ មុខជាចូឆូនឹងលើកទ័ពត្រឡប់ទៅវិញ ។ ឡៅពីស្តាប់យល់ត្រូវ ចិត្តក៏គិតធ្វើសំបុត្រតាមសំដីខុងបេងនិយាយ  ហើយឲ្យបំរើដែលទុកចិត្ត កាន់សំបុត្រនោះស្រូតរូតទៅឲ្យម៉ាឈៀវ ឯស្រុកសៃលៀង ។

ឯម៉ាឈៀវនោះ លុះដល់ពេលយប់ក្នុងថ្ងៃនោះក៏ដេកលក់ស្និទ្ធដល់ ពេលអធ្រាត្រសុបិននិមិត្តឃើញថា «មានខ្លាមួយហ្វូងចូលមកព័ទ្ធខាំខ្លួន» លុះភ្ញាក់ឡើងក៏ភ័យខ្លាចណាស់ ទើបហៅទីប្រឹក្សាទាំងពួងមកជួយទំនាយ សប្តិ ៗ ប៉ាំងតេកឆ្លើយជំរាបថា លក្ខណៈដែលយល់សប្តិនេះកាចណាស់ បិតាលោកដែលលើកទ័ពចូលទៅស្រុកហ៊ូតោនោះ មុខជាមានសេចក្តីភ័យ អន្តរាយប្រាកដណាស់  លុះនិយាយមិនទាន់ផុតមាត់  ទទួលឃើញម៉ា-តាយមកដល់ ថ្លែងពតិមានឲ្យស្តាប់គ្រប់ប្រការហើយថា  សូម្បីតែខ្លួនខ្ញុំ នេះ ចូឆូក៏ប្រុងនឹងសម្លាប់ចោលដែរ  តែដោយសារខ្ញុំក្លែងខ្លួនបន្ទុំធ្វើជា កូនឈ្នួលអ្នកជំនួញរះរត់មកទាំងយប់-ថ្ងៃបានជារួចខ្លួន ។

ម៉ាឈៀវឮដូច្នោះ ក៏ទួញយំដួលសន្លប់មួយរំពេច ។ ទាហានទាំងពួងឃើញដូច្នោះ ក៏នាំគ្នាគ្រាហ៍លើកម៉ាឈៀវឡើង ៗ លុះដឹងខ្លួនហើយ

មាំឈៀវនឹកខឹងក្ដៅលើសកម្លាំង តាំងតែខាំមាត់ហើយថា អញនឹងសងសឹកអាចូចូឲ្យបានវិញ ។ ខណៈនោះ ទទួលបំរើឡៀវពីកាន់សំបុត្រចូលមកដល់ ហុចឲ្យទៅមាំឈៀវ មាំឈៀវទទួលយកហើយ មើលឃើញសេចក្ដីថា សំបុត្រឡៀវពីឲ្យពរមកដល់មាំឈៀវ ព្រោះចូចូទីមហាទបកដនៅស្រុកហ៊ូតោ គិតធ្វើការកោក្រក់ផ្សេងៗ ទាល់តែព្រះចៅហៀនតេបានសេចក្ដីក្ដៅក្រហាយខ្លាំងអំពើទាំងនេះអ្នកក៏គង់នឹងយល់ច្បាស់ណាស់ហើយមួយទៀត គឺកាលព្រះចៅហៀនតេ ទ្រង់ព្រះអក្សរដោយព្រះលោហិតឲ្យតង់ស៊ិននោះ បិតាអ្នកនឹងយើងក៏បានចុះឈ្មោះព្រមគំនិតគ្នាថា នឹងធ្វើការកំចាត់ចូចូចេញឲ្យបាន ឥឡូវយើងដឹងច្បាស់ថា បិតាអ្នកធ្វើការឲ្យធ្លាស់ចាញ់ឧបាយកលចូចូ លុះដល់ជីវិតអន្តរាយ យើងក៏នឹកស្ដាយតូចចិត្តណាស់ ខ្ញុំអ្នកក៏ជាជាតិទាហាន គង់នឹងមានចិត្តនោះឈឺក្ដៅ ត្រូវសងសឹកឪពុកវិញ បើអ្នកនឹងលើកគង់ទ័ពទៅវាយយកស្រុកហ៊ូតោវេលាណា យើងនឹងលើកទ័ពពីខាងស្រុកកេងជីវខាងនេះទៅជួយព្រួតគ្នាកំចាត់ចូចូឲ្យបានវិញ ដើម្បីនឹងជួយបំពេញព្រះរាជហឫទ័យ នៃព្រះចៅហៀនតេឲ្យបានសេចក្ដីសុខ ។

មាំឈៀវមើលចប់សេចក្ដីសំបុត្រនោះ ក៏ឲ្យនឹកពោរពេញគន់ចិត្តគិតក្ដៅនឹងវាហង លុះរំសាយសេចក្ដីសោកវេលាណា ក៏សរសេរជាសារតបទៅឡៀវពីវិញ ហើយមាំឈៀវក៏តាំងចាត់ចែងកេណ្ឌពលទាហាន

ដើម្បីទឹងលើកទៅកាយស្រុកហ៊្វូគោ ទទួលមានបំរើមកដំកបថា ហ៍នស៊ុយឲ្យអញ្ជើញម៉ាឈៀវទៅជួប ។ ម៉ាឈៀវក៏ចូលទៅជួបទឹងហ៍នហ៊ុយ ។ ហ៍នស៊ុយនិយាយប្រាប់ម៉ាឈៀវថា ចូឆូឲ្យសំបុត្រមកដល់យើងថា ឲ្យចាប់ទៅទាំងពីរនាក់បញ្ជូនចូលទៅក្រុងហ៊្វូគោ ចូចូ នឹងតាំងយើងឲ្យធ្វើជាចៅហ្វាយស្រុកសែលៀង ។

ម៉ាឈៀវឮដូច្នោះ ក៏ក្រាបចុះគំនាប់ហើយនិយាយដំកបថា លោកនឹងបិតាខ្ញុំបាទ គឺជាមិត្រសំឡាញ់នឹងគ្នាស្និទ្ធស្នាលណាស់ ឥឡូវចូចូសម្លាប់បិតាខ្ញុំបាទទៅហើយ រឿងទាំងនេះសូមឲ្យលោកឈ្វេងយល់ទៅដល់បិតាខ្ញុំបាទផងចុះ ។ ហ៍នស៊ុយឆ្លើយថា បិតាចៅនឹងយើងបានស្រឡាញ់រាប់អានគ្នាជាប្រាកដណាស់ ដែលចូចូសម្លាប់បិតាចៅទៅហើយនោះ យើងក៏មានចិត្តទោមនស្សពន់ប្រមាណ បើចៅនឹងលើកទ័ពទៅកាយស្រុកហ៊្វូគោសងសឹកចូចូគ្រាណា យើងក៏ត្រូវទៅជាមួយផង ។

ម៉ាឈៀវឮដូច្នោះ ក៏គោរពដោយសេចក្តីត្រេកអរក្រៃលែងណាស់, ហ៍នស៊ុយក៏ឲ្យយកខ្លួនទាហានចូចូ ដែលកាន់សំបុត្រទៅនោះទៅប្រហារជីវិតនៅមុខម៉ាឈៀវ ហើយម៉ាឈៀវនឹងហ៍នស៊ុយក៏រៀបចាត់ចែងទាហានចាត់ឲ្យហៅឈ្មួន ធៀងិន លីខាំ ទៀវហេង លៀងហ៊ីង សេងងី ថែអនអៀវឈើវ ទាំង ៨ នាយនេះ នាំទាហានទៅជាមួយនឹងហ៍នស៊ុយមួយកង, លុះបានឫកពារពេលាល្អ ម៉ាឈៀវនឹងហ៍នស៊ុយក៏លើកទ័ពចេញទៅ

ក្រុងហ៊ូតោ ។

ខណៈកាលលើកទ័ពទៅដល់គយស្រុកទៀងអ័ន ចុងហ៊ីវ ចៅហ្វាយស្រុក ក៏ឲ្យបំរើសេះកាន់សំបុត្រប្តឹងចូលទៅដល់ចូឆូ ហើយលើកទាហានចេញមកកំពង់ទាំងទ័ព លុះម៉ាតាយលើកទាហាន ៥ ពាន់ជាកងមុខទៅដល់ប្រទល់គ្នា ចុងហ៊ីវក៏បំផាយសេះចូលតយុទ្ធនឹងម៉ាតាយបាន ៦ ភ្លេង ចុង-ហ៊ីវទ្រទឹងម៉ាតាយពុំបាន ក៏ញាក់បំផាយសេះនាំទាហានរត់ចូលទៅក្នុងស្រុកវិញ បង្គាប់ទាហានឲ្យត្រួតត្រាយាមល្បាតតាមសើនបន្ទាយជុំវិញមាំមួន ៗ ម៉ាឈៀវហ៊ានស៊ុយលើកពលទៅដល់ក៏ដេញឲ្យចូលព័ទ្ធជុំវិញស្រុកទៀងអ័នគំរប់ ១០ ថ្ងៃ គ្មានឃើញឈ្មោះណាចេញមកតយុទ្ធគ្នាសោះ លុះលើកទាហានសន្ធុញចូលទៅវាយទំលាយ ក៏ឃើញចុងហ៊ីវចាត់ការយាមល្បាតជាមាំមួនណាស់ ។

ប៉ាំងតេក ក៏និយាយនឹងម៉ាឈៀវថា ស្រុកទៀងអ័ននេះជាមណ្ឌលធំ កំពែងបន្ទាយជុំវិញក៏មាំមួន ព្រោះជាទីក្រុងដែលព្រះចៅហៀនតេបានរៀបចំទុកមក, យើងនឹងមកព័ទ្ធទុកស្ងៀមដូច្នេះ ក៏មិនជាការមានប្រ. យោជន៍ នាំឲ្យតែព្រួយនឿយទាហាន បើប្រសិនជាចូឆូលើកកងទ័ពមកជួយពាន់ បានវាយខ្ទប់ពីក្រៅមួយជាន់ទៀត យើងក៏គង់នឹងលំបាកជួសការ ខ្ញុំបាទនឹងគិតកលឧបាយមួយឲ្យបានស្រុកទៀងអ័នដោយងាយ ព្រោះពេលនេះ ប្រជារាស្ត្រនៅស្រុកទៀងអ័នកំពុងដាច់ស្បៀងអាហារ

ណាស់ សូមឲ្យលោកបន្ថយរំសាយទ័ពទៅបង្អាប់ឲ្យឆ្ងាយពីស្រុកដើម្បី
នឹងឲ្យអ្នកស្រុកនេះចេញមករកស្បៀងអាហារ ខ្ញុំបាទនឹងបន្ទំចូលទៅក្នុង
ស្រុកឲ្យបាន ហើយនឹងដុតភ្លើងជាសញ្ញាចាំបើកទ្វារទទួលលោកឲ្យ
ចូលទៅ ៗ ម៉ាឈៀវឮដូច្នោះក៏ពេញចិត្តណាស់ លុះដល់ពេលយប់ ក៏
ឲ្យយកខ្ទង់លើកឡើងប្រាប់ទាហានឲ្យសំគាល់ថា ត្រូវថយទ័ពចេញទៅ
បោះនៅពីចម្ងាយវិញ តាមគំនិតប៉ាំងតេក ៗ

វេលានោះ បណ្ដាមនុស្សម្នាក្នុងស្រុកទៀនអ័នក៏សឹងតែដាច់ផុត
ស្បៀងអាហារ ដាច់ទាំងទឹកនឹងខ្សត់ភ្លើងខ្លាំងណាស់ ព្រោះក្នុងទាទី
ស្រុកទៀនអ័ននោះជាទីស្ងួតក្រៀម ទោះបីជីកអណ្ដូងឲ្យជ្រៅយ៉ាងណា
ក៏គ្មានទឹកចេញសោះ ប៉ុន្តែនៅទុកចិត្តថា ចូចូគង់នឹងលើកទ័ពមកជួយ
បានជាព្រងើយកន្ដើយគ្រាន់តែការពារក្នុង លុះព្រឹកព្រហាមឃើញកង
ទ័ពម៉ាឈៀវលើកថយចេញទៅវិញក៏មានសេចក្ដីត្រេកអរពេលគ្នា នៅតែ
ចុងហ៊ុវម្នាក់ មានសេចក្ដីសង្ស័យក្រែងជាកលសឹក ទើបប្រើបាវឲ្យចេញ
ទៅលបមើល ក៏មិនឃើញមានកងទ័ពតាំងជាក្បួន ចុងហ៊ុវក៏ឲ្យបើកទ្វារ
ស្រុកបញ្ចេញមនុស្សម្នាក្នុងស្រុកនោះឲ្យទៅរកស្បៀងអាហារប្រហែល៤
ថ្ងៃ ៗ ខណៈនោះ ប៉ាំងតេក នឹងទាហានដែលស្និទ្ធទុកចិត្ត ក៏បន្ទំជាមនុស្ស
កែខ្សត់ចូលទៅក្នុងស្រុកទៀនអ័ន កាលបើម៉ាឈៀវបានដឹងហើយ ក៏
ប្រមូលពលលើកត្រឡប់ទៅព័ទ្ធស្រុកនោះជុំវិញដូចថ្ងៃមុន, ចុងហ៊ុវឃើញ

ដូច្នោះ ក៏បង្គាប់ឲ្យខំបិទទ្វារស្រុកជាប់មាំមួន ហើយចាត់ការយាម-ល្បាតទាំងថ្ងៃ-យប់ ។

ឯបាំងគេក ដែលបានចូលទៅនៅក្នុងកំផែង លុះដល់ពេលយាម ៣ យប់ ក៏យកភ្លើងអុជឲ្យឆេះឡើងក្នុងស្រុកខាងទិសឯលិច ។ ឈ្មោះចុងជិនជាប្អូនចុងហ៊ុំ ជាអ្នកនៅត្រួតទាហានខាងទិសនោះ លុះឃើញភ្លើងឆេះសន្ធោឡើង ក៏ភ័យខ្លាំងណាស់ ឡើងសេះបំបាយចូលទៅទីងលត់ភ្លើង ។ បាំងគេកក្រឡេកឃើញ ក៏បរសេះចេញទៅស្ទាក់ពីមុខចុងជិនហើយស្រែកថា យើងឈ្មោះបាំងគេក ចូលមកនៅក្នុងស្រុកនេះហើយ អ្នកឯងដឹងឬទេ ? ។ ចុងជិនទើបតែបានស្ដាប់មិនទាន់ទទួលអាវុធ បាំងគេកក៏ដកដាវកាប់ចុងជិនធ្លាក់ពីលើសេះស្លាប់ ។ ឯពួកទាហានដែលយាមល្បាតទាំងប៉ុន្មាន ក៏សឹងតែបាក់បែកខ្ចាត់ខ្ចាយទៅទាំងអស់ ។ បាំងគេក ក៏កាប់សោបើកទ្វារស្រុកចេញទៅទទួលម៉ាឈៀវឲ្យចូលទៅក្នុងស្រុក ។

ឯចុងហ៊ុំ ដែលនាំទាហានទៅនៅរក្សាទ្វារខាងទិសឯកើតនោះ លុះឃើញភ្លើងឆេះសន្ធោឡើង ឃើញទាហានបែកខ្ញែកគ្នាពាក់ពពូនដូច្នោះ ក៏ដឹងថា ម៉ាឈៀវនឹងហ៊ានស៊ុយចូលស្រុកបាន មានសេចក្ដីភ័យខ្លាំងណាស់ នាំទាហានរត់ចេញទៅតាំងនៅទីគុងគួន ហើយប្រើបរស្រុករួតទៅថ្ងឹងចូន ។ ឯម៉ាឈៀវនឹងហ៊ានស៊ុយ កាលបើយកបានស្រុក

ទៀនអ័នហើយក៏ចែកបំណាច់ទាហានតាំងពួនតមសមគួរ ហើយក៏ស្រុត
លើកទ័ពតាមចុងហ៊ុវទៅឯបន្ទាយគុងគួន ។

ខណៈកាល ចូឆូគិតនឹងលើកទ័ពទៅវាយយកស្រុកកាំងតាំងនោះ លុះឮដំណឹងថាម៉ាឈៀវលើកកងទ័ពមកវាយយកបានស្រុកទៀនអ័នដូច្នោះ ក៏ចាត់ចែងនឹងលើកទ័ពទៅជួយ ទទួលមានបំរើចូលទៅប្តឹងថា ម៉ាឈៀវនឹងហ៊ានស៊ុយវាយយកបានស្រុកទៀនអ័នហើយ នឹងលើកកងទ័ពមកវាយយកស្រុកហ៊ូគោទៀត ឯចុងហ៊ុវទៅហ្វាយស្រុកទៀនអ័នក៏ចែកទ័ពត្រឡប់ទៅនៅគយគុងគួន ។

ចូឆូក៏និយាយថា ពីដើមយើងគិតនឹងលើកទ័ពលួងទៅវាយយកស្រុកកាំងតាំង ឥឡូវម៉ាឈៀវធ្វើបង្អាប់លើកទ័ពត្រឡប់ប្រុងនឹងមកវាយយកស្រុកយើងដូច្នេះ ត្រូវតែយើងនឹងត្រិះរិះកំចាត់ម៉ាឈៀវចេញជាមុន លុះថាហើយក៏ឲ្យគេហៅខូនទោហងជាប្អូន នឹងស៊ុឡុងមកបង្គាប់ថា ទៅឯងចូលនាំពលទាហានមួយម៉ឺនទៅជួយចុងហ៊ុវ ដើម្បីនឹងការពារគយគុងគួនឲ្យមាំមួន បើឃើញកងទ័ពម៉ាឈៀវលើកមកដល់ ត្រូវឲ្យព្រួតគ្នារក្សាបន្ទាយឲ្យមាំមួន កុំឲ្យអន្តរាយក្នុងរវាង ១០ ថ្ងៃ បើបន្ទាយគុងគួននោះខូចនឹងម៉ាឈៀវក្នុងរវាងនេះ យើងនឹងយកទោសដល់ខ្លួន បើហួស ១០ ថ្ងៃហើយខូចក៏វាហើចុះ ទោហងនឹងស៊ុឡុងក៏ទទួលបង្គាប់ រួចលើកទ័ពចេញទៅបន្ទាយគុងគួន ។

ក្រោយនោះ ទោយ៉ិននិយាយជម្រាបចូឆូថា ទោហង់នេះនៅក្នុងសេចក្ដីណាស់ ចិត្តវាក៏ជាមនុស្សរឹងរូសមិនសូវមានពិគ្រោះហេតុការជាធ្ងន់ឬស្រាល ដែលលោកនឹងប្រើឲ្យទៅរក្សាបន្ទាយតុងគួននោះ ខ្ញុំបាទឃើញថានឹងមានសេចក្ដីអន្តរាយជាប្រាកដ ចូឆូយល់ឃើញត្រូវផង ទើបចាត់ប្រើទោយ៉ិនឲ្យលើកទាហានតាមទោហង់ទៅហើយចូឆូក៏លើកទ័ពធំតាមទៅជាខាងក្រោយ ។

ឯម៉ាឈៀវនោះ លុះលើកកងទ័ពទៅដល់ទល់នឹងបន្ទាយតុងគួន ក៏ឲ្យរេហ៍ពលរាយគ្នាព័ទ្ធជុំវិញបន្ទាយ នោះទោហង់នឹងស៊ីឡុងចុងហ៊ុំក៏ចាត់ទាហានឲ្យយាមល្បាតតាមសើន ទីងទារបន្ទាយរាយព័ទ្ធជុំវិញ មិនបានចេញតតាំងច្បាំងគ្នា ឯម៉ាឈៀវក៏ឲ្យទាហានចូលទៅស្រែកជេរប្រមាថចូឆូជាពាក្យអាស្រូវកោសផ្សេងៗ ហើយរំលើកដៀលដល់ពូជត្រកូល ទោហង់ឮដូច្នោះក៏ខឹងខ្លាំងណាស់ គិតនឹងចេញទៅតយុទ្ធនឹងម៉ាឈៀវ ស៊ីឡុងក៏ហាមឃាត់ថា ដែលម៉ាឈៀវប្រើទាហានឲ្យមកជេរប្រមាថយ៉ាំងនេះ ប្រាថ្នាឲ្យយើងខឹងចិត្តឈឺក្ដៅ ត្រូវតែអ្នកខំអត់សង្កត់ចិត្តទៅសិនចុះ ពោះបើយ៉ាងណាក៏កុំត្រូវចេញទៅតយុទ្ធគ្នាឡើយ ត្រូវតែការង់ចង្អង់ចាំទំរាំទ័ពធំលើកមកដល់ មហាឧបរាជនឹងគិតដោយកលឧបាយប្រការម្ដេចសឹមយើងធ្វើតាម ទោហង់ក៏ឃើញត្រូវផង ។

ឯម៉ាឈៀវ ក៏ចាត់ទាហានឲ្យផ្លាស់ប្ដូរគ្នាចូលទៅស្រែកជេរចូឆូតាំង

យប់ថ្ងៃមិនដាច់ ចោបានខឹងខ្លាំងណាស់ ក៏បរពលចេញមកច្បាំង ស៊ីឡុងហាមឃាត់ថា មហាឧបាកដបង្គាប់ផ្តាំជាដាច់ខាតថា ឲ្យយើងគិតរក្សាតែបន្ទាយកុំឲ្យអន្តរាយក្នុងរវាង ១០ ថ្ងៃ ឥឡូវបាន ៩ ថ្ងៃហើយ ត្រូវតែអ្នកទំអត់ធន់ឲ្យបានគ្រប់ ១០ ថ្ងៃចុះ ចោហានស្តាប់ហើយនឹកបារម្ភចិត្តស៊ីឡុងក៏នៅស្ងៀម ស៊ីឡុងបំរុងចាត់ចែងស្បៀងអាហារនឹងចែកទាហាន កាលស៊ីឡុងទៅហើយ ចោហានក៏ឡើងលើសើមបន្ទាយ ឃើញទាហានមាំឈៀវនៅកយគ្នា ខ្លះដេកខ្លះអង្គុយមិនមែនជាក្បួនទ័ព ចោហានក៏នាំទាហាន ៣ ពាន់ បើកទ្វារចេញទៅខាងក្រៅ ទាហានមាំឈៀវដែលនៅកយគ្នានោះក៏រត់ប្រាត់ប្រាយ ចោហានក៏បំផាយសេះដេញតាមទៅ ស៊ីឡុងដឹងដូច្នោះក៏ភ័យខ្លាំងណាស់ នាំចុងហ៊ុលើកទាហានតាមចោហានចេញទៅ លុះទៅទាន់ហើយក៏ស្រែកហៅឲ្យចោហានឈប់ត្រឡប់វិញ ទទួលមាំឈៀវលើកទាហានចេញមកស្ទាក់ពីមុខ ចោហានក៏បំផាយសេះវេះគេចនឹងចូលបន្ទាយ ទទួលប្រទះនឹងមាំតាយលើកទាហានស្ទាក់ពីក្រោយ ហើយព័ទ្ធជុំវិញខ្លួនចោហាននិងស៊ីឡុង។ ឃើញលើសកម្លាំងណាស់នឹងទ្រាំតពុំឈ្នះ ក៏ទំលាយចោលបន្ទាយតុងគួន នាំទាហានរត់យកតែខ្លួនចេញទៅ បាំងតេកក៏បំផ្ទាយសេះស្ទុះតាមទៅដល់តែផុតកាតបន្ទាយតុងគួន ប្រទះនឹងចោឃិនលើកទ័ពមកជួយចោហានស៊ីឡុង មាំឈៀវឃើញដូច្នោះ ក៏បរពលចូលទៅជួយបាំងតេកហើយត្រឡប់នាំ

យកខ្លួនបាំងគេគេចចូលទៅនៅក្នុងបន្ទាយគុងគួន ។

ខណៈនោះចៅហង ស៊ុឡុងនឹងចៅយ៉ិន ចុងហ៊ុវ ក៏នាំទាហានលើកត្រឡប់ទៅក្រោយអស់រង ១ ថ្ងៃ ទទួលប្រទះនឹងកងទ័ពចូចូ ក៏សួរសាកយកសេចក្តីដល់ចៅហងថា កាលយើងចាត់ប្រើខ្លួនឲ្យលើកទ័ពមកនោះ យើងក៏បានផ្តាំកំជាប់ទុកថា ឲ្យខំតាំងរក្សាបន្ទាយគុងគួនទុកឲ្យមាំមួនកុំឲ្យផ្លាស់ការណ៍ក្នុងពេល ១០ ថ្ងៃ ហេតុអ្វីក៏ខ្លួនរត់ចោលបន្ទាយបណ្តោយឲ្យសត្រូវយកបាន ចៅហងឆ្លើយថា កាលខ្ញុំបាទទៅនៅរក្សាបន្ទាយនោះ ក៏បានចាត់ការប្រុងប្រៀបប្រយ័ត្នឲ្យយាមល្បាតលាតប្រវែងមិនដែលប្រមាទឲ្យឃ្លៀងឃ្លាតពីប្រកាសមហាឧបរាជសោះ តែព្រោះម៉ា-ឈៀវឲ្យទាហានមកស្រែកជេររំលឹកដល់ត្រកូលមហាឧបរាជជារាល់ពេលទាំងយប់ថ្ងៃ ខ្ញុំបាទក៏នឹកខឹងណាស់ ខំមានះអត់សង្កត់ចិត្ត តែទ្រាំអត់ពុំបាន ទើបលើកទាហានចេញទៅតច្បាំងគ្នានឹងម៉ាឈៀវ ដែលខ្ញុំបាទមើលងាយប្រមាទឲ្យកើតផ្លាស់ការណ៍យ៉ាងដូច្នេះ ទោសខ្ញុំបាទក៏ត្រូវខុសណាស់ហើយ តាមតែមហាឧបរាជនឹងប្រោសចុះ ។

ចូចូឮដូច្នោះ ក៏ថា ចៅហងនៅក្មេងសេចក្តីខ្លីគំនិត យើងក៏មិនបានទុកចិត្តជាប្រាកដណាស់ ទើបប្រើខ្លួនជាមនុស្សចាស់ឲ្យមកជួយ ដើម្បីនឹងចាំជួយតឿនរំលឹកស្មារតីឲ្យធ្វើការអ្វី ៗ គប្បីឲ្យដឹងខុសនឹងត្រូវ ឥឡូវគួរហើយឬ? ដែលខ្លួនធ្វើឲ្យខូចការរបស់យើងយ៉ាងនេះ ស៊ុឡុងឆ្លើយថា

កាលម៉ាឈៀវប្រើទាហានមកដេរដៀមជាមនោះ តោហានចេះតែប្រឡោត ចឹងប្រុងតែនឹងចេញច្បាំង ខ្ញុំបាទក៏ចេះតែឃាត់ទាំងកំងកជាច្រើនវេលាមក ហើយ កាលតោហានចេញទៅតយុទ្ធនឹងម៉ាឈៀវនោះ ទទួលខ្ញុំបាទមិននៅជិត ចេញទៅពិនិត្យចែកស្បៀងអាហារឲ្យបណ្ដាពួកទាហាន លុះដឹងថា តោហានចេញទៅក៏មានចិត្តភិតភ័យណាស់ ក្រែងតោហាននឹងថ្ស់ការណ៍ដល់ម៉ាឈៀវ ខ្ញុំបាទក៏លើកទាហានទន្រ្ទានតាមទៅជួយ កុំឲ្យថ្ស់ការណ៍ក្នុងខណៈនោះ ។

ចូឆូឮដូច្នោះខឹងណាស់ បង្គាប់ឲ្យចាប់ខ្លួនតោហានទៅសម្លាប់ ពួកនាម៉ឺនក្នុងកងទ័ពក៏ប្រញាប់ទៅជម្រាបចូឆូថា វេលានេះយើងកំពុងធ្វើការសង្រ្គាមនឹងម៉ាឈៀវជាសឹកធំ គួរតែរកបុក្សជោគជាមង្គលឧត្តម ដែលមហាឧបការនឹងបង្ខំឲ្យសម្លាប់ប្អូនចេញនោះមិនគួរសោះ សូមឲ្យអនុគ្រោះលើកទោសម្ដងចុះ ចូឆូយល់ឃើញគួរដូច្នោះ ក៏ឲ្យឃុំខ្លួនតោហានទុក ហើយក៏ស្រូតលើកទ័ពតម្រង់ទៅបន្ទាយតុងគួន លុះទៅជិតព្រំបន្ទាយចម្ងាយផ្លូវ ២០ សិន (៨០០ម.) តោយិនក៏ជម្រាបចូឆូថា បើយើងនឹងលើកទាហានពុះពារទំលាយបន្ទាយចូលទៅក្នុងគ្រាឥឡូវនេះ គង់ម៉ា-ឈៀវនឹងប្រើកលឧបាយបញ្ឆោតដោយប្រការម្ដេចក៏យើងពុំអាចដឹង គួរតែបង្អង់កងទ័ពឈប់នៅទីនេះស្ដាប់ការសិន សឹមលើកចូលទៅវាយយកបន្ទាយតុងគួនវិញទើបបានដោយងាយ ចូឆូក៏យល់តាម ទើបឲ្យបញ្ឈប់

ទ័ពតាំងបន្ទាយខ្ជាប់នៅទីនោះៗ អន្ទើ ឲ្យពោយ៉េននៅក្រៅបន្ទាយខាងស្តាំ ឲ្យហែហួនអៀននៅក្រៅបន្ទាយខាងឆ្វេង ឯខ្លួនចូចូនៅបន្ទាយកណ្តាល ហើយសម្រាំងរើសយកតែទាហានដែលមានថ្វីដៃ ដើម្បីនឹងពុះទំលាយ វាយយកបន្ទាយគុនគួនឲ្យបាន ។

ម៉ាឆៀវឃើញចូចូលើកមកតាំងបន្ទាយនៅជិតដូច្នោះ ក៏នាំទាហាន ចេញពីក្នុងបន្ទាយទៅតទល់នឹងទាហានចូចូ ម៉ាឆៀវបរសេះស្ទុះទៅ ឈរមុខទ័ព ចូចូក៏ឡើងសេះមកបញ្ឈប់នៅមុខបន្ទាយ ក្រឡេកឃើញ ទាហានម៉ាឆៀវនេះនោះមានរូបសម្បត្តិមាំមួនប្រហែលគ្នា ហើយឃើញ ម៉ាឆៀវពាក់គ្រោះប្រាក់ពាក់មួកស ជិះសេះកាន់លំពែងឈរមុខទាហាន មានរូបយ៉ាងសមៀម ស្មាតាងកងចង្កេះមូល មុខសពុកមាត់ក្រហមសម គួរជាទាហានឯក ហើយឃើញបាំងគេកជិះសេះនៅខាងស្តាំ ម៉ាតាយ នៅខាងឆ្វេង ចូចូក៏នឹកក្នុងចិត្តថា ម៉ាឆៀវនេះមិនបង់ជាតិ ដែលកើត មកធ្វើជាទាហាន នឹងចូលគយុទ្ធសង្គ្រាមក៏មានស្វាហាប់ចំណាប់ណាស់ ចូចូក៏បរសេះចូលទៅហើស លុះដល់ជិតហើយក៏ស្រែកទៅឲ្យម៉ាឆៀវ ថា ខ្លួនអ្នកជាមនុស្សមានពូជត្រកូលខ្ពស់ ឈ្មោះថាមន្ត្រីខុំពដការ ហេតុ ម្តេចក៏លើកពលយោធាមកជាក្បួនក្បត់ផែនដីដូច្នេះ ។

ម៉ាឆៀវឮដូច្នោះខឹងណាស់ ខាំមាត់ក្រឹតធ្មេញហើយស្រែកជេរ ទៅចូចូថាអាចោរសត្រូវកេងសម្បត្តិ អាឯងជាតួក្បត់ផែនដីមានសេចក្តី

ប្រព្រឹត្តអាក្រក់ណាស់ ធ្វើឲ្យព្រះចៅហៀនតេជាម្ចាស់មានព្រះទ័យមិនសប្បាយសោះ ទោសអាឯងខុសជាទម្ងន់ គួរតែនឹងកាប់ជញ្ជ្រាំសាច់ឲ្យល្អិតល្អន់ដូចប្រអួល ទើបគួរនឹងទោសកំហុស ហេតុអ្វីអាឯងគិតខុសមកសម្លាប់អាពុកអញ ។ អញមានសេចក្តីខឹងខ្លាំងណាស់ អញមកនេះប្រាថ្នានឹងចាប់អាឯងវះពោះសាច់ហុតឈាមទាំងរស់ឲ្យបាន ថាហើយក៏បរសេះចូលតម្រង់ទៅនឹងចាប់ខ្លួនចូចូ អ៊ីកឹមឃើញដូច្នោះក៏ញាក់សេះស្ទុះមកតទល់នឹងម៉ាឈៀវបាន ២០ កួន អ៊ីកឹមអស់កម្លាំងប្រឹងតពុំបានក៏ទាញសេះវៃត្រឡប់រត់ទៅក្រោយ លើកដងក៏ស្ទុះបណ្តោយមកតនឹងម៉ា-ម៉ាឈៀវបាន ៩ កួន ម៉ាឈៀវលើកលំពែងចាក់ត្រូវលើកដងធ្លាក់ពីលើសេះស្លាប់ ម៉ាឈៀវក៏បរពលចូលខ្ទាប់ តាំងតែប្រកាប់ជាប់ដៃគ្នានឹងទ័ពចូចូ ទាហានចូចូស៊ូពុំបានក៏បែកធ្លាយបាក់ទាំងទ័ពសន្ធាប់សន្ធឹកណាស់ ម៉ាឈៀវក៏ដេញទាហានឲ្យចូលរហ័សសន្ទុញទៅទៀត ម៉ាឈៀវស្រែកឲ្យចាប់ខ្លួនចូចូឲ្យបាន ទាហានក៏ស្ទុះចូលច្រូលច្របល់ស្រែកថា អាពាក់ក្រោះក្រហមនោះជាមេចោរក្បត់ឲ្យចាប់ខ្លួនវាឲ្យបាន ចូចូឮដូច្នោះភ័យខ្លាំងណាស់ដោះក្រោះចេញពីខ្លួន ហើយបំផាយសេះស្ទុះចេញទៅជាមួយនឹងកូនទាហាន ពួកទាហានម៉ាឈៀវស្រែកថាអាចោរពុកចង្កាវែងនោះហើយឈ្មោះចូចូ ឲ្យចាប់វាឲ្យបាន ។

(នៅមានត)

# រឿងព្រេងទាក់ទងដោយប្រវត្តិសាស្ត្រខ្មែរ
# តាមឯកសាររបស់ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

ទំនៀមទម្លាប់ នៃខេមរជាតិ
ខ្មែរគួរខ្មីឃ្មាត សិក្សាពេញទី ។
ព្រោះខេមរជាតិ ជាជាតិសោភី
ក្នុងទ្វីបអាស៊ី តាំងពីព្រេងនាយ ។
ប.ព

## រឿងប្រាសាទនាងខ្មៅ

### នៅខេត្តតាកែវ

បើយើងធ្វើដំណើរពីក្រុងភ្នំពេញ ទៅកាន់ខេត្តតាកែវ ដល់ទៅឃុំរវៀង ស្រុកសំរោង យើងនឹងឃើញវត្តបុរាណមួយ ឈ្មោះវត្តប្រាសាទ-នាងខ្មៅ តាំងនៅខាងកើតជាប់នឹងថ្នល់ពីក្រុងភ្នំពេញទៅ ។

បានជាហៅថា វត្តប្រាសាទនាងខ្មៅ ព្រោះវត្តនោះមានប្រាសាទបុរាណ ២ ឈ្មោះប្រាសាទនាងខ្មៅនៅខាងលិចព្រះវិហារ ចំខ្លោងទ្វារវត្តពីទិសបស្ចិម ។ ប្រាសាទទាំងពីរនោះ ធ្វើពីថ្មផងឥដ្ឋផង ទំហំ ៤ ម៉ែត្រ ៤ ជ្រុង, កំពស់ ១០ ម៉ែត្រ កំពូលស្រួចដូចចេតិយ ខ្ពស់ត្រដែត ។

ប្រវត្តិនៃប្រាសាទនោះ មានសេចក្ដីដំណាលថា៖

ក្នុងអតីតកាលដ៏កន្លងយូរមកហើយ មានស្ដេចមួយព្រះអង្គទ្រង់ព្រះ

នាមព្រះសុរិយោទេវវង្ស ជាស្ដេចប្រកបដោយមហិទ្ធិឫទ្ធិនិងបុណ្យបារមីច្រើន ៗ ទ្រង់មានព្រះរាជបុត្រីមួយព្រះអង្គព្រះនាមនាងខ្មៅ ហើយទ្រង់គង់នៅលើភ្នំដីស្បូរ ៗ ទ្រង់បានកសាងប្រាសាទ ៥ នៅលើភ្នំនោះ ទ្រង់ជីកស្រះ ៤ លើភ្នំ នៅគ្រប់ជ្រុងប្រាសាទ ៗ អំពីកំពូលភ្នំចុះមកខាងក្រោមចម្ងាយប្រហែល ៧០០ ម៉ែត្រ មានទន្លេ ៤ គ្រប់ជ្រុងទាំង ៤ គឺទន្លេអុំ១, ទន្លេស្ងួត ១, ទន្លេស្ដុក ១, ទន្លេប្រទ្រុន ១ ៗ ទន្លេទាំង ៤ នេះជាកន្លែងសម្រាប់ការក្រសាលរបស់ស្ដេចអង្គនោះ ៗ លុះព្រះរាជបុត្រីមានវ័យវឌ្ឍនាការចំរើនឡើងបានព្រះជន្ម ១៦ ព្រះវស្សា ព្រះនាងមានព្រះរូបឆោមល្អជាងស្រីឯទៀតក្នុងព្រះនគរ ៗ សម័យថ្ងៃមួយ ព្រះនាងនឹកក្នកចង់ទៅក្រសាលទន្លេប្រទ្រុន បានចូលទៅថ្វាយបង្គំលាព្រះរាជាសុំទៅក្រសាលទន្លេនោះ ៗ ព្រះរាជាក៏ទ្រង់ព្រះរាជានុញ្ញាត ហើយទ្រង់ចាត់អ្នកបំរើឲ្យរៀបចំហែហមដំណើរព្រះនាង ទៅក្រសាលក្នុងវេលាថ្ងៃរសៀល។

គ្រានោះ មានបុរសម្នាក់ឈ្មោះបណ្ឌិតស្រី ទើបតែនឹងសឹកពីសាមណេរ មានរូបឆោមល្អល្អះស្អាតបាតជាងបុរសឯទៀត ព្រមទាំងចេះអាគមវិជ្ជាការផង ៗ បណ្ឌិតនេះ មានទីលំនៅ ៗ ភូមិមួយខាងលិចភ្នំដីស្បូរ ជិតផ្លូវដែលចុះទៅទន្លេប្រទ្រុន ៗ ថ្ងៃនោះ បណ្ឌិតស្រីមានសេចក្ដីអផ្សុក រួចចេញទៅលេងជិតផ្លូវ ក៏បានឃើញព្រះរាជធីតាយាងចុះពីលើភ្នំជាមួយនឹងស្រីជាបរិវារ ៗ លុះបានយល់កាលណា បណ្ឌិត

ស្រីស្រាប់តែមានសេចក្ដីស្នេហាប្រតិពទ្ធជាប់ចិត្តនឹងព្រះនាងនោះក្រៃពេក ៗ បណ្ឌិតនោះពិចារណាថា: ថ្ងៃនេះជាថ្ងៃមានលាភធំដោយបានជួបប្រទះនឹងស្រីគ្រប់លក្ខណ៍ តែអាត្មាអញជាកូនរាស្ត្រអ្នកកំសត់ ធ្វើម្ដេចនឹងបានព្រះនាងនេះហ្ន៎ ! , ព្រះនាងនេះមិនមែនជាស្ត្រីធម្មតាទេ គឺជាព្រះរាជបុត្រីរបស់ស្ដេច អាត្មាអញនឹងព្រះនាងពុំសមសក្តិគ្នាសោះ បើដូច្នេះអញនឹងគិតយ៉ាងណាទៅអេះ ! ៗ បណ្ឌិតស្រីគិតសព្វគ្រប់ទៅ ចេះតែស្រឡាញ់ខ្លាំងឡើង ៗ ទើបនឹកថា នឹងចូលទៅដណ្ដឹងតាមច្បាប់ក៏ពុំសមមុខជាស្ដេចនឹងយកទោសដល់ស្លាប់ ៗ លុះសេចក្ដីស្រឡាញ់ចេះតែកើតទ្វេឡើង ៗ ក៏ស៊ូប្ដូរស្លាប់ ថាទុកជាស្ដេចយកទោសយ៉ាងណា ៗ ក៏សុខចិត្តតែស្លាប់ ទើបបាននឹកដល់មន្តវិជ្ជាការដែលខ្លួនចេះចាំប៉ុន្មាន រួចបេះស្លឹកឈើយកមកសូត្រផ្លុំមន្តវិជ្ជាការ ហើយឡើងលើដើមឈើផ្លុំស្លឹកបន្លឺឡើង ៗ ឯសូរសម្លេងស្លឹកដែលបណ្ឌិតនោះផ្លុំ ហាក់ដូចជាទៅចុចចំពេះជូនព្រះនាង ៗ ក៏ក័ន្តតាំងស្មារតី ៗ លុះភ្ញាក់ដឹងព្រះអង្គឡើង ព្រះនាងទ្រង់គិតថា អាត្មាអញជាកូនស្ដេច ធ្លាប់ស្ដាប់ភ្លេងដូរ្យតន្ត្រីសព្វថ្ងៃ តែពុំដែលមានភ្លេងអ្វីធ្វើឲ្យអញស្លុតចិត្តដូចសម្លេងនេះសោះ ៗ ព្រះនាងទ្រង់សម្រឹងគិតយូរទៅ ៗ សម្លេងនោះរឹតតែពីរោះឡើង ៗ , ព្រះនាងអត់ទ្រាំពុំបានក៏លាន់ព្រះឱស្ឋថា " យើអើហ្ន៎ ! សម្លេងនេះជាសម្លេងប្លែកណាស់ គួរតែអញទៅតាមស្ដាប់មើលឲ្យឃើញច្បាស់ តើអ្នកនោះដូច

ម្តេចបានជាចេះផ្ទុំពីកេះដល់ម្ល៉ឹង !” ។ ព្រះនាងទ្រង់យាងទៅគេមើល ឲ្យឃើញដោយព្រះអង្គឯង ។ លុះទៅដល់ ព្រះនាងទតយល់រូបឆោម បណ្ឌិតនោះស្អាតល្អ ក៏មានសេចក្តីប្រតិព័ទ្ធជាប់ចិត្តនឹងបណ្ឌិតនោះ បាន សាកសួរសុខទុក្ខគ្នាទៅវិញទៅមកតាមដំណើររបស់បុរសនឹងស្ត្រី ដែល ស្រឡាញ់គ្នាតាមបវេណី ។ ជនទាំងពីរក៏បាននិយាយមត់គ្នាថា ថ្ងៃ ក្រោយយើងនឹងមកជួបគ្នាទៀត ហើយលាគ្នាបែកមុខរៀងខ្លួន ។ ចំណែក ព្រះនាង ចាប់ដើមតាំងពីបែកមុខអំពីបណ្ឌិតនោះមក តែងមានទឹកព្រះភក្ត្រ ប្លែកប្រក្រតី ព្រះភក្ត្រក្រៀមក្រំលែងកេះកាយនឹងពួកបរិវារ ។ ពួកបរិវារ មានចិត្តសន្ទិះសង្ស័យ ។ ថ្ងៃក្រោយ នាងចូលលាព្រះរាជាទៅម្តងទៀត ។ ព្រះរាជាទ្រង់អនុញ្ញាតឲ្យព្រះនាងទៅ ទ្រង់ចាត់អ្នកបំរើឲ្យហែហមដំណើរ ព្រះនាងដូចថ្ងៃមុន ។ លុះទៅដល់កន្លែងនោះ ព្រះនាងទ្រង់មានព្រះស-វនីយ៍ប្រាប់ពួកបរិវារថា “អ្នកពលគ្នាត្រូវឈប់ចាំខ្ញុំ ។ មានកិច្ចទៅកន្លែង ឯនោះបន្តិច” ។ មានព្រះសវនីយ៍ប្រាប់ហើយ ព្រះនាងទ្រង់ស្តេចសំដៅ ទៅកន្លែងដែលសន្មតឲ្យបណ្ឌិតស្រីមកជួបនោះ ។ លុះបានជួបគ្នាហើយ គូស្នេហាក៏សម្រេចសេចក្តីប្រាថ្នារបស់ខ្លួនទៅ ។ ពួកបរិវារសង្ស័យទៅ លបមើលឃើញកិរិយាមិនល្អ មានសេចក្តីភិតភ័យខ្លាចក្រែងព្រះរាជាយក ទោសដល់ជីវិត ក៏ជំនុំពិគ្រោះគ្នាថា: “យើងគួរតែក្រាបទូលស្តេចកុំ ខាន” ។ លុះត្រឡប់ទៅវិញ ពួកបរិវារ ក៏ចូលទៅគាល់ទូលស្តេចសព្វគ្រប់

តាមដំណើរ ។ ស្តេចទ្រង់ខ្ញាល់ជាយ៉ាងខ្លាំង ទ្រង់ហៅពួកពេជ្ឈឃាតមកប្រាប់ថា "ត្រូវយកកូនអញទៅសម្លាប់ឲ្យដាច់" ។ ចំណែកព្រះមាតាជាអគ្គមហេសី ក្រាបទូលសូមទោសព្រះស្វាមីថា "សូមព្រះករុណាទ្រង់ព្រះមេត្តាប្រោស កូនរបស់យើងតែមួយ បើទុកជាមានទោសខុសយ៉ាងណា ៗ សូមព្រះអង្គកុំសម្លាប់ គ្រាន់តែបំបរបង់ចេញអំពីទីនេះចុះ សូមទ្រង់អនុញ្ញាតឲ្យផង" ។ ស្តេចក៏ទ្រង់អនុញ្ញាតតាមសេចក្តីសុំរបស់ព្រះនាងជាមាតា ។ ទ្រង់ព្រះបញ្ជាទៅពួកសេនាបតីឲ្យធ្វើប្រាសាទ ២ ខ្នង ចម្ងាយពីគ្នាដីស្ងួត ៣ យោជន៍ ។ ពួកសេនាបតីក៏ទទួលធ្វើតាមព្រះរាជបញ្ជារួចហើយ ស្តេចទ្រង់បង្គាប់ឲ្យនាំព្រះនាងខ្មៅទៅគង់នៅទីនោះ ។ ប្រាសាទនេះនៅខាងលិចគ្នាដីស្ងួត ។ តាំងពីថ្ងៃនោះទៅ ព្រះនាងកើតទុក្ខជាទម្ងន់ណាមួយព្រះបិតាបំបង់ខ្លួនចោលឲ្យទៅនៅតែម្នាក់ឯង ណាមួយបែកពីសង្សារលែងបានមកជួបលោះ ដោយមិនជ្រាបថាទៅទីណា ។

សម័យនោះ មានភិក្ខុមួយអង្គឈ្មោះកែវ លោកនិមន្តចេញពីស្រុកខ្មែរ ទៅរៀនមន្តវិជ្ជាការនៅស្រុកក្រៅ លោករៀនបានចេះពូកែណាស់ លោកត្រឡប់មកស្រុកវិញ គង់នៅវត្តមួយក្នុងខែត្រតាកែវ ទីនោះអត់ទឹក អ្នកស្រុកនាំគ្នាជីកស្រះមួយប្រគេនលោក ។ ដោយសារស្រះនោះជារបស់លោកគ្រូកែវ ទើបស្រះនោះមានឈ្មោះថាស្រះកែវ ៗ រហូតដល់សព្វថ្ងៃ ។

លោកគ្រូអង្គនោះគង់នៅយូរបន្តិចទៅ មានកិត្តិសព្ទខ្លួនទៅគ្រប់ស្រុក

កូម៉ែកពូកែខាងមន្តវិជ្ជាការ ។ ព្រះនាងភ្ញៅបានទ្រង់ជ្រាបដំណឹងថា លោកគ្រូនោះទើបតែនិមន្តមកពីស្រុកក្រៅ ចេះមន្តវិជ្ជាការល្បីល្បាញដូច្នោះ មានបំណងចង់ជួបលោក ដើម្បីចង់ដឹងសេចក្តីទុក្ខរបស់នាងថា តើថ្ងៃណានឹងបានស្រាកស្រាន្តស្បើយល្ហើយ ។ ព្រះនាងមានព្រះសវនីយ៍ប្រាប់ពួកអ្នកបំរើឲ្យរៀបព្រះទីនាំងដំរី ដើម្បីទៅថ្វាយបង្គំលោកគ្រូអង្គនោះ ។ លុះធ្វើព្រះដំណើរទៅដល់ទីកន្លែងលោកគ្រូនោះហើយ ព្រះនាងស្តេចចូលទៅថ្វាយបង្គំលោកតាមធម្មតា បានឃើញលក្ខណៈលោកគ្រូអង្គនោះសព្វគ្រប់ ក៏ទ្រង់បែកព្រះទ័យអំពីសង្សារចាស់ មកជាប់នឹងលោកគ្រូកែវវិញ ពីព្រោះលោកអង្គនោះមានរូបសម្បត្តិល្អជាង ពេញលក្ខណៈជាប្រុសគួរឲ្យស្រឡាញ់ ។ ព្រះនាងក៏ដំណាលពីសេចក្តីសុខទុក្ខរបស់ទ្រង់ទូលលោកសព្វគ្រប់ ហើយសំដែងអាការស្និទ្ធស្នាលហាក់ដូចជាទុកចិត្តយូរមកហើយ ។ ការដែលព្រះនាងពណ៌នារឿងរ៉ាវរបស់ព្រះនាងនោះគួរឲ្យលោកយល់បានថា ព្រះនាងមានហទ័យជាប់ជំពាក់នឹងលោក ។ លោកគ្រូកែវ អត់ទ្រាំពុំបានក៏មានចិត្តទោរទន់ទៅរកព្រះនាងដែរ ហើយមានពុទ្ធដីកាទន់ភ្លន់ទៅរកព្រះនាង ។ កាលបើព្រះនាងទ្រង់បានឮពុទ្ធដីកាលោកផ្អែមល្ហែមទន់ភ្លន់មកកាន់ទ្រង់ ក៏នឹកសង្ឃឹមថា "តទៅមុខ អញនឹងមានអានលែងកើតទុក្ខតាំងពីថ្ងៃនេះទៅហើយ" ។ ចាប់តាំងពីថ្ងៃនោះមក ព្រះនាងមានពណ៌សម្បុរស្រស់បំព្រង ដូចស្រីទេពអប្សរឡើងវិញ ។

ចំណែកលោកគ្រូកែវ លោកខំប្រឹងពិចារណាធម៌ ដើម្បីដកចិត្តអំពីព្រះនាងនោះខ្លាំងណាស់ដែរ តែដកចិត្តពុំរួចសោះ ។ ពេលក្រោយមក ព្រះនាងស្តេចត្រឡប់ទៅថ្វាយបង្គំសុំឲ្យលោកស្រោចទឹក ដើម្បីឲ្យមានសិរីសួស្តី ពេលស្តេចទៅស្រោចទឹកនោះ ព្រះនាងរឹតតែសំដែងសេចក្តីរាក់ទាក់ទៅរកលោកគ្រូកែវខ្លាំងឡើងទៀត ព្រះនាងទូលលោកថាៈ "សូមឲ្យលោកម្ចាស់គង់នៅជាសុខសប្បាយចុះ" ។ កាលបើឮព្រះសូរសៀងព្រះនាងដូច្នោះ លោកគ្រូកែវក៏ក្រៀមក្រំ ស្រពោនកើតទុក្ខដោយសំដីព្រះនាង ។ អាការដែលលោកធ្វើនោះ ហាក់ដូចជាប្រាប់ព្រះនាងឲ្យដឹងច្បាស់ថាលោកកើតទុក្ខពីព្រោះតែព្រះនាង ។ ព្រះនាងរឹតតែមានសេចក្តីស្រឡាញ់ខ្លាំងឡើង រួចទ្រង់ស្តេចត្រឡប់ទៅព្រះដំណាក់វិញ កើតទុក្ខផ្ទំពុំលក់ សោយក្រយាពុំបាន អត់ទ្រាំពុំបានក៏ចាត់បំរើឲ្យរៀបព្រះទីនាំងដំរី ឲ្យទៅនិមន្តលោកមកដំណាក់ព្រះនាង ។ ចំណែកលោកគ្រូកែវ កាលបើបានឃើញអ្នកបំរើទៅនិមន្ត ក៏សប្បាយព្រះទ័យបានរៀបចំដំណើរនិមន្តមកជាប្រញាប់ ។ ព្រះនាងរៀបចំបណីតាហារសុទ្ធតែរបស់ថ្លៃ ៗ ទុកបំរុងប្រគេន ។ លុះលោកនិមន្តទៅដល់ ព្រះនាងក៏លើកប្រគេនលោកផ្ទាល់ព្រះអង្គ ។ លោកគ្រូកែវឆាន់ពុំបាន អាការដែលលោកឆាន់មិនបាននោះ ហាក់ដូចជាប្រាប់នាងឲ្យរឹតតែច្បាស់ឡើង ។ ព្រះនាងក៏រឹតតែកើតទុក្ខខ្លាំងឡើង ។ អត់ទ្រាំកើតខ្មាសពុំបាន ទ្រង់ចូល

ទៅទូលលោកថា «សូមលោកម្ចាស់តាកសិក្ខាបទមកចុះ» ហើយព្រះនាងប្រគេនសំលៀកបំពាក់ ព្រមទាំងប្រដាប់ប្រដាសព្វគ្រប់ ។ លោកគ្រូកៃក៏ទទួលយល់ព្រមតាមសំដីព្រះនាងនិមន្ត ហើយក៏សឹកតាកសិក្ខាបទជាឃរាវាស នៅរួមសុខទុក្ខជាមួយព្រះនាងខ្មៅក្នុងប្រាសាទនោះ បានជាកន្លែងនោះគេហៅថា «ប្រាសាទនាងខ្មៅ» តាំងពីនោះរហូតមក ។

ចំណេរកាលមកខាងក្រោយ មានពុទ្ធបរិស័ទជ្រះថ្លាបានស្ថាបនាវត្តនៅទីនោះឡើង បានជាវត្តនោះហៅថា «វត្តប្រាសាទនាងខ្មៅ» រហូតមកដល់សព្វថ្ងៃ ។

---

លោកថាឆ្កួតបី ឆ្កួតមួយនឹងស្រី ឆ្កួតមួយនឹងស្រា ឆ្កួតមួយនឹងល្បែង អំពើពាលា ឆ្កួតនេះហៅមហា ឆ្កួតក្រៃកន្លង ។ ឆ្កួតស្រីឆ្កួតស្រា ឆ្កួតល្បែងពាលា អំពើសឹងឆ្គង លោកពុំឲ្យសេព ឲ្យវៀរជាម្ដង កុំតែងឲ្យហ្មង ខូចកាំងស្មារតី ។ ឲ្យខូចក្ដីគាប់ ខូចទាំងខ្លួនស្លាប់ ខូចសាស្ត្រសូត្រ ខូចសីលខូចទាន ខូចញាណវិជ្ជា ខូចច្បាប់-ប្រក្រតី ឆ្កួតបីប្រការ ។

ច្បាប់កូនចៅ

# អង្គរនិងសម័យអង្គរ តាមទស្សនាវដ្ដី "ញូវអូរិយ៉ង់" (ក្រុងប្រាក) លេខ ៣/១៩៦១

ជនណាដែលជាប់ចិត្តនឹងប្រវត្តិសាស្ត្រ ហើយនឹងវប្បធម៌ប្រទេសឥណ្ឌា មិនគប្បីបិតនៅព្រងើយកន្តើយ ចំពោះសម័យដែលឋានៈដ៏ខ្ពង់ខ្ពស់នៃអារ្យធម៌ចាស់ទុំនៃប្រទេសឥណ្ឌាជាន់ចាស់ បានចាប់ផ្ដើមបង្ហាញឲ្យឃើញច្បាស់ ប្រហែលចំនួនពីរពាន់ឆ្នាំហើយ ដោយសារការពង្រីកផ្សាយខាងពាណិជ្ជកម្មនិងវប្បធម៌ នៃតំបន់មាត់សមុទ្រប្រទេសអាស៊ីភាគអគ្នេយ៍ទេ ។ បូព៌ាភាគទាំងមូលនៃសាគរឥណ្ឌា ឈូងសមុទ្របេង-ហ្គាល ច្រកសមុទ្រម៉ាឡាកា សមុទ្រជ្វានិងសមុទ្រចិនខាងត្បូង ទាំងអស់នេះ ទៅជាវិស័យនៃការដឹកនាំខាងសមុទ្រ និងពាណិជ្ជកម្មរបស់ប្រទេសឥណ្ឌា ។ មាគ៌ាទាំងឡាយដែលនាំទៅរកផលិតផលមានតម្លៃថោកនិងទៅរកគ្រឿងទេសដ៏ថ្លៃថ្លា ដែលថែមទាំងមានលេចឡើងនៅផ្សារជាតិរ៉ូ-ម៉ាំងតាមរយៈនៃប្រទេសឥណ្ឌានោះ រមែងតែប្រព្រឹត្តទៅតាមផ្លូវសមុទ្រទាំងនេះឯង ។ ដូច្នេះហើយទើបគេឃើញលេចកើតមានរដ្ឋថ្មីៗ ជាច្រើននៅកោះសុង[១] (Sonde) និងនៅប្រទេសឥណ្ឌាបូព៌ាភាគ តែការកកើតរដ្ឋថ្មីទាំងនេះ ក៏រមែងបិតនៅតែក្រោមអានុភាពនៃប្រទេសឥណ្ឌាជាធម្មតា ។ ការដឹកនាំផ្ទាល់មុខនៃជនជាតិឥណ្ឌាពោះទៅទ្វីបអាស៊ីភាគអគ្នេយ៍

១- កោះប្រទេសម៉ាឡាយូបន្តពីជ្រោយកោះម៉ាឡាកា ហូតទៅទល់នឹងកោះម៉ូលុក ។

នឹងប្រទេសចិនខាងត្បូង ព្រមទាំងអានុភាពនៃការតាំងអាណានិគមខាងវប្បធម៌ឥណ្ឌា តែងនៅមាននៅឡើយ នៅពេលដែលការពង្រីកផ្សាយខាងសាសនាឥស្លាមក្នុងតំបន់នោះ កំពុងរុងរឿង ៗ សព្វថ្ងៃនេះក៏ដោយ គេនៅតែជួបប្រទះនូវអានុភាពសាសនាឥណ្ឌា នឹងវប្បធម៌ឥណ្ឌាក្នុងតំបន់នោះ ។ ផែនដីប្រទេសកម្ពុជាបច្ចុប្បន្នក៏ឋិតនៅក្នុងរង្វង់នៃអានុភាពនោះដែរ ។

ប៉ុន្តែកាលបើជឿថា វត្ថុដែលនៅគង់វង់ខាងមុខសិល្បៈនៃសម័យនោះ គឺជាទម្រង់តែមួយក្នុងរង្វង់នៃសិល្បៈឥណ្ឌា ការជឿយ៉ាងនេះទុកជាការកាន់ច្រឡំ ។ តាមពិត សិល្បៈខ្មែរនឹងកេរសិលាគីអង្គរ ជាវត្ថុតាងដ៏ជាក់ច្បាស់នៃការវិវត្តន៍ខាងសិល្បៈរបស់ខ្មែរ នឹងជាប្រភពដ៏រស់រ-វើកដែលបង្កើតនូវប្រពៃណីខាងវេទាសិល្បៈរបស់ខ្មែរនោះ ។

កាលដែលខ្ញុំបានឱកាសទៅទស្សនាលើកដំបូង នូវប្រាសាទអង្គរដ៏ល្បីល្បាញ នៅពេលនោះ ខ្ញុំចង់ដឹងថា សិល្បៈអង្គរស្រដៀងគ្នានឹងនិម្មាបនកម្មឥណ្ឌាខាងប្រាសាទ ខាងចម្លាក់នឹងខាងការតាក់តែងលំអ ដោយវិធានការណ៍បែបណា ? ហើយម្យ៉ាងទៀត ការណ៍ទាំងនេះផ្សាយចេញនូវអារម្មណ៍ទូទៅដូចម្តេច ? ។ ខ្ញុំជឿទៀតថា ចម្លើយចំពោះបញ្ហានេះជាអារម្មណ៍មួយដ៏ខ្លាំងជាងអារម្មណ៍ ដែលខ្ញុំបាននាំយកមកពីអង្គរទៅទៀត ៗ

សព្វថ្ងៃ គេឲ្យឈ្មោះអង្គរ (ជាភាសាសំស្ក្រឹតថា នគរ: ជាភាសា

ខ្មែរថានគរ ប្រែថាទីក្រុង ឬរដ្ឋ) ជាក្រុមប្រាសាទដ៏សំខាន់ តាំងនៅខាងជើងបឹងទន្លេសាប ក្នុងខេត្តសៀមរាប ដែលបានចាប់កសាងឡើង ជាច្រើនលើកច្រើនគ្រា ពីសតវត្សទី ៩ រហូតមកដល់សតវត្សទី ១៥ គឺជាព្រះរាជធានីនៃព្រះអធិរាជាណាចក្រខ្មែរ ។ សម័យនោះ ព្រះរាជធានីមិនបានកសាងថ្មី នៅតែកន្លែងដែលជាធម្មតាទេ ជួនកាលយកទីក្រុងចាស់មួយភាគនឹងទីក្រុងថ្មីមួយភាគរួមបញ្ចូលគ្នា ស្ថាបនាជាព្រះរាជធានីថ្មីៗ មុនសម័យនោះនឹងអន្តរកាលក៏ដោយ ព្រះរាជធានីខ្មែរ ត្រូវបានស្ថាបនាឡើងជាបណ្តោះអាសន្នក្នុងភាគដទៃផ្សេងនៃព្រះរាជអាណាចក្រ ។ មិនដែលមានប្រាសាទណាមានសភាពដូចគ្នាបានគង់វង់នៅទេ ឃើញមានគង់វង់នៅតែសំណល់នៃប្រាសាទទាំងឡាយដែលកសាងពីឥដ្ឋ ឬ ពីថ្មប៉ុណ្ណោះ ។ ប្រាសាទព្រះមហាក្សត្រនឹងអភិជន អាគារសាធារណៈនឹងគេហស្ថានអ្នកស្រុក សុទ្ធសឹងសង់អំពីឈើ ។ មិនដែលឈើណាទោះបីជាប់ដូចម្តេចក៏ដោយ អាចទប់ទល់នឹងភ្លៀងនឹងធាតុក្តៅសើមនៃប្រ-ទេសក្តៅនឹងការរុករាននៃព្រៃញាតស្បាតរបស់ខ្មែរបានឡើយ ។ ទីក្រុងគេបោះបង់ចោលហើយគ្មានជីវភាព បានត្រឡប់ក្លាយទៅជារំពាគ្មានគ្រឿងការពារនៃធម្មជាតដ៏សាហាវ ដែលដុះរួបរោមរឹត ដូចកម្រាលមួយរបនាដោយវល្លិជាតិពណ៌បៃតង ក្នុងរយៈកាលច្រើនសតវត្ស ។ សព្វថ្ងៃនេះទៀត អ្នកទស្សនាអាចយល់ច្បាស់បាន នូវការងឿងឆ្ងល់នឹងការកោត

សរសេររបស់អ្នកប្រាជ្ញបារាំងម្នាក់ឈ្មោះ (ហង់រី មូហ៊ុត) នៅឆ្នាំ ១៨៦៦ កាលដែលលោកកំពុងចរគ្រាច់ក្នុងព្រៃស្បាត ហើយស្រាប់តែទៅដល់នៅចំពោះមុខប្រាសាទអង្គរក្នុងនោះ ។ អ្នកគួមិជិតខាង នៅក្រោមកិច្ចបាត់ការនៃអ្នកប្រាជ្ញខាងបុរាណវត្ថុ ដែលកំពុងធ្វើការដើម្បីរក្សាឃុំគ្រង និងរៀបឡើងវិញនូវប្រាសាទដ៏ថ្លៃថ្លាបំផុតនៃសិល្បៈខ្មែរ បានទំប្រឹងចប់ និងរុញច្រានឲ្យថយឆ្ងាយបន្តិច នូវរុក្ខជាតិដុះស្ទាប់យ៉ាងច្រើនដែលតែងតែស្វែងរក (ឱកាស) និងកនទន្ទ្រានមកលើសិល្បៈខ្មែរជានិច្ចនោះ ។ ប្រាសាទខ្លះលិចកប់ពាក់កណ្ដាលបាត់ទៅក្នុងស្ទាប់ព្រៃញាតស្បាត ប្រាសាទខ្លះត្រូវគេបណ្ដោយឲ្យឋិតនៅក្នុងសភាពដើមតាមចិត្ត ដូចនៅពេលដែលគេទើបនឹងបានរកឃើញ បានជាទុកបណ្ដោយដូច្នេះ គឺដើម្បីបញ្ជាក់នូវកំស្កតាំងខាងកម្លាំងឧទ្ទិនបង្ហោចរបស់ធម្មជាតិរស់នៅលើសិលាឥតវិញ្ញាណ ។

កន្លែងដែលគេបានឃើញគ្រឹះតាំងឡាយនៃប្រាសាទធ្វើអំពីឥដ្ឋដ៏ចាស់បំផុត កំណត់ឡើងឃើញទៀតនូវចំណុចនៃការចេញដំណើរឆ្ពោះទៅកាន់ការស្វះស្វែងរកជាងខ្មែរបុរាណ ។ ដូច្នេះហើយទើបគេបានរកឃើញនូវប្រាសាទទឹងផ្ទាំងសិលាជាច្រើន មានចារឹកអក្សរសំស្ក្រឹត ឬ អក្សរខ្មែរជាន់ចាស់ សិលាចារឹកទាំងនោះពោលអំពីប្រវត្តិសាស្ត្រខ្មែរខ្លះ ។ ក្នុងសម័យនេះ ឬ សម័យនោះ ។ ថ្មកក់និងថ្មបាយក្រៀមដែលមានជាប់

វិជ្ជាភាពដ៏ប៉ិនប្រសប់នៃជាងចម្លាក់ខ្មែរអាចឲ្យគេឃើញបាននូវទម្រង់បុគ្គល និងព្រឹត្តិការណ៍ទាំងឡាយ ។ ព្រះអធិរាជាណាចក្រដែលពីដើម តាំងនៅលើផែនដីដ៏ធំទូលំទូលាយក្រៃលែងនៃទ្វីបអាស៊ីភាគអគ្នេយ៍ បាន ត្រូវគេទើបនឹងធ្វើឲ្យលេចឃើញច្បាស់ ។ គេបានរកឃើញទៀត នូវ ផ្ទាំងស្ថាបត្យកម្មនិងក្បាច់ចម្លាក់ទាំងឡាយ ដែលកប់បញ្ចូលក្នុងចំណោម ស្នាដៃឯកនៃសិល្បៈសាកលរហូតមកដល់សម័យយើងនេះ ។

សេចក្ដីបំណងចង់ស្គាល់យ៉ាងពិតប្រាកដនូវរឿងអតីតខ្មែរ ហើយ និងចង់ដោះស្រាយនូវបញ្ហាទាំងឡាយដែលបានចោទឡើងចំពោះការរក ឃើញថ្មីៗ កាន់តែរីកធំឡើង ។ ប្រភពនៃសម្ភារៈមានទុជារសមិនអាច រីងស្ងួតនេះ ដែលសម្រាប់កសាងប្រាសាទដ៏ល្អអស្ចារ្យ និងយ៉ាងទូលំទូ-លាយទាំងនោះ ផ្សាយមកតែពីការណ៍ខាងលើឬ ? ដោយហេតុដូចម្ដេច បានជាមានប្រាសាទថ្មីៗ ទាំងឡាយដ៏យ៉ាងល្អ និងប្រកបដោយកត្តិនាមជា និច្ច ដែលមានពាសពេញផែនដី បានកកើតឡើងដោយពិធីបុណ្យ មាន ការទាក់ទងនឹងស្ថាបត្យកម្មដ៏ពិតប្រាកដនេះ ? ខេបនភាព (ការរុញ) ដូច ម្ដេច ដែលរុញច្រានសិល្បៈខ្មែរឲ្យមានវិសិដ្ឋភាពដ៏សមគួរទុកជាគំរូនេះ ? ហើយម្យ៉ាងទៀត ប្រហែលចំនួនប្រាំសតវត្សពីនោះមក តើមានការប្រ-ព្រឹត្តទៅយ៉ាងណា ដែលញុំាងប្រាសាទទាំងឡាយនៃអង្គរ ព្រមទាំងព្រះ អធិរាជាណាចក្រខ្មែរឲ្យស្ទើរតែកប់បាត់ទៅក្នុងការមិនដឹងនា ?

ខ្មែរ (ដើម) ជាបុព្វបុរសខ្មែរសព្វថ្ងៃ និងជាអ្នកទទួលកេរ្តិ៍ពីព្រះអធិរាជាណាចក្រដ៏យ៉ាងចាស់បំផុត ដែលប្រទេសឥណ្ឌៀបស្ចិមទិសស្គាល់ច្បាស់ ហើយដែលប្រភពចិនហៅថា (ហ្វូណន) បានបង្កើតនូវទម្រង់រដ្ឋខ្លួនមួយ ក្នុងរវាងឆ្នាំ ៥៥០ ។ ដទៃពីកិច្ចវិវត្តន៍ខាងប្រវត្តិសាស្ត្រប្រកបដោយការរំកើប ហើយក្នុងសម័យនោះ ប្រទេសត្រូវបែកខ្ញែកគ្នា ព្រមទាំងបានបាត់ឯករាជ្យខ្លះផងនោះ គេប្រទះឃើញការកសាងឯកភាព និងអំណាចជាថ្មីឡើងវិញ នៃព្រះរាជាណាចក្រ ក្នុងរជ្ជកាលនៃព្រះបាទជ័យវរ្ម័នទី ២ (៨០២-៨៦៩) ដែលតាំងនៅក្នុងសតវត្សទី ៩ ។ សម័យខ្មែរចាប់ផ្តើមមានឡើងពីពេលនោះឯង ។ តមក សម័យនោះមានការចំរើនឡើងដល់កំពូលនៅសតវត្សទី១២ នឹងទី១៣ រួចធ្លាក់ចុះនៅសតវត្សទី ១៥ ។ សេដ្ឋកិច្ចនិងវប្បធម៌ដែលមានការរីកចំរើនដ៏ល្អ កសិកម្មដែលមានការវិវត្តន៍ ទុកជាមូលដ្ឋានខាងសេដ្ឋកិច្ចនៃព្រះអធិរាជាណាចក្រ ។ ខ្មែរជាគ្រូក្នុងការកសាងអាងទឹក ព្រែកជីក របៀបបញ្ចូលទឹក និងរបៀបបង្ហូរទឹក ។ ព្រះមហាក្សត្រទ្រង់ព្រះអំណាចផ្តាច់ការ ។ សាសនាព្រាហ្មណ៍ជាសាសនារដ្ឋ តមកព្រះពុទ្ធសាសនាក៏ផ្សាយចូលមកដែរ តែមានសភាពមិនបិតថេរ ។ តាមការពិត ប្រជាជាតិ (ខ្មែរ) មិនបានកាន់សាសនាទាំងឡាយនៃប្រទេសឥណ្ឌៀ ដូចជានៅក្នុងប្រទេសឥណ្ឌៀនោះទេ ។ មជ្ឈដ្ឋានខ្មែរក៏មិនបានប្រកាន់លទ្ធិវណ្ណៈដ៏យ៉ាងណាស់ណា

ដូចជានៅប្រទេសឥណ្ឌាដែរទេ ។ ប្រជារាស្ត្ររក្សាទុកនូវការគោរពបូជាខាងសាសនាតាមដើមកំណើតនៃខ្លួន ម្យ៉ាងទៀតការគោរពបូជានេះច្រើនតែមានអានុភាពមកពីប្រពៃណីខាងសាសនានៃព្រះពជបល្លក ។ គេអាចទទួលស្គាល់បាន នូវការគោរពបូជាបុព្វបុរសក្នុងការបង្ហាញឱ្យឃើញនូវបែបខ្មែរសុទ្ធ គឺការគោរពព្រះមហាក្សត្រទុកជាទេពតានេះឯង ព្រោះព្រះមហាក្សត្រគឺជាទេពតាដែរ ។ ការទុកព្រះមហាក្សត្រទាំងឡាយជាទេពតា ក្នុងវេលាដែលទ្រង់គង់ព្រះជន្មនៅ បង្កើតនូវប្រភពនៃអំណាចដ៏ពេញលេញនៃព្រះអង្គ ព្រះអំណាចនេះជាបាតុកម្មនៃសម្ពន្ធភាពរវាងរដ្ឋនឹងសាសនា ។ សារវន្តពិសេសនៃស្ថាបត្យកម្មខ្មែរនឹងទម្លាប់ឥតល្ហែក្នុងកិច្ចស្ថាបនានៃព្រះមហាក្សត្រទាំងឡាយ បណ្តាលមកតែពីជំនឿខាងលើនេះដែរ ។

ព្រះមហាក្សត្រទាំងឡាយ កាលដែលទ្រង់គង់ព្រះជន្មនៅ រមែងមានទម្លាប់សព្វព្រះរាជហឫទ័យបញ្ជាឱ្យស្ថាបនាសម្រាប់ព្រះអង្គ នូវបញ្ចាមរណប្រាសាទ ។ ឯប្រាសាទទាំងនេះមិនមែនសម្រាប់មនុស្សនៅទេ គឺសម្រាប់ទេពតា ហើយមានតែព្រះសង្ឃទើបអាចនិមន្តចូលក្នុងប្រាសាទនេះបាន ។ ប្រាសាទទាំងឡាយសង់នូវកណ្តាលទីក្រុង ហើយជាតំណាងផ្ចិតពិភពលោក គឺភ្នំព្រះសុមេរុនេះឯង ដែលយើងធ្លាប់ស្គាល់អំពីរឿងបុរាណសាស្ត្រនៃប្រទេសឥណ្ឌាជាន់ចាស់នោះ ។ ការបញ្ជាក់

ដ៏ត្រឹមត្រូវដែលសម្រេចឡើងតាមចំណុចវិសេសទាំងឡាយ ក៏ជាហេតុនៃពិធីសង់របៀបនេះដែរ ប្រាសាទទាំងឡាយកសាងលើភ្នំធម្មជាតិ ហើយតមកលើភ្នំអធម្មជាតិក៏មកពីហេតុនេះដែរ ប្រាសាទទាំងឡាយតែងមានស្រះទឹកដូចជាគូទសាគរព័ទ្ធជុំវិញ ក៏មកពីហេតុនេះដែរ សព្វិសសណ្ឋាននៃស្ថាបត្យកម្មក៏មកតែពី ហេតុនេះដែរ ។

ដូច្នេះ ពីសម័យមួយទៅសម័យមួយ គេអាចយកប្រាសាទអង្គរជាបែប ហើយតាមពិនិត្យគេទូទៅការវិវត្តន៍នៃការកែចំរើននៃសិល្បៈខ្មែរបានៗ មិនយូរប៉ុន្មាន ឥដ្ឋសម្រាប់កសាងមានចំនួនមិនគ្រប់គ្រាន់ ហើយគេទៅយកផ្ទាំងសិលាដ៏ធំ ៗ ពីកន្លែងយកថ្មដែលនៅឆ្ងាយ ៗ ៗ សិល្បៈករនិងសិប្បិកៈខ្មែរទាំងឡាយជាមេចម្លាក់ឈើតាំងពីដើមមក ក៏បានរៀនតុបតែងលំអទ្វារផង ហើយជាអវសានចេះលំអទាំងជញ្ជាំងសិលាទាំងឡាយថែមទៀត ៗ ពួកនេះវេទនាថ្មកក់ដូចជាឆ្លាក់ឈើមានសាច់ទន់ដែរ ៗ ជាបឋម ខ្មែរធ្វើស្ដម្ភសិលា ដូចស្ដម្ភនេះជាផ្តើងផ្ទាន់ធ្វើពីឈើ ៗ ភ្នំបាក់ខែងមានកាលបរិច្ឆេទនៅដំណាច់សតវត្សទី ៩ ជាសំណង់ព្រះលានលើកដំបូង គឺសំណង់នេះហើយជាជានពន្លកនៃអនាគតស្ថាបត្យកម្មដ៏រីកចំរើន ៗ គឺនៅបន្ទាយស្រី ដែលកសាងពីថ្មកក់ពណ៌ស៊ីកូឡាបក្នុងសតវត្សរ៍ទី ១០ នេះហើយ ដែលគេជួបប្រទះនូវក្បាច់ចម្លាក់លើផ្ទាំងសិលាដ៏ល្អបំផុត នូវ

ក្បាច់ចម្លាក់ក្បាលសរសរល្អយ៉ាងឆើតអស្ចារ្យក្រៃលែង និងផ្ដាំងចម្លាក់គួរជាទីចេតនា ហើយដែលគេទទួលទុកជាសោភណភាពខាងផែនដី ។ ប្រាសាទបាភួន (សតវត្សរ៍ទី ១១) បណ្ដាលឲ្យយល់ច្បាស់នូវគោលគំរូបុរាណនៃស្ថាបត្យកម្មខ្មែរ ។ ស្ថាបត្យកម្មខ្មែរដែលអាចបង្កើតនូវវត្តទាំងពួងក្នុងសម័យខ្ពស់បំផុតបាន (ក្នុងសតវត្សរ៍ទី ១៣) ក៏ដោយសារតែមានប្រាសាទទាំងអស់ខាងលើនេះ និងប្រាសាទដទៃទៀតច្រើន ជាការផ្ដើម ។ វត្តដ៏ថ្លៃថ្លាក្នុងសម័យនោះ គឺប្រាសាទអង្គរវត្ត ព្រោះអង្គរវត្តជាទីប្រជុំចុះនៃប្រាសាទទាំងឡាយ ដែលចាត់ទុកជាសំណង់ធំបំផុតប្រទេសនេះក្នុងលោក វត្តដ៏ថ្លៃថ្លាមួយទៀត គឺអង្គរធំដែលជាដំណែលនៃព្រះរាជធានី ។

---

គួរមនុស្សទាំងឡាយ ខិតខំខ្វល់ខ្វាយ
គិតដល់ការស្លាប់ មុននឹងផ្លាស់ភព
ត្រូវមានគុណគាប់ ណាខ្លះសម្រាប់
ទុកជាកេរ្តិ៍ហោង

ផេង . ជ្រឹវ

# អ្នករៀនដើម្បីជាតិ

ហៃកុមារ ចូរខំនាំគ្នា រៀនអក្សរសាស្ត្រ ចូរកុំរត់លេង ត្រូវនឹកអៀនខ្មាស បាត់អានឱ្យច្បាស់ សរសេរឱ្យត្រូវ ។ រៀនសូត្រឱ្យចេះ អស់អាថ៌ចំណេះ កុំឱ្យសត្រូវ ញាំញីលើក្បាល ចរកាលតទៅ នាំឱ្យអាស្រូវ ថោកដល់ជាតិទៀត ។ រដ្ឋខ្មែរតូចណាស់ ចូរប្រែក្រឡាស់ រិះរ រកស្មៀត កុំនៅខ្ជីខ្ជា ខាតពេលបង់មៀត នាន់អោយខំធ្មៀត ពាន់-នាន់នៅក្មេង ។ ចូរនាន់ជឿថា រដ្ឋនឹងថ្លៃថ្លា ដោយសារនាន់ឯង ដែលខំស្វាធ្យាយ ដើម្បីតាត់តែន តាំងផ្ទះសម្បែង ឱ្យល្អដូចគេ ។ ន.មោ.ក.ខ បាត់អានឱ្យល្អ កុំនៅទំនេរ ដីសខ្មៅដៃ ព្យាយាមសរសេរ កុំចាំគ្រូជេរ រៀនសោះគេថា ។ កុំដូចមនុស្សខ្វាក់ តាមតែគេញាក់ ឆ្វេងស្ដាំតាមការ ពួកជនបែបនេះ មានគុណតម្រា ថានាំអាត្មា ទៅរកក្ដីទុក្ខ ។ ១-២.៣-៤ បូកសង់តាមក្បួន គុណចែកតាមមុខ កុំធ្វេសប្រហែស ខំឡើងគ្រប់ស្រុក ទើបរដ្ឋបានសុខ រស់ពនក្សេមក្សាន្ត ។ អនាគតអ្នក ដូច្នេះត្រូវស្ទ្រ កុំទំនេប្រាណ ទៀយបាត់កុំភ្លេញ យកចេះឱ្យបាន ខ្លួននាន់ចើនថ្កាន ពីព្រោះទៀយមុន ។ ខំគូសខំគូរ អស់ចាំងតំនូរ ជូនស្រាលទំពន់ ចំណេះនេះហើយ ដែលនាំនូវគុណ បុណ្យសក្តិទ្រព្យធន ដល់ជាតិដល់អ្នក ។ ជំនួញជួញប្រែ ជាតិគេធ្វើតែ បន្ទុលចលាក់ បិទក្អកខ្មែរស៊ី ព្រោះជាតិខ្មែរខ្វាក់ នាន់អោយគួរគ្រោក ខំរុលទៅមុខ ។ រៀនដើម្បីអ្វី ដើម្បីទឹកដី ចូរបង់តាំទុក រដ្ឋកម្ពុជា កើតមីទីពុក សាន់បានជាស្រុក ដោយសារសាច់-ឈាម ។ បើជាតិត្រូវការ នាន់កុំសាក់ ថយក្រោយទមតាម ស្ទុះស្ទ្រ

បំរើ ឲ្យទាន់ពេលក្លាម នោះទើបដល់ពាម គឺសុខសប្បាយ ។ ពោះរស់ ពោះស្លាប់ ស្រីប្រុសប្រញាប់ ត្រូវបូជាកាយ ដល់មាតុភូមិ កុំបីទៀយ-ណាយ ជីវិតកុំស្តាយ ស្តាយត្រង់តែជាតិ ។ បើសត្រូវជិះជាន់ ព្រួតកុំ-ព្រាន់ វាយវាឲ្យឃ្លាត កុំដេកផ្សងព្រេង ត្រូវវាយឲ្យព្រាត់ វាយឲ្យខ្ចាយ ខ្ចាត់ ចាកពីទឹកដី ។ ត្រូវប្តូរជីវិត ស្លាប់រស់កុំគិត ណានាងប្រុសស្រី រស់នៅខ្ញុំគេ មិនប្រសើរអី ស្លាប់ព្រោះបូរី ជយោស្លាប់ចុះ ។ បើនាង បណ្តោយ ដល់ពៅថ្ងៃក្រោយ គ្មានបញ្ញាធ្ងុះ ព្រោះខ្ជិលពុំរៀន គំនិត-គុញគុះ ដល់ដឹងថាខុស ចាស់ជ្រុលពៅហើយ ។ ពេលកន្លងពៅ អ្នក-នាងស្រែកហៅ ពុំវិលវិញឡើយ នៅក្មេងត្រូវប្រឹង កុំធ្វើព្រងើយ នែអ្នក នាងអើយ មកពៅ! មកពៅ! ។ មកពៅសាលា នាងកណ្តៀតក្តារ ក្រាបលាម៉ែឪ បបួលមិត្តភក្តិ កុំគិតកាត់ទៅ ខំរៀនណាពៅ អ្នកខាង ក្នុងខ្មែរ ។ ម៉ែឪសប្បាយ ចិត្តលោកខ្វល់ខ្វាយ ខិតខំធ្វើស្រែ នាងស្ទាក រៀន ឲ្យបានពូកែ កុំយំឡែឡែ ខ្មាសជាតិជិតខាង ។ គុណគ្រូត្រូវស្គាល់ យប់ថ្ងៃខាងគាល់ ផ្ចិតផ្ចង់សំអាង គឺគ្រូនេះហើយ ដែលជួយកសាង វាស-នាសំណាង ឲ្យនាងពល់គ្នា ។ ចូរនាងចងចាំ អស់ចាំងបណ្តាំ ខាងលើ នេះណា ព្រឹកស្អែកត្រៀមខ្លួន ចេញចរយាត្រា ឆ្ពោះពៅសាលា ខំសិក្សាអើយ ។

(១)

នេះគឺបណ្តាំរបស់ខ្ញុំ ជាពាក្យសុខុមបរមក្សេម សូមអស់លោកអ្នក ពិនិត្យថែម បើមិនសូវផ្អែមសូមជួយតម្រង់ ។

---

(១) ពាក្យនេះអ្នកនិពន្ធដាក់បន្ថែមខាងចុងអត្ថបទរបស់ខ្លួន ។

**បច្ចុប្បន្នភាពជាតិ**

# ព្រះរាជពិធីបួងសួងលាព្រះបំណន់នៅខេត្តសៀមរាប នឹងខេត្តកណ្ដាល

## ពិធីបុណ្យបួងសួងលាព្រះបំណន់នៅលើភ្នំគូលេន

នៅថ្ងៃទី ៤ កក្កដា មានធ្វើព្រះរាជពិធីបួងសួងលាព្រះបំណន់នៅលើភ្នំគូលេន ។

នៅថ្ងៃនោះ ឥស្សរជនពីព្រះរាជធានី នឹងក្នុងខេត្តសៀមរាបព្រមទាំងគណៈប្រតិភូពីខេត្តនានា ក្នុងព្រះរាជាណាចក្រ រួមជាមួយអ្នកស្រុក បានធ្វើដំណើរទៅកាន់ភ្នំគូលេន ដែលមានចម្ងាយ ៤០ គ.ម. ពីអង្គរវត្ត ។

នៅម៉ោង ១៦ ព្រះទីនាំងឧទ្ធម្ភាគចក្រ បានដឹកនាំសម្ដេចឪ ទៅចុះនៅលើភ្នំគូលេន ។

នៅពេលដែលស្ដេចយាងចុះពីព្រះទីនាំង ព្រះអង្គបានទទួលការក្រាបថ្វាយបង្គំ អំពីអ្នកអង្គម្ចាស់ ណរោត្តម-កាន្តុល ប្រធានក្រុមប្រឹក្សាព្រះរាជាណាចក្រ, ឯ.ឧ. សាន-យុន ជូ-ព្រៀង ពីទូជីម៉ង-ទេរ៉ូ គូ-រុន សមាជិករដ្ឋាភិបាល សមាជិកសភាទាំងពីរ មន្ត្រីអ្នករាជការ ទាហាន ស៊ីវិលនឹងប្រជាពលរដ្ឋជាច្រើន រួចស្ដេចយាងបន្តព្រះដំណើរទៅលើកំពូលភ្នំ ដើម្បីរួបរួមក្នុងពិធីចំរើនព្រះបរិត្ត.ប្រគេននូវគ្រឿងបរិក្ខារផ្សេង ៗ ដល់ព្រះសង្ឃ ។

បន្ទាប់មកព្រះអង្គបានស្ដេចយាងទៅកាន់ព្រះពន្លា ដើម្បីទ្រង់ជាព្រះអធិបតីក្នុងព្រះពិធីបួងសួងលាព្រះបំណន់ ។

នៅលើព្រះពន្លា មានរៀបចំផ្កាយផ្សេង ៗ ដំកល់នៅលើតុបៃមុខឆ្ពោះទៅព្រះស្តូបនៃព្រះបដិមាករពុទ្ធរូបចូលព្រះបរិនិព្វាន ដែលបិតនៅខ្ពស់លើផ្ទាំងសិលា ។

ក្រោយដែលលោក ហ៊ិនពេជ្រសុរិយា ញ៉ែម.ចន ថ្លែងប្រកាសប្រគេនថ្វាយព្រះបដិមាករ ព្រះអតីតព្រះមហាក្សត្រតាមព្រះរាជប្រពៃណីនិងបួងសួងសុំទឹកភ្លៀង និងក្រោយដែលល្ហោនព្រះរាជទ្រព្យបានកំថ្វាយព្រះពុទ្ធបដិមាករ និងព្រះអតីតព្រះមហាក្សត្រហើយ សម្ដេចជាអម្ចាស់ព្រះអង្គបានទ្រង់ប្រកាសបួងចំពោះព្រះបដិមាករ ចំពោះព្រះអតីតព្រះមហាក្សត្រ ចំពោះទេវតាទាំងឡាយ និងចំពោះវត្ថុស័ក្ដិសិទ្ធិទាំងអស់អំពីអំពើឃោរឃៅយង់ឃ្នងនៃសៀមនិងយួន ដែលចេះតែរុករានធ្វើបាបកស្ត្រខ្មែរនិងបូមទឹកដីខ្មែរ ។

ព្រះអង្គបានក្រាបបង្គំទូលសុំឲ្យដាក់ទណ្ឌកម្ម ចំពោះសត្រូវរបស់ខ្មែរឲ្យវិនាសឲ្យតុតធាប់ដោយព្រឹត្តិការណ៍ណាមួយ ។

ក្រោយពិធីបួងសួង ព្រះអង្គបានស្ដេចយាងឡើងទៅលើព្រះស្តូបដាក់ព្រះកេសថ្វាយចំពោះព្រះបដិមាករ ជាព្រះរាជកិច្ចលាព្រះបំណន់ ។

នៅឱកាសនោះ ឥស្សរជន ព្រះរាជវង្សានុវង្ស និងទៅហ្វាយខែត្រ

ខ្ទះ បានដាក់ព្រះកេស បានគោរសក់ ថ្វាយព្រះបដិមាករដៃផ្ទៃសម្តេចព្រះប្រមុខរដ្ឋដែរ ។

សូមជ្រាបថា ពិធីបុណ្យនៅលើក្តួលេននេះ មានធ្វើជាបន្តនៅថ្ងៃទី ៥ និងថ្ងៃទី ៦ កក្កដា តាមទំនៀមទម្លាប់អ្នកស្រុកទៀត ។

## ពិធីដាក់បាត្រព្រះសង្ឃមួយរយអង្គនៅអង្គរវត្ត

នៅវេលាព្រឹកនៃថ្ងៃទី ៥ កក្កដា នៅអង្គរវត្ត ត្រង់ព្រះពាន់ មានធ្វើពិធីដាក់បាត្រព្រះសង្ឃមួយរយអង្គ ក្រោមព្រះរាជាធិបតីភាពនៃសម្តេចព្រះរាជកនិដ្ឋាស៊ីសោភ័ណ ជាព្រះរាជដំណាងនៃសម្តេចព្រះមហាក្សត្រិយានីជាអម្ចាស់ជីវិតលើត្បូង ដោយមានសហជីវិន ចាំង - ឈិន វដ្ឋ មន្ត្រីក្រសួងធម្មការអមផង ។

ពិធីនេះ បានកើតឡើងដោយហេតុកាលពីខែមេសា ១៩៦១ សហជីវិន អាំង-គីម-ឃន បានអញ្ជើញអ្នកតំណាងក្រុងទាំងអស់ទៅទស្សនាអង្គរវត្ត ។ ក្នុងពេលនោះ ប្រទេសថៃកំពុងតែកាន់អាកប្បកិរិយាជំនឹងរឹង មិនព្រមទទួលស្គាល់សមត្ថកិច្ចតុលាការអន្តរជាតិចំពោះខ្ទង់ក្នុងរឿងក្តីព្រះវិហារ ហើយប្រើអាកប្បកិរិយាយ៉ាងកាចសាហាវមកលើកម្ពុជា ក្នុងរឿងព្រះវិហារនេះទៀតផង ។ អ្នកតំណាងក្រុងទាំងអស់ក៏បាននាំគ្នាបន់ស្រន់ដល់ព្រះពាន់ ដែលមានព្រះពុទ្ធនៃពនលិចជាប្រធាន សូមឲ្យព្រះតេជៈបារមី ជួយឲ្យខ្មែរបានឈ្នះក្តីព្រះវិហារនេះ ។

លុះដល់មកថ្ងៃទី ១៩ មិថុនា ១៩៦២ ខ្មែរក៏បានឈ្នះក្តីព្រះវិហារនេះដូចជាបំណន់មែន ។

ហេតុដូច្នេះ បានជាអ្នកតំណាងរាស្ត្រទាំងអស់ បាននាំគ្នាមកធ្វើបុណ្យដាក់បាត្រលាបំណន់នឹងថ្វាយភ្លេងពិណពាទ្យ ៧ ចប់ ។

## ព្រះរាជពិធីបុណ្យរំលឹកជ័យជំនះក្តីព្រះវិហារ
## នៅខេត្តសៀមរាប ក្នុងថ្ងៃទី ៩ កក្កដា

ថ្ងៃទី ៩ កក្កដា ជាថ្ងៃទី ៧ នៃព្រះរាជពិធីបុណ្យបួងសួងលាព្រះបំណន់ នឹងរំលឹកដល់ជ័យជំនះរឿងក្តីព្រះវិហារ នៅខេត្តសៀមរាប ។ ព្រះរាជពិធីនៅថ្ងៃនេះ ក៏គ្មានអ្វីប្លែកដែរ ដោយបានប្រារព្ធឡើងជាពិធីបុណ្យតាមទំនៀមទម្លាប់នៃព្រះពុទ្ធសាសនាគឺនៅព្រះរាជតំណាក់ខេត្តសៀមរាប វេលាម៉ោង៧ព្រឹក សម្តេចព្រះមាតាជាតិជាទីគោរពនឹងសម្តេចព្រះប្រមុខ-រដ្ឋ បាននិមន្តព្រះសង្ឃមួយរយអង្គ ដែលមានព្រះតេជព្រះគុណព្រះ-ពោធិវង្ស ហួត-តាត អគ្គាធិការនៃពុទ្ធិកសិក្សាក្នុងព្រះរាជាណាចក្រ នឹងព្រះតេជព្រះគុណមេគណខេត្តសៀមរាប ជាប្រធានសង្ឃ និមន្តមកជាអធិបតីដើម្បីដាក់បាត្រជាកិច្ចថ្វាយព្រះរាជកុសល ដល់ព្រះអតីតព្រះមហាក្សត្រខ្មែរទាំងឡាយ ។

ពេលដែលព្រះសង្ឃបាននិមន្តមកដល់ហើយ សម្តេចព្រះមាតាជាតិជាទីគោរពដោយមានសម្តេចព្រះប្រមុខរដ្ឋ សម្តេចក្រុមព្រះ ស៊ីសុវត្ថិ-

មុនីវេត ប្រធានឧត្តមក្រុមប្រឹក្សាព្រះរាជបល្ល័ង្ក សម្តេចព្រះរាជកនិដ្ឋា រស្មីសោភ័ណ ព្រមទាំងព្រះរាជបរិពារជាន់ខ្ពស់ជាច្រើនអមព្រះរាជ-ដំណើរផង បានស្តេចយាងចេញពីព្រះរាជដំណាក់មកគង់ប្រថាប់នៅព្រះពន្លាជ័យ ។

តមក ព្រះសង្ឃក៏បានស្វាធ្យាយធម៌ជយន្តោប្រសិទ្ធិពរជ័យនិងធ្វើកត្តានុមោទនា ជាកិច្ចថ្វាយព្រះរាជកុសលក្នុងពិធីដាក់បាត្រនេះ ។

បន្ទាប់ពីនេះមក ព្រះសង្ឃទាំងឡាយ ក៏បាននិមន្តទទួលបង្ហាន់បិណ្ឌបាត្រ ហើយសម្តេចព្រះមាតាជាតិ និងសម្តេចព្រះប្រមុខរដ្ឋ ព្រះរាជវង្សានុវង្ស សមាជិកឧត្តមក្រុមប្រឹក្សាព្រះរាជបល្ល័ង្ក គណៈរដ្ឋមន្ត្រី សមា-ជិកសភាទាំងពីរខ្ទះ ចៅហ្វាយខេត្រនានា មន្ត្រីខេត្រ ព្រមទាំងពុទ្ធបរិស័ទប្រុសស្រីជាច្រើន បានស្តេចយាង និងអញ្ជើញដាក់បាត្រព្រះសង្ឃទាំង ១០០ អង្គ ក្រោមបរិយាកាសដ៏សែនរីករាយ ។

## ព្រះរាជពិធីបួងសួងថ្វាយវត្តសក្តិសិទ្ធិ
## នៅប្រាសាទអង្គរ ក្នុងថ្ងៃទី ១០ កក្កដា ១៩៦២

នៅថ្ងៃទី ១០ កក្កដា ១៩៦២ ជាថ្ងៃចុងក្រោយបំផុតនៃព្រះរាជពិធីបួងសួងលាព្រះបំណន់ និងពិធីបុណ្យរំលឹកដល់ជ័យជំនះក្នុងរឿងក្តីប្រា-សាទព្រះវិហារនៅទីរួមខេត្រសៀមរាប ។ ព្រះរាជពិធីនាថ្ងៃនេះ ក៏បានប្រព្រឹត្តទៅដូចជាថ្ងៃមុនៗដែរ គឺនៅវេលាព្រឹកមានមហាជនប្រុសស្រីចាស់

ក្មេងគ្រប់សាសន៍ បាននាំគ្នាទៅទស្សនាប្រាសាទបុរាណនានាជាធម្មតា ។ វេលាល្ងាច នៅប្រាសាទអង្គរវត្ត មានធ្វើពិធីបួងសួងថ្វាយវត្តសក្តិសិទ្ធិ ដ៏មហោរិក ដែលនៅទីនោះ មានការរៀបចំតាក់តែង រំលេចរចនាទៅ ដោយទន់ជាតិ គឺផ្កាយ៉ាងប្រសើរគួរជាទីទស្សនា ព្រមទាំងមានរៀបចំ ភោជ្យកស្តុក្រយាប្រណីត វិចិត្រដោយគ្រឿងទេសវិសេសវិសាលគ្រ-ការរុងរឿងជាគ្រឿងដង្វាយចំពោះវត្តសក្តិសិទ្ធិទាំងអស់ ព្រមទាំងមាន ការជួបជុំព្រះរាជវង្សានុវង្ស នាហ្មឺនសព្វមុខមន្ត្រី ទាហាន ស៊ីវិល យុវជន យុវតី និងប្រជាពលរដ្ឋជាច្រើនពាន់នាក់ ដែលបានស្ដេចយាង និង អញ្ជើញទៅ ដើម្បីរង់ចាំក្រាបថ្វាយបង្គំគាល់សម្ដេចព្រះមាតាជាតិជាទី គោរពនៅទីនោះ ។

នៅវេលាម៉ោង ៨ ល្ងាច សម្ដេចព្រះមាតាជាតិជាទីគោរព ដោយ មានសម្ដេចព្រះប្រមុខរដ្ឋ សម្ដេចក្រុមព្រះប្រធានឧត្តមក្រុមប្រឹក្សាព្រះរាជ បល្ល័ង្ក ព្រះរាជវង្សានុវង្សខ្លះ និងព្រះរាជបរិពារជាន់ខ្ពស់ផ្ទាល់ព្រះអង្គអម ព្រះរាជដំណើរផង បានស្ដេចយាងទៅដល់ប្រាសាទអង្គរវត្ត ជាកន្លែង ប្រារព្ធព្រះរាជពិធីបួងសួងលាព្រះបំណន់ ។

តមក ហ្មឺនពេជ្រសុរិយា ញ៉ែម-ចន ក៏បានសូត្រប្រកាសបួងសួង លាព្រះបំណន់ ។ លុះចប់សេចក្ដីប្រកាសបួងសួងនេះហើយ ក្រុម ល្ខោនព្រះរាជទ្រព្យ ក៏បានចេញមករាំថ្វាយវត្តដ៏សក្តិសិទ្ធិទាំងឡាយ

ដោយបានកាច់ក្បាច់យ៉ាងស្រស់ឆើតឆាយ ហាក់បីដូចជាកិន្នរី នឹងទេពអប្សរបរកញ្ញានៃចម្លាក់ប្រាសាទអង្គរ ដោយមានក្រុមភ្លេងពិណពាទ្យព្រះរាជទ្រព្យ បានបន្ទរទូរបទនានាជាចង្វាក់នៃការរាំនេះផង ។

ព្រះរាជពិធីនេះ បានប្រព្រឹត្តទៅក្នុងបរិយាកាសដ៏ជាទីរីករាយក្រៃលែង ។

## ព្រះរាជពិធីបួងសួងលាព្រះបំណន់នៅព្រះវិហារសួរ ស្រុកខ្សាច់កណ្ដាល (កណ្ដាល)

នៅថ្ងៃទី ១៨ ខែកក្កដា ១៩៦៦, ពេលរសៀល សម្ដេចព្រះបិតាជាតិ ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុតនៃប្រជាពលរដ្ឋខ្មែរទាំងមូល ព្រះអង្គបានស្ដេចយាងប្រាព្ធ ព្រះរាជពិធីបួងសួងលាព្រះបំណន់នៅវត្តព្រះវិហារសួរ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ។

នៅពេលម៉ោង៤ទឹង ៣០នាទីរសៀល ព្រះទីនាំងទន្ទាគបក្រពិសេសរបស់ព្រះអង្គមួយគ្រឿង ដោយមានអាកាសយានទាំងឡាយហោះអមផង បានដឹកនាំព្រះរាជដំណើររបស់ព្រះអង្គ មកចុះចតនៅលើមណ្ឌលចុងភូមិព្រះវិហារសួរដែលគេបានរៀបចំទុក ។ នៅពេលយាងចុះពីព្រះទីនាំងភ្លាមព្រះអង្គបានទទួលកូនផ្កាអំពីកញ្ញាដ៏ស្រស់ឆើតឆាយបីរូបនៃភូមិព្រះវិហារ-សួរ ជានិមិត្តរូបនៃការថ្វាយព្រះពរសព្វសាធុការយ៉ាងឧត្ដមចំពោះព្រះអង្គ នឹងដើម្បីជានិមិត្តរូបនៃសេចក្ដីស្នេហានឹងស្វាមីភក្ដិដ៏ស្មោះស្ម័គ្រផង ។

បន្ទាប់មក ព្រះអង្គបានទទួលការក្រាបថ្វាយបង្គំអំពីឥស្សរជនច្រើនរូបជាអាទិ៍គឺ ឯកឧត្តមទៀង-គាង ឯកឧត្តមគូ-រុន សមាជិកឧត្តមក្រុមប្រឹក្សាព្រះរាជបល្ល័ង្ក លោកឧត្តមសេនីយ៍ឯកលន់-ណុល ទេសរដ្ឋមន្ត្រីទទួលបន្ទុកខាងក្រសួងការពារប្រទេស ឯកឧត្តមប៉ាច-ឈឿន រដ្ឋមន្ត្រីក្រសួងធម្មការ ហើយបន្ទាប់មកទៀត ព្រះអង្គបានទទួលគារវកិច្ចយ៉ាងខ្លាំងខ្លាស់បំផុត អំពីកងយោធពលខេមរភូមិន្ទ កងរាជតម្រួត កងអាសាស្ម័គ្រ យុវជនរាជសង្គមនិយមខ្មែរជាច្រើនក្រុមដែលបានលើកអាវុធធ្វើវន្ទនកិច្ចនិងបន្លឺនូវបទភ្លេងចរលើលា និងភ្លេងជាតិថ្វាយជាព្រះរាជកិត្តិយសចំពោះព្រះអង្គ រួចហើយស្តេចយាងឡើងព្រះទីនាំងរថយន្តយានព្រះរាជដំណើរ ចូលមកកាន់វត្តព្រះវិហារសួរ ដែលមានចម្ងាយជាង ៥០០ម. ពីកន្លែងចុះព្រះទីនាំងទម្លាក់ចក្រ ៗ ក្រោយពេលដែលបានយាងចូលមកដល់ទីវត្តហើយ ព្រះអង្គបានយាងឡើងលើខឿនព្រះវិហារដែលគាត់តែងរៀបចំយ៉ាងស្រស់ដោយភ្ញីផ្កា និងរំយោលនានាគួរជាទីគយគន់ ៗ បន្ទាប់មកព្រះអង្គបានក្រាបថ្វាយបង្គំព្រះសង្ឃជាច្រើនអង្គ ដែលគង់ក្នុងទីនោះមានព្រះតេជព្រះគុណអនុគណជាប្រធាន ហើយព្រះអង្គបានទទួលការក្រាបថ្វាយបង្គំអំពីឥស្សរជនជាច្រើនរូបទៀត ៗ

ក្រោយពេលដែលទ្រង់គង់ប្រថាប់ សម្រួលព្រះឥរិយាបថបន្តិចមក ក្រុមយុវជន យុវតីនៃដំបន់ព្រះវិហារសួរមួយក្រុមបានច្រៀងនូវចម្រៀង

ថ្វាយពរជ័យចំពោះព្រះអង្គ ។

លុះចប់ចម្រៀងថ្វាយព្រះពរជ័យហើយ សម្តេចនុជាទីគោរព បាន ទ្រង់ថ្លែងព្រះរាជសន្ថាមួយរៀបរាប់អំពីនយោបាយក្នុងប្រទេសខ្មែរ នឹង ក្រៅប្រទេសខ្មែរ ដែលពោរពេញដោយទុក្ខគតិយុត្តិធម៌ ។

លុះចប់ សម្តេចព្រះបិតាជាតិ បានស្តេចយាងចូលកាន់រោងក្រសាល សម្រាប់ប្រារព្ធពិធីបួងសួងលាព្រះបំណន់ ដែលតាំងនៅអមតួព្រះវិហារ ធំដែលតំកល់ព្រះពុទ្ធបដិមាករមានព្រះបារមីយ៉ាងពូកែស័ក្តិសិទ្ធ ហើយ នៅពេលជាបន្ទាប់គ្នានោះ មានចាប់ផ្តើមពិធីនមស្សការថ្វាយបង្គំ ចំពោះ គុណព្រះរតនត្រៃយ៉ាងកងរំពង ។

បន្ទាប់ពីពិធីនមស្សការព្រះរតនត្រៃនេះមក សម្តេចព្រះបិតាជាតិ ជាទីគោរពដោយមានព្រះរាជបរិពារអមព្រះរាជដំណើរផង បានស្តេច យាងចូលក្រាបថ្វាយបង្គំព្រះជ័រអង្គធំ ក្នុងតួព្រះវិហារធំដែលមានព្រះបារមី យ៉ាងពូកែស័ក្តិសិទ្ធអស្ចារ្យនោះ ដោយព្រះឥរិយាបថយ៉ាងរៀបរយ ប្រ. កបដោយព្រះកាយយ៉ាងទន់ភ្លន់ជាទីបំផុត រួចហើយស្តេចយាងនិវត្តន៍ ចូលមក ក្នុងព្រះរាជរោងក្រសាលវិញ ។

ចំណែកក្រុមសេវកាមាត្យទាំងឡាយ ក៏បានចាប់ផ្តើមធ្វើពិធីបួងសួង លាព្រះបំណន់ ដែលនៅទីនោះមានរៀបចំខាទនីយភោជនីយាហារក្រយា ស្លាបារី បាយសី ស្លាធម៌ យ៉ាងពោរពាស ដែលជាដំបូង

មុនពេជ្រសុរិយា ញែម.ចន កំបានសូត្រពាក្យលាព្រះបំណន់ដែលព្រះអង្គបានបន់ក្នុងរឿងក្តីប្រាសាទព្រះវិហារមានជ័យជំនះនេះ ។

បន្ទាប់ពីសេចក្តីប្រកាសលាព្រះបំណន់នេះរួចហើយ ក្រុមភ្លេងពិណពាទ្យព្រះរាជទ្រព្យក៏បានបន្លឺឡើង ហើយក្រុមកុមារីនៃរបាំព្រះរាជទ្រព្យបានចេញរាំថ្វាយព្រះអង្គជាកិច្ចបង្ហើយលាព្រះបំណន់ ។ ការរាំនេះបានប្រព្រឹត្តទៅយ៉ាងស្រស់ឆើតឆាយ ទន់ភ្លន់គួរជាទីចាប់អារម្មណ៍យ៉ាងក្រៃលែង ។

ពិធីនេះបានប្រព្រឹត្តទៅដ៏សែនរីករាយពន់ពេក ។

---

សម្តេចទ្រង់រិទ្ធិ សីហនុបពិត្រ
ដែនកម្ពុជា ទ្រង់ផ្ចាញ់សត្រូវ
ដោយព្រះធម្មា បានព្រះវិហារ
វិលចូលសីមា ។ ពួកអន្តរជាតិ
ជាប់ចិត្តសុទ្ធសាធ នឹងព្រះបញ្ញា
ឧត្តមគតិ ដោះស្រាយបញ្ហា
តាមបញ្ចសីលា ទៀងទាត់កន្លង

ដេង - ជ្រី